ត្រូវអប់រំជំនឿត្រូវការ
ជំនឿនិងទ្រឹស្ដី <ទំព័រៈ ១៨



ទ្រឹស្ដសាសនានិងពុទ្ធសាសនា
រួមគ្នាជួយអ្នកក្រីក្រ <ទំព័រៈ ១៩



កាសែតចេញផ្សាយ
ប្រចាំខែ ឆ្នាំទី១២

# អ្នកនាំសារ
# the messenger

ខែ កញ្ញា | ឆ្នាំ ២០២២ | លេខទី ១៥៤

www.catholiccambodia.org/km/ www.facebook.com/RVAKHMER/ https://khmer.rvasia.org/ September, 2022 | #154

# បុណ្យភ្ជុំរំលឹកដល់មរណបុគ្គលតាមប្រពៃណីខ្មែរ



បុណ្យភ្ជុំជាពេលវេលាដែល នឹកឃើញដល់មរណបុគ្គលទាំងឡាយតាមរបៀបប្រពៃណីនៅប្រទេសកម្ពុជា ហើយសម្រាប់ព្រះសហគមន៍កាតូលិក យើងគោរពដល់វិញ្ញាណក្ខន្ធ និងនឹកដល់ជីវិតរបស់យើងដែលបានស្រឡាញ់ព្រះជាម្ចាស់និងបងប្អូនឯទៀតៗ។ នេះជាប្រសាសន៍របស់លោកអភិបាលអូលីវីយេ ជ្មីតហាស្លេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ នាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២២។ លោកអភិបាលមានប្រសាសន៍ទៀតថា យើងអធិដ្ឋានសម្រាប់បងប្អូនដែលស្លាប់ ដើម្បីឱ្យគេជម្រះចិត្តគំនិតរបស់គេម្ដងទៀតរហូតដល់អាចមើលឃើញព្រះជាម្ចាស់ផ្ទាល់ភ្នែក។ លោកបន្ថែមថា នៅពេលនេះ យើងក៏អធិដ្ឋានសូមព្រះអង្គថែរក្សាបងប្អូនរបស់យើងដែលទទួលមរណភាព និងលើកលែងទោសឱ្យពួកគាត់។ លោកអភិបាលរំឭកគ្រីស្ដបរិស័ទទាំងអស់ឱ្យត្រៀមខ្លួនជានិច្ច ព្រោះជីវិតមិនទៀងទាត់ អាចមានជំងឺ ឬគ្រោះថ្នាក់ចរាចរណ៍ ដោយមិនដឹងជាមុន។ ប៉ុន្តែអ្វីដែលសំខាន់នោះ ពេលរស់នៅប្រចាំថ្ងៃ គឺត្រូវយកចិត្តទុកដាក់សួរសុខទុក្ខអ្នកជំងឺ អ្នកជាប់ឃុំឃាំង ផ្ដល់ម្ហូបដល់អ្នកស្រេកឃ្លាន និងឱ្យអាវទៅមនុស្សខ្លួនទទេ និងរៀបចំបុណ្យសពត្រឹមត្រូវសម្រាប់អ្នកស្លាប់ ទាំងនេះជគឺជាកិច្ចការទាំង៧នៃធម៌មេត្តាករុណាដែលគ្រីស្ដបរិស័ទត្រូវតែធ្វើ។

នៅក្នុងឆ្នាំ១៩៧០ បុរីវ៉ាទីកង់បានអនុញ្ញាតឱ្យព្រះសហគមន៍កាតូលិកប្រារព្ធពិធីបុណ្យមរណបុគ្គលនៅថ្ងៃបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែរ ព្រោះបុណ្យនេះមានអត្ថន័យដូចគ្នានឹងពិធីបុណ្យរបស់ព្រះសហគមន៍។ នេះបើយោងតាមសៀវភៅកត់ត្រាThe Rice Paddyរបស់លោកបូជាចារ្យហ្វ្រង់ស្វ័រ ប៉ុងសូដ៍។

## កម្ពុជាទទួលបានពានរង្វាន់ពិភពលោកចំនួន ២ គឺទេសចរណ៍វប្បធម៌ និង ទេសចរណ៍យុវជនឈានមុខ

ទំព័រ-៩



## កម្ពុជានឹងមានបូជាចារ្យពរូបបន្ថែមទៀតក្នុងពេលឆាប់ៗ

ទំព័រ-១៦

## ការចែកទានគឺជាទង្វើល្អនិងការជួយដែលកើតចេញពីទឹកចិត្តនឹងសេចក្ដីពិតដែលទទួលបានពីព្រះជាម្ចាស់

ទំព័រ-១៧



# ហេតុអ្វីគ្រីស្តបរិស័ទកាតូលិក រំលឹកដល់មរណបុគ្គល ដូចប្រជាជនខ្មែរពុទ្ធសាសនា?

ប្រជាជនខ្មែរមានទំនៀមទំលាប់មួយ គឺរំលឹកដល់អ្នកដែលបានស្លាប់ទៅហើយ ជាពិសេសគឺញាតិសន្តានទាំង៧របស់ខ្លួនក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ។

ទំនៀមនេះ មិនខុសពីព្រះសហគមន៍កាតូលិកនោះឡើយ គឺព្រះសហគមន៍បានរំលឹកដល់អ្នកដែលបានស្លាប់ទៅហើយជារៀងរាល់ឆ្នាំក្នុងថ្ងៃទី២ ខែវិច្ឆិកាខាងមុខនេះ។

**តើការរំលឹកនេះមានអត្ថន័យយ៉ាងណា?**

ព្រះសហគមន៍កាតូលិកជឿថា ពេលមនុស្សស្លាប់ទៅហើយ គេនឹងទៅកន្លែងចំនួន៣ផ្សេងពីគ្នាតាមអំពើដែលពួកគេបានប្រព្រឹត្ត គឺទី១ ស្ថានបរមសុខ ដែលជាព្រះដំណាក់របស់ព្រះជាម្ចាស់សម្រាប់មនុស្សដែលសុចរិតគាប់ព្រះហទ័យព្រះអង្គ។ ទី២គឺស្ថាននរក ដែលយើងបានឮជាច្រើនលើកក្នុងគម្ពីរដំណឹងល្អ ជាពិសេសអំពីអ្នកមាននិងអ្នកក្រឡាសា (លក១៦,១៩-៣១) គឺអស់អ្នកដែលមិនដែលចាប់អារម្មណ៍នឹងសេចក្តីពិតនិងសុចរិត ពោលគឺគ្មានជំនឿនិងសេចក្តីស្រឡាញ់។ ទី៣ គឺស្ថានជម្រះ ជាទីឋានដែលត្រូវកែប្រែចិត្តឡើងវិញសម្រាប់មនុស្សដែលខិតខំប្រឹងប្រែងធ្វើតាមព្រះហឫទ័យព្រះជាម្ចាស់ តែទោះជាយ៉ាងណាក៏នៅមានផ្តាំផ្តងខ្លះ ដូច្នេះពួកគេត្រូវការពេលវេលាមួយពិសេសដើម្បីលន់តួបាបរបស់ខ្លួន។



ស្ថានជម្រះនេះសំខាន់ណាស់ ជាទីដែលព្រលឹងត្រូវបានសម្អាតមុនពេលចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ គឺស្ថានបរមសុខ។ ដោយហេតុនេះហើយ ព្រះសហគមន៍បានទូលអង្វរព្រះជាម្ចាស់សម្រាប់អស់វិញ្ញាណទាំងឡាយនៅក្នុងឋានជម្រះនោះ «[16] [...] ពាក្យទូលអង្វររបស់មនុស្សសុចរិតមានប្រសិទ្ធភាពខ្លាំងណាស់(យក៥,១៦)» ដើម្បីសុំព្រះជាម្ចាស់លើកលែងទោសឱ្យពួកគាត់ទាំងនោះ ឱ្យបានចូលក្នុងស្ថានបរមសុខជាមួយព្រះអង្គ។

ព្រះជាម្ចាស់តែងតែផ្ទៀងព្រះការណ៍ស្តាប់ពាក្យទូលអង្វរជានិច្ច(១សិលា៣,១២) ហើយធម៌មេត្តាករុណារបស់ព្រះអង្គធំធេងណាស់ ដែលយើងមិនអាចស្មានដល់បាន។

**ហេតុផលនៃការទូលអង្វរព្រះជាម្ចាស់សម្រាប់អ្នកស្លាប់៖**

យើងអាចមើលក្នុងគម្ពីរនៅពេលដែលលោកយូដាប្រយុទ្ធយកក្រុងនានា ក្រោយពេលបញ្ចប់សង្គ្រាម ពលទ័ពរបស់លោកប្រមូលសពទាហាន ហើយលោកបានរៃប្រាក់ធ្វើយញ្ញបូជារំដោះបាបសម្រាប់ទាហានដែលស្លាប់។

ក្នុងគម្ពីរ២ម៉ាកាបាយ ១២,៤៣-៤៦ « [43] លោកយូដារៃប្រាក់ពីកងទ័ពបានប្រហែលពីរពាន់កាក់ ហើយផ្ញើកាក់នេះទៅក្រុងយេរូសាឡឹម ដើម្បីឱ្យគេថ្វាយយញ្ញបូជារំដោះបាប។ លោកធ្វើដូច្នេះ ជាអំពើដ៏ល្អប្រពៃ និងថ្លៃថ្នូរផង ដោយនឹកគិតថា មនុស្សស្លាប់នឹងរស់ឡើងវិញជាពុំខាន។៤៤ ប្រសិនបើលោកមិនសង្ឃឹមថាពលទាហានដែលបាត់បង់ជីវិតមិនរស់ឡើងវិញទេ លោកក៏មិនឆោតល្ងង់ ទូលអង្វរព្រះជាម្ចាស់ សម្រាប់មនុស្សស្លាប់ដែរ។ ទោះបីលោកទូលអង្វរព្រះអង្គដូច្នេះ ក៏គ្មានន័យ ហើយក៏ឥតបានការអ្វីឡើយ។ [45] ប៉ុន្តែ លោកនឹកគិតថា ព្រះជាម្ចាស់មុខជាប្រទានរង្វាន់ដ៏ប្រសើរបំផុត ដល់មនុស្សស្លាប់ទាំងគោរពប្រណិប័តន៍ព្រះអង្គ។ នេះពិតជាគំនិតដ៏វិសុទ្ធរបស់អ្នក ដែលគោរពប្រណិប័តន៍ព្រះអង្គមែន។ [46] អាស្រ័យហេតុនេះហើយ បានជាលោកសូមឱ្យគេថ្វាយសក្ការបូជារំដោះបាប ដើម្បីសូមព្រះជាម្ចាស់ លើកលែងទោសឱ្យពលទាហាន ដែលបាត់បង់ជីវិត»

ពិធីរំលឹកដល់មរណបុគ្គលនេះក៏ត្រូវបានប្រារព្ធឡើងនៅព្រះសហគមន៍ខាងកើតហៅថាអូតូដុក និងនិកាយអង់គ្លីខិនផងដែរ។ ប៉ុន្តែក្រុមជំនុំផ្សេងទៀតមិនយល់ស្របអំពីទេវវិទ្យាមួយនេះទេ។

តាមរបៀបពុទ្ធសាសនា យើងឃើញថា ប្រជាជនបានយកចង្ហាន់ទៅវត្ត វេរប្រគេនព្រះសង្ឃដើម្បីឧទ្ទិសដល់វិញ្ញាណអ្នកស្លាប់ដែលស្ថិតនៅក្នុងឋាននរក ឬប្រេត។

ការរៀបចំពិធីមានលក្ខណៈខុសគ្នារវាងពុទ្ធសាសនា និងព្រះសហគមន៍កាតូលិក តែទោះជាយ៉ាងណាពិធីនេះមានទិសដៅតែមួយ គឺជួយដល់ព្រលឹងរបស់មនុស្សស្លាប់ឱ្យរួចពីទុក្ខវេទនា។

តាមឯកសារប្រវត្តិសាស្ត្រដែលរៀបចំចងក្រងដោយលោកបូជាចារ្យហ្វ្រង់ស្វ័រប៉ុងស្វដ៍(MEP) បានសរសេរថា ក្នុងឆ្នាំ១៩៧០ បុរីវ៉ាទីកង់បានអនុញ្ញាតឱ្យគ្រីស្តបរិស័ទកាតូលិកនៅក្នុងប្រទេសកម្ពុជា ប្រារព្ធពិធីបុណ្យរំលឹកដល់មរណបុគ្គលរួមជាមួយប្រជាជនខ្មែរ ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌដែលបានធ្វើជារៀងរាល់ឆ្នាំ៕

CSC
Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក
ចាងហ្វាង : លោក លី សុវណ្ណា
សេចក្តីប្រកាសលេខ៖ លេខចុះបញ្ជី២០២២៖ ១២៧៩|២២ធត.ប្រ
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Contact: (855) 17 726 060
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

# សម្តេច ហ៊ុន សែន៖ កម្ពុជានឹងបន្តជំរុញការយកចិត្តទុកដាក់លើការអភិវឌ្ឍប្រសិទ្ធភាពថាមពល និងថាមពលកកើតឡើងវិញ



*អត្ថបទ៖ អមរិទ្ធ ដានុត*

ក្នុងឆ្នាំ ២០២១ កន្លងមកនេះ ថាមពល ដែលបានមកពីប្រភពថាមពល កកើតឡើងវិញ រួមមាន វារីអគ្គិសនី ថាមពលដើរដោយពន្លឺព្រះអាទិត្យ និង ថាមពលជីវម៉ាស់ បានកើនឡើងទៅដល់ ៤០% នៃថាមពលសរុបរបស់កម្ពុជា។

ម្យ៉ាងទៀត បើពិនិត្យមើលតាមទំហំអានុភាព នៃប្រភពថាមពល របស់កម្ពុជា ចំណែកអានុភាព នៃប្រភពថាមពលកកើតឡើងវិញ គឺមានរហូតដល់ ៥៥% នៃអានុភាពតម្លើងសរុប។ នេះជាប្រសាសន៍លើកឡើង របស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងជាប្រធានអាស៊ានឆ្នាំ២០២២ ក្នុងឱកាសបើកកិច្ចប្រជុំ រដ្ឋមន្ត្រីថាមពលអាស៊ាន លើកទី ៤០ កិច្ចប្រជុំពាក់ព័ន្ធ នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ ។

សម្តេច ហ៊ុន សែន មានប្រសាសន៍ថា ៖ «សម្រាប់ទិសដៅទៅមុខ កម្ពុជានឹងបន្តជំរុញការយកចិត្តទុកដាក់លើការអភិវឌ្ឍប្រសិទ្ធភាពថាមពល និងថាមពលកកើតឡើងវិញ ឱ្យបានអតិបរមា និងជាបន្តបន្ទាប់ ទៅតាមលទ្ធភាពទទួល បានរបស់ប្រព័ន្ធផ្គត់ផ្គង់ថាមពលកម្ពុជា ជាមួយនឹងការកាត់បន្ថយការអភិវឌ្ឍគម្រោងប្រភពថាមពល ដែលប្រើប្រាស់ឥន្ធនៈហ្វូស៊ីល ដែលមានធ្យូងថ្ម និងប្រេងជាដើម»។

ដើម្បីសម្រេចទិសដៅនេះ រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងសហការជាមួយដៃគូអភិវឌ្ឍន៍នានា ក្នុងការសិក្សា និងរៀបចំផែនការមេអភិវឌ្ឍន៍វិស័យថាមពលកម្ពុជា រហូតដល់ឆ្នាំ ២០៤០ គោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ផែនទីបង្ហាញផ្លូវ ស្តីពីការអភិវឌ្ឍអន្តរកាលថាមពលស្អាត ឆ្ពោះទៅអព្យាក្រឹត្យភាពកាបូន និងគោលនយោបាយអភិវឌ្ឍន៍ ថាមពលពន្លឺព្រះអាទិត្យ លើដំបូលនៅកម្ពុជា។

សូមបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជា នៅខែកុម្ភៈ ឆ្នាំ២០២២ កន្លងទៅនេះ បានដាក់ចេញយុទ្ធសាស្ត្រ អភិវឌ្ឍន៍រយៈពេលវែង ប្រកបដោយអព្យាក្រឹតកាបូន LTS4CN ដែលរំពឹងថានឹងសម្រេចបានការងារអព្យាក្រឹតកាបូននៅឆ្នាំ២០៥០។

ការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែង ប្រកបដោយអព្យាក្រឹតកាបូន«LTS4CN» នេះ គឺជាសក្ខីភាពបញ្ជាក់នូវការប្តេជ្ញាចិត្ត របស់កម្ពុជា ចំពោះកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុ និងបង្ហាញនូវសេណារីយ៉ូ គោលនយោបាយ ដើម្បីធ្វើឱ្យសម្រេចបាននូវចក្ខុវិស័យនៃសង្គមមួយប្រកបដោយអព្យាក្រឹតកាបូន និងមានភាពធន់ក្នុងរយៈពេល ៣០ឆ្នាំខាងមុខ។

យុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន ត្រូវបានអនុម័ត និងដាក់ជូនលេខាធិការដ្ឋានអនុសញ្ញាក្របខ័ណ្ឌសហប្រជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ។

សម្រាប់ការផលិតថាមពល យុទ្ធសាស្ត្រនេះ បានធ្វើការបញ្ចូលការប្តេជ្ញាចិត្តថ្មីៗ របស់កម្ពុជា ក្នុងការមិនសាងសង់រោងចក្រថាមពលធ្យូងថ្មថ្មី និងគោលដៅថាមពលកកើតឡើងវិញ ៣៥% ក្នុងប្រភពថាមពលចម្រុះត្រឹមឆ្នាំ ២០៥០ ។ ជាមួយគ្នានេះ យុទ្ធសាស្ត្រក៏បានដាក់គោលដៅកាត់បន្ថយការដុតសំណល់នៅទីវាល ឱ្យបាន ៨៥% ផងដែរ៕

# ក្រសួងសុខាភិបាល បន្តលើកទឹកចិត្តប្រជាពលរដ្ឋ ឱ្យធ្វើតេស្តរហ័សរកមេរោគកូវីដ១៩ដោយខ្លួនឯង




*អត្ថបទ៖ អមរិទ្ធ ដានុត*

រដ្ឋមន្ត្រីក្រសួងសុខាភិបាល លោក ម៉ម ប៊ុនហេង នៅតែបន្តអំពាវនាវ និងលើកទឹកចិត្តទៅដល់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ ដែលមានការសង្ស័យថាខ្លួនមានមេរោគកូវីដ១៩ ត្រូវធ្វើតេស្តរហ័ស ដោយខ្លួនឯង និងត្រូវដាក់ខ្លួននៅដាច់ដោយឡែកភ្លាមនៅពេលទទួលបាន លទ្ធផលតេស្តរហ័សវិជ្ជមានវីរុសកូវីដ-១៩ ។

លោកបានមានប្រសាសន៍ថា ៖ «ក្រសួងសុខាភិបាល សូមលើកទឹកចិត្តដល់បុគ្គលម្នាក់ៗ អនុវត្តការធ្វើតេស្តរហ័សដោយខ្លួនឯង ក្នុងករណីដែលមានស្ថានភាពសង្ស័យ ឬមានរោគសញ្ញាណាមួយដែលសង្ស័យ និងត្រូវដាក់ខ្លួននៅដាច់ដោយឡែកភ្លាម នៅពេលទទួលបាន លទ្ធផលតេស្តរហ័សវិជ្ជមានវីរុសកូវីដ-១៩ ដើម្បីចៀសវាងការចម្លងទៅកាន់ក្រុមគ្រួសារ និងបុគ្គលដទៃទៀត»។

លោក ម៉ម ប៊ុនហេង បានបន្ថែមថា អ្នកជំងឺអាចធ្វើការព្យាបាលដោយខ្លួនឯងតាមការណែនាំរបស់ក្រសួងដែលធ្លាប់ បានផ្សាយជូនកន្លងមកជារឿយៗ ឬស្វែងរកការព្យាបាលពីគ្រូពេទ្យជំនាញត្រឹមត្រូវ ឬទៅកាន់មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត បើមានរោគសញ្ញាដែលសង្ស័យមានការវិវត្តន៍ទៅរកសភាពធ្ងន់ធ្ងរ។

យោងតាមរបាយការណ៍ របស់អង្គការសុខភាពពិភពលោក (WHO) ស្ថានភាពនៃការចម្លងវីរុសកូវីដ-១៩នៅលើសកលលោក បានបង្ហាញថា មាន ករជំងឺកូវីដ-១៩ សរុបចំនួនជាង ៦០០លាននាក់ ដែលក្នុងនោះមានអ្នកស្លាប់សរុបជាង ៦លាន ៤០០ពាន់នាក់ គិតត្រឹម ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២២ ។

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងភាពឈ្លាសវៃ របស់ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន កម្ពុជាបានគ្រប់គ្រង និងឆ្លើយតបទៅនឹងការរាតត្បាតវីរុសកូវីដ-១៩ បានយ៉ាងល្អប្រសើរ ហើយការស្រោចស្រពវ៉ាក់សាំងកូវីដ-១៩ ទទួលបានអត្រាគ្របណ្តប់រហូតដល់ប្រមាណជា៩៥% ក្នុងចំណោម ប្រជាជនប្រមាណជា ១៦លាននាក់។

លោក ម៉ម ប៊ុនហេង បានថ្លែងថា ៖ «ដូច្នេះ ដើម្បីរក្សាបាននូវការរស់នៅតាមបែបគន្លងប្រក្រតីភាពថ្មីរបស់បងប្អូនប្រជាពលរដ្ឋ ការបន្តអនុវត្តនូវវិធានការការពារទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ របស់បុគ្គល គ្រួសារ និងសហគមន៍ ត្រូវតែបន្តធ្វើជាចាំបាច់ ដើម្បីរួមចំណែកទប់ស្កាត់នូវការផ្ទុះការចម្លងវីរុសកូវីដ-១៩ក្នុងទ្រង់ទ្រាយធំនៅក្នុងសហគមន៍យើងសារជាថ្មីឡើងវិញ»។

ដើម្បីសុវត្ថិភាព និងភាពរីករាយក្នុងក្រុមគ្រួសារ សូមលោកអ្នកអនុវត្តបន្តប្រកបដោយការ បង្កើនការប្រុងប្រយ័ត្នខ្ពស់ ជាពិសេស អនុវត្តឱ្យបានខ្ជាប់ខ្ជួន និងឱ្យបានគ្រប់ៗគ្នា នូវវិធានការ «៣ការពារ (ពាក់ម៉ាស់ លាងដៃ ឱ្យញឹកញាប់ និងរក្សាគម្លាតសុវត្ថិភាពបុគ្គលពីមួយម៉ែត្រកន្លះឡើង) និង៣កុំ (កុំទៅកន្លែងមានមនុស្សច្រើន កុំទៅកន្លែងបិទ ជិតគ្មានខ្យល់ចេញចូល កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា កុំកៀកស្មាគ្នា)»៕

# កម្ពុជា-អូស្ត្រាលី បើកដំណើរការកម្មវិធីភាពជាដៃគូ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់

*អត្ថបទ៖ អមរិន្ទ ដានុត*

កម្ពុជានិងអូស្ត្រាលី បានប្រកាសដាក់ឱ្យបើកដំណើរការកម្មវិធីថ្មី ឈ្មោះថា ភាពជាដៃគូកម្ពុជា-អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ Cambodia Australia Partnership for Resilient Economic Development (CAP-RED) ដែលមានថវិកា ៨៧លាន ដុល្លារអូស្ត្រាលី។



CAP-RED ជាកម្មវិធីថ្មី មានរយៈពេល៥ឆ្នាំ ដែលត្រូវបានបង្កើតឡើង ផ្អែកលើជំនួយជាងមួយទសវត្សរ៍របស់អូស្ត្រាលី ដល់វិស័យកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា តាមរយៈកម្មវិធីខ្សែសង្វាក់ តម្លៃកសិកម្មកម្ពុជា-អូស្ត្រាលី (CAVAC) និងកម្មវិធីវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធ (3i) ដែលទើបតែបានបញ្ចប់ថ្មីៗនេះ។

កម្មវិធីទាំងពីរដែលទើបតែបានបញ្ចប់នេះ បានផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនកម្ពុជានៅតាមជនបទ ជាងពីរលាននាក់។ នេះបើយោងតាមសេចក្តីប្រកាសព័ត៌មានរបស់ស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា។

ស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា បានឱ្យដឹងថា កម្មវិធី CAP-RED ត្រូវបានបង្កើតឡើង បន្ទាប់ពីមានការពិគ្រោះយោបល់ដ៏ទូលំទូលាយជាមួយ ទាំងវិស័យសាធារណៈ និងឯកជន អំពីមធ្យោបាយដ៏ល្អប្រសើរបំផុត ដើម្បីជួយសេដ្ឋកិច្ចកម្ពុជាស្តារឡើងវិញបន្ទាប់ពីជំងឺកូវីដ-១៩ ។ កម្មវិធី CAP-RED នឹងជួយដល់រាជរដ្ឋាភិបាលកម្ពុជា និងសមភាគីពាក់ព័ន្ធផ្សេ ងៗទៀត បង្កើតគោលនយោបាយនានា ដែលជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន ភាពធន់ និងនិរន្តរភាព។

លោកព្រឹទ្ធសមាជិក Tim Ayres ឧបការីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាឧបការីរដ្ឋ មន្ត្រីក្រសួងផលិតកម្ម របស់អូស្ត្រាលី បានថ្លែងថា ឆ្នាំនេះជាខួបទី៧០ឆ្នាំ នៃទំនាក់ ទំនងការទូតរវាងកម្ពុជា និងអូស្ត្រាលី ហើយកម្មវិធី CAP-RED ជាភស្តុតាងរឹតតែច្បាស់ បន្ថែមទៀតនៃភាពជាដៃគូដ៏យូរអង្វែងរបស់ប្រទេសទាំងពីរ។

លោកថា ៖ «យើងរង់ចាំចែករំលែកចំណេះដឹង និងជំនាញ ជាមួយសមភាគីកម្ពុជារបស់យើង ដើម្បីបង្កើតបរិយាកាសអំណោយផលសម្រាប់ការវិនិយោគ ផលិតភាព និងពាណិជ្ជកម្ម»។

ដើម្បីសម្រេចបាននូវលទ្ធផលទាំងនេះ កម្មវិធីនេះនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងពាក់ព័ន្ធ និងផ្នែកពាក់ព័ន្ធនានាក្នុងវិស័យចំនួនបី ដើម្បីជំរុញកំណើន៖ សេវាហេដ្ឋារចនាសម្ព័ន្ធ កសិកម្ម និងក សិ-កែច្នៃ ព្រមទាំងការអភិវឌ្ឍ ពាណិជ្ជកម្ម ការវិនិយោគ និងសហគ្រាស។ កម្មវិធីនេះនឹងផ្តោតសំខាន់ ខ្លាំងលើ ការចែករំលែកការស្រាវជ្រាវ និងចំណេះដឹង ព្រមទាំងផ្តោតលើ សមភាពយេនឌ័រ ពិការភាព និង បរិយាបន្នសង្គម ផងដែរ។

លោក អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានមានប្រសាសន៍ឱ្យដឹងដែរថា កម្មវិធី CAP-RED ជាការរួមចំណែកយ៉ាងសំខាន់ ទៅដល់របៀប វារៈនៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា ដែលគាំទ្រដល់ការស្តារឡើងវិញ ភាពធន់ និងកំណែទម្រង់។

លោកថា កម្មវិធីនេះនឹងលើកទឹកចិត្តដល់ការវិនិយោគសាធារណៈ និងឯកជន ប្រកបដោយបរិយាបន្ន ដើម្បីជួយជំរុញ សេដ្ឋកិច្ចអោយកាន់តែមានភាពចម្រុះ និងបរិយាបន្ន។

លោក អូន ព័ន្ធមុនីរ័ត្ន មានប្រសាសន៍ថា ៖ «តាមរយៈភាពជាដៃគូនេះ យើងរំពឹងថា គ្រួសារកម្ពុជាមួយចំនួន ជាពិសេសគ្រួសារមកពីជនបទក្នុងប្រទេសកម្ពុជា ជាពិសេស ស្ត្រី កុមារី កុមារ មនុស្សចាស់ ជនមានពិការភាព និងក្រុមងាយរងគ្រោះ នឹងមានជីវភាពប្រសើរឡើង»៕

# អាមេរិកផ្តល់ជំនួយជាអគារ និងម៉ាស៊ីនផលិត អុកស៊ីសែនថ្មីមួយ នៅខេត្តព្រះវិហារ

*អត្ថបទ៖ អមរិន្ទ ដានុត*

រដ្ឋាភិបាលសហរដ្ឋអាមេរិកបានផ្តល់ជំនួយជាអគារ និងម៉ាស៊ីនផលិតអុកស៊ីសែនថ្មីមួយ មានទីតាំងនៅក្នុងខេត្តព្រះវិហារនៃប្រទេសកម្ពុជា ដែលនឹងផ្តល់អត្ថប្រយោជន៍ ដល់ប្រជាជនជិត ៣០០ ០០០ នាក់។

រោងចក្រនេះ មានទីតាំងនៅ មន្ទីរពេទ្យបង្អែកខេត្ត ១៦ មករា និងជាមូលនិធិរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍអន្តរជាតិ (USAID) ហើយត្រូវបាន សាងសង់ក្នុងភាពជាដៃគូជាមួយអង្គការយូនីសេហ្វ និងក្រសួងសុខាភិបាលកម្ពុជា។ នេះបើយោងតាមសេចក្តីប្រកាសព័ត៌មានរបស់ស្ថានទូតអាមេរិកប្រចាំកម្ពុជា នាថ្ងៃទី១៤ ខែកញ្ញានេះ។

ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា លោក W. Patrick Murphy មានប្រសាសន៍ថា ៖ «ម៉ាស៊ីននេះនឹងបំពេញតម្រូវការផលិតអុកស៊ីសែនសម្រាប់សេវាសំខាន់ៗ ដូចជា ការព្យាបាលអ្នកជំងឺ កូវីដ-១៩ ការតាមដាន និងការព្យាបាលជំងឺសង្គ្រោះបន្ទាន់»។

លោកថា វាជាផ្នែកមួយក្នុងទឹកប្រាក់ជាង ១៦ លានដុល្លារ នៅក្នុងការគាំទ្ររបស់រដ្ឋាភិបាលសហរដ្ឋអាមេរិកចំពោះការឆ្លើយតបរបស់កម្ពុជាលើជំងឺ រាតត្បាត និងជាឧទាហរណ៍ ដែលបង្ហាញនៃចំណងទាក់ទងដ៏រឹងមាំនៃប្រទេសទាំងពីរ។

ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវអគារនិងម៉ាស៊ីនផលិតអុកស៊ីសែននេះ ជាទីតាំងដំបូងគេនៅក្នុងខេត្ត។ មន្ទីរពេទ្យបង្អែកខេត្ត ១៦ មករា បានបម្រើដល់ស្រុកចំនួន ៧ ដែលមានប្រជាជនប្រមាណ ២៨៤ ០០០នាក់។

សេចក្តីប្រកាសព័ត៌មានដដែលនេះបានបន្តថា បន្ថែមពីលើការផ្តល់ការគាំទ្រ យ៉ាងសំខាន់សម្រាប់ការថែទាំអ្នកជំងឺ កូវីដ-១៩ ការផ្គត់ផ្គង់អុកស៊ីសែន ដែលអាចជឿទុកចិត្តនឹងផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់សហគមន៍ដែលពឹងផ្អែក លើសេវាព្យាបាលរបស់មន្ទីរពេទ្យ។

តំណាងអង្គការយូនីសេហ្វប្រចាំកម្ពុជា លោកស្រី Foroogh Foyouzat បានលើកឡើងដែរថា អុកស៊ីសែន អាចធ្វើឱ្យមានភាពខុសគ្នារវាងជីវិត និងសេចក្តីស្លាប់។ នេះជាមូលហេតុ ដែលអង្គការ យូនីសេហ្វ កំពុងធ្វើការជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកែលម្អការផ្គត់ផ្គង់អុកស៊ីសែននិងហេដ្ឋារចនាសម្ព័ន្ធ ទន្ទឹមនឹងការកសាងសមត្ថភាពបុគ្គលិកសុខាភិបាលក្នុងការប្រើប្រាស់វា» ។

លោកស្រីមានប្រសាសន៍ថា ៖ «យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសហរដ្ឋអាមេរិក និងជាពិសេសទីភ្នាក់ងារ USAID សម្រាប់ជំនួយម៉ាស៊ីនផលិតអុកស៊ីសែនថ្មី សម្រាប់សង្គ្រោះជីវិតនេះ ដែលនឹងជួយលើកកម្ពស់ សុខភាពថ្ងៃនេះ និងបង្កើតភាពធន់ចំពោះបញ្ហាប្រឈមនៅថ្ងៃអនាគត»។




ម៉ាស៊ីនផលិតអុកស៊ីសែន ជាម៉ាស៊ីនដែលអាចផលិតអុកស៊ីសែនចំនួន ៣០០ លីត្រក្នុងមួយនាទី (LPM) ជាមួយនឹងស្ថានីយ៍ផ្ទុកដែលមានបំពង់ស៊ីឡាំង និងតភ្ជាប់ទៅបំពង់អុកស៊ីសែនរបស់មន្ទីរពេទ្យ។

ជាលទ្ធផលគម្រោងនេះនឹងជួយ មន្ទីរពេទ្យឈប់ទិញបំពង់អុកស៊ីសែនពីអ្នកផ្គត់ផ្គង់ឯកជនបញ្ជូនបំពង់អុកស៊ីសែន របស់ខ្លួនទៅកាន់ទីតាំងឆ្ងាយៗ សម្រាប់បំពេញឡើងវិញឡើយ។

ដូច្នេះវានឹងជួយសន្សំសំចៃពេលវេលា ថវិកា និងកាត់បន្ថយការប្រឈមនឹងកង្វះអុកស៊ីសែន ដែលបង្កគ្រោះថ្នាក់ដល់ ការព្យាបាលអ្នកជំងឺ។

ក្នុងកិច្ចពិធីសម្ពោធនេះដែរ លោកស្រី ឱ វណ្ណឌីន ក៏បានលើកឡើងដែរថា ការជួយឧបត្ថម្ភសាងសង់នូវអគារ និងម៉ាស៊ីនផលិតអុកស៊ីហ្សែននេះ បានឆ្លុះបញ្ចាំងពីកិច្ចសហប្រតិបត្តិការល្អ ក្នុងការបង្កើតជាសមិទ្ធផលថ្មីមួយទៀតក្នុងវិស័យសុខាភិបាល។

លោកស្រីថា សមិទ្ធផលនេះ បានចូលរួមចំណែកកាត់បន្ថយភាពខ្វះខាតក្នុងការផ្គត់ផ្គង់អុកស៊ីហ្សែនឲ្យបានទាន់ពេលវេលា និងបានជួយដល់ការផ្តល់សេវាសុខាភិបាលជូនប្រជាពលរដ្ឋឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងល្អប្រសើរ។

លោកស្រីក៏បានផ្តល់នូវអនុសាសន៍លើបញ្ហាគន្លឹះមួយចំនួនពាក់ព័ន្ធទៅនឹងដំណើការម៉ាស៊ីនផលិតអុកស៊ីហ្សែន និងការពង្រឹងការផ្តល់សេវាសុខាភិបាលផងដែរ៕

# ក្រសួងបរិស្ថានណែនាំឱ្យសហគមន៍នីមួយៗ ត្រូវមានស្បៀងអាហារគ្រប់គ្រាន់

*អត្ថបទ៖ អមរិន្ទ ដានុត*

មន្ត្រីជាន់ខ្ពស់នៃក្រសួងបរិស្ថាន បានថ្លែងឱ្យដឹងថា ៖ «សហគមន៍យើងនីមួយៗគួរមានស្បៀងអាហារហូបគ្រប់គ្រាន់ ជីវភាពកាន់តែល្អប្រសើរ នេះជាកត្តាសំខាន់ក្នុងការពារធនធានធម្មជាតិ»។

នេះជាការលើកឡើងរបស់លោក សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន កាលពីថ្ងៃទី១៩ ខែកញ្ញា ក្នុងឱកាសចូលរួមជាអធិបតីភាពនៃការដាំស្តារព្រៃឈើ ក្លូនរុក្ខជាតិ រៀបចំថ្នាលបណ្តុះកូនឈើ និងការពិនិត្យការចិញ្ចឹមពូជសត្វក្របី នៅក្នុងដែនជម្រកសត្វព្រៃភ្នំព្រេច ស្ថិតក្នុងភូមិសាស្ត្រ ខេត្តមណ្ឌលគីរី។

លោកបានមានប្រសាសន៍ថា ៖ «វត្តមាននៅថ្ងៃនេះ ដើម្បីថ្លែងនូវការដឹងគុណ និង កោតសរសើរដល់មន្ត្រីឧទ្យានុរក្ស និងប្រជាសហគមន៍ ដែលជាទ័ពស្រួច បានលះបង់កម្លាំងកាយ-ចិត្ត ពេលវេលា ដើម្បីបុព្វហេតុការពារធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ ជូនជាតិមាតុភូមិ និងប្រជាជនកម្ពុជាគ្រប់ជំនាន់»។

ការដាំស្តារ និងក្លូនរុក្ខជាតិអាកាស្យានេះគឺជាការរួមចំណែកឆ្លើយតបទៅនឹងគោលនយោបាយគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តរភាព ដើម្បីបំពេញនូវសេចក្តីត្រូវការចំពោះមុខ បន្ថយសម្ពាធលើការប្រើប្រាស់ សម្ភារសំណង់ និងគ្រឿងសង្ហារឹមដែលធ្វើពីឈើធម្មជាតិ ព្រមទាំងបំពេញសេចក្តីត្រូវការនៅក្នុងវិស័យឧស្សាហកម្មផងដែរ។ នេះបើតាមការបញ្ជាក់ពី លោក សាយ សំអាល់។

គួរបញ្ជាក់ថា ក្រសួងបរិស្ថានបានរៀបចំផែនការដាំស្តារព្រៃឈើចាប់ពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៥ ក្នុងគោលបំណងបង្កើនគម្របដីព្រៃឲ្យបានប្រសើរឡើង និងផ្តល់ជូនមន្ត្រីឧទ្យានុរក្សនូវចំណេះដឹង បទពិសោធន៍ក្នុងការធ្វើក្លូនរុក្ខជាតិ ក៏ដូចជាបច្ចេកទេសដាំដុះ និងថែទាំចម្ការឈើដាំ ព្រមទាំងការផ្សព្វផ្សាយឲ្យបានទូលំទូលាយ ចំណេះដឹង បច្ចេកទេស និងឱកាសការងារជូនប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ។

ប្រភេទក្លូនឈើដែលដាំដុះពេលនេះជាប្រភេទឈើអាកាស្យា ចំនួន ១ម៉ឺនដើម ដាំនៅលើផ្ទៃដីទំហំ ៦,៥ ហិកតា និងបានបណ្តុះកូនអាកាស្យាទុកសម្រាប់ធ្វើពូជចំនួន ៧.០០០ ដើម និងកូនអាកាស្យាចំនួន ១៧០០០ដើម ត្រូវបានដាំរួចរាល់លើផ្ទៃដី ០៨ ហិកតា និងព្រួសពូជស្មៅចំនីសត្វលើផ្ទៃដីទំហំ ៦ ហិកតា សម្រាប់ជាចំណីរបស់សត្វក្របីចំនួន ៦០ ក្បាល ដែលទទួលបានពីក្រសួងបរិស្ថាន ក្នុងនោះបានយកទៅចិញ្ចឹមនៅស្នាក់ការកែវពៅ ចំនួន ១០ក្បាល និងនៅស្នាក់ការខ្វង់ចំនួន ៥០ ក្បាល ហើយបច្ចុប្បន្នកើនបានចំនួន២ក្បាលបន្ថែម៕





# កម្ពុជាចង់សម្រួលឱ្យពលរដ្ឋថៃ ដែលរស់នៅខេត្តជាប់ព្រំដែន មកលេងសៀមរាប-អង្គរ

*អត្ថបទ៖ អមរិន្ទ ដានុត*





គណៈកម្មការអន្តរក្រសួង ដើម្បីសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរនៅប្រកទ្វារព្រំដែនអន្តរជាតិ និងប្រកទ្វារអន្តរជាតិទូទាំងប្រទេស (គ.អ.ច.ទ.) បានលើកឡើងពីយោបល់ទាក់ទាញពលរដ្ឋថៃ ដែលរស់នៅខេត្តជាប់ព្រំដែនកម្ពុជា ឱ្យចូលមកទស្សនាខេត្តសៀមរាប ពិសេសរមណីយដ្ឋានអង្គរ។

ការលើកឡើងនូវសំណើនេះ ធ្វើឡើងក្នុងកិច្ចប្រជុំពេញអង្គរបស់គណៈកម្មការអន្តរក្រសួង គ.អ.ច.ទ. នាថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ នៅទីស្តីការក្រសួងទេសចរណ៍ ក្រោមអធិបតីភាព លោក ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធាន គ.អ.ច.ទ.។

នាឱកាសនោះ លោក ហោ សារុន រដ្ឋលេខាធិការក្រសួងទេសចរណ៍ និងជាអនុប្រធាន គ.អ.ច.ទ. បានឱ្យដឹងនាក្រោយកិច្ចប្រជុំថា រដ្ឋមន្ត្រីបានលើកឡើងអំពីយោបល់មួយ គឺសំណើស្នើទៅកាន់រាជរដ្ឋាភិបាល ដើម្បីអនុញ្ញាតឱ្យប្រជាពលរដ្ឋថៃ ដែលរស់នៅខេត្តជាប់ព្រំដែនកម្ពុជា អាចឆ្លងមកខេត្តសៀមរាបដែលជាខេត្តទី២ (បន្ទាប់ពីខេត្តទី១ដែលជាប់ព្រំដែន) ដោយគ្រាន់តែប្រើប្រាស់ត្រឹមបណ្ណព្រំដែន Border Pass (មិនចាំបាច់មានលិខិតឆ្លងដែន)។

លោកថា ឧទាហរណ៍ ពលរដ្ឋថៃដែលរស់នៅខេត្តស្រះកែវ ពេលចូលមកខេត្តបន្ទាយមានជ័យ ហើយអាចចូលមកខេត្តសៀមរាប, អ្នកនៅខេត្តសុរិន្ទពេលចូលមកខេត្តឧត្តរមានជ័យ អាចចូលមកខេត្តសៀមរាបទៀតបាន។

លោក ហោ សារុន បានថ្លែងថា ៖ ««ប្រជាពលរដ្ឋថៃខ្លះគាត់ចង់មកលេងប្រាសាទអង្គរវត្ត តែគាត់អត់មានលិខិតឆ្លងដែន ដូច្នេះបើគាត់រស់នៅខេត្តជាប់ព្រំដែន គាត់អាចស្នើសុំបណ្ណព្រំដែន នឹងអាចចូលមកទស្សនារមណីយដ្ឋានអង្គរបានដូចគ្នា»។

រដ្ឋលេខាធិការរូបនេះបានបន្តទៀតថា ប្រសិនបើការអនុវត្តយ៉ាងដូច្នេះ កម្ពុជានឹងទទួលបានផលចំណេញបន្ថែម ពីវិស័យទេសចរណ៍ តាមរយៈការចូលមកទស្សនា ដោយផ្ទាល់របស់ភ្ញៀវទេសចរ ដែលជាប្រជាពលរដ្ឋថៃរស់នៅ តាមខេត្តជាប់ព្រំដែនកម្ពុជា។

សូមជម្រាបថា ខេត្តរបស់ប្រទេសថៃ ដែលជាប់ជាមួយព្រំដែនប្រទេសកម្ពុជា រួមមាន ខេត្តឧត្តុបលរាជធានី (Ubon Ratchathani) ជាប់ជាមួយខេត្តព្រះវិហារ។ ខេត្តស្រីសាកេត (Si Sa Ket) ជាប់ជាមួយខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ។ ខេត្តសុរិន្ទ (Surin) ជាប់ជាមួយខេត្តឧត្តរមានជ័យ។ ខេត្តបុរីរម្យ (Buri Ram) ជាប់ជាមួយខេត្តឧត្តរមានជ័យ និងខេត្តបន្ទាយមានជ័យ។ ខេត្តស្រះកែវ (Sa Kaeo) ជាប់ជាមួយខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង។ ខេត្តចន្ទបុរី (Chanthaburi) ជាប់ជាមួយខេត្តបាត់ដំបង និងខេត្តប៉ៃលិន។ ខេត្តត្រាត (Trat) ជាប់ជាមួយខេត្តប៉ៃលិន បាត់ដំបង ពោធិ៍សាត់ និងខេត្តកោះកុង។

បើតាមក្រសួងទេសចរណ៍ បច្ចុប្បន្នកម្ពុជា-ថៃ កំពុងអនុវត្តការអនុញ្ញាតឱ្យមានការចេញ/ចូល រវាងប្រជាជនដែលរស់នៅជាប់ព្រំដែនទាំងសងខាង។ ប្រជាជនដែលកាន់ប័ណ្ណព្រំដែន អាចឆ្លងកាត់ព្រំដែនបានដោយមិនចាំបាច់ មានលិខិតឆ្លងដែនឡើយ។ ដើម្បីទទួលបានបណ្ណព្រំដែននេះ ប្រជាពលរដ្ឋគ្រាន់តែមានអត្តសញ្ញាណបណ្ណ គឺអាចស្នើសុំបណ្ណព្រំដែននេះបាន៕

# ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិត ឆ្នាំ២០២៣ កើនដល់ ២០០ ដុល្លារ

*អត្ថបទ៖ អមរិន្ទ ដានុត*

ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមានៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសម្រេចតម្លើងប្រាក់ឈ្នួលសម្រាប់កម្មករនិយោជិត ផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ចំនួន ២០០ ដុល្លារ ក្នុងមួយខែ សម្រាប់ឆ្នាំ២០២៣ ។

សម្តេចនាយករដ្ឋមន្ត្រី បានសម្រេចផ្តល់ប្រាក់បន្ថែមចំនួន ២ (ពីរ) ដុល្លារអាម៉េរិក លើតួលេខដើមរបស់ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ដែលមានចំនួន១៩៨ដុល្លារ ដែលធ្វើឱ្យប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០២៣ កើនឡើងដល់២០០ដុល្លារក្នុង១ខែ។




លោក អ៊ុិត សំហេង រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឱ្យដឹងថា ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ កម្មករនិយោជិត ផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប នឹងមានប្រាក់ឈ្នួល អប្បបរមាចំនួន ២០០ដុល្លារអាម៉េរិក ក្នុងមួយខែចំពោះកម្មករនិយោជិតពេញសិទ្ធិ។

លោកបានបន្ថែម ចំពោះកម្មករនិយោជិតសាកល្បង ទទួលបានប្រាក់ឈ្នួលចំនួន ១៩៨ ដុល្លារអាម៉េរិក ក្នុងមួយខែ។

លោក អ៊ុិត សំហេង បានបញ្ជាក់ថា ៖ «ទន្ទឹមនឹងនេះ ប្រាក់អត្ថប្រយោជន៍ផ្សេងទៀត ដែលកម្មករនិយោជិតធ្លាប់ទទួលបានកន្លងមក ត្រូវបានរក្សាទុកនៅដដែល មានដូចជា ប្រាក់សោហ៊ុយធ្វើដំណើរនិងស្នាក់នៅ, ប្រាក់រង្វាន់ធ្វើការទៀងទាត់, ប្រាក់ថ្លៃបាយសម្រាប់ការធ្វើការងារបន្ថែម ម៉ោងដោយស្ម័គ្រចិត្ត និង ប្រាក់រង្វាន់អតីតភាពការងារ»។

សូមបញ្ជាក់ថា ប្រាក់សោហ៊ុយធ្វើដំណើរ និងស្នាក់នៅចំនួន ៧ដុល្លារអាម៉េរិក ក្នុងមួយខែ, ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ដុល្លារអាម៉េរិក ក្នុងមួយខែ, ប្រាក់ថ្លៃបាយសម្រាប់ការធ្វើការងារបន្ថែម ម៉ោងដោយស្ម័គ្រចិត្តចំនួន ២ ០០០រៀល ក្នុងមួយថ្ងៃ ឬការទទួលបានបាយមួយពេលដោ យឥតគិតថ្លៃ និងប្រាក់រង្វាន់អតីតភាពការងារចំនួនពី ២ដុល្លារអាម៉េរិក ដល់ ១១ដុល្លារអា ម៉េរិក ក្នុងមួយខែ សម្រាប់កម្មករ និយោជិតដែលបានធ្វើការចាប់ពីឆ្នាំទី២ ដល់ឆ្នាំទី១១ ។

លោករដ្ឋមន្ត្រីបានថ្លែងថា ៖ «ជាមធ្យមកម្មករនិយោជិតម្នាក់ៗនឹងទទួល បានប្រាក់បៀវត្សយ៉ាងតិចចំនួនពី ២១៧ ដល់ ២២៨ដុល្លារអាម៉េរិក ក្នុងមួយខែ»។

លោក ប៉ាវ ស៊ីណា ប្រធានសម្ព័ន្ធសហជីពចលនាកម្មករកម្ពុជា បានប្រាប់ឱ្យដឹងថា បើទោះបីជាចំនួននេះមិនទាន់ឆ្លើយតបតាមការចង់បានរបស់កម្មករក៏ដោយតែវាជាការសម្រេចចិត្តភាគច្រើនរបស់ភាគីចរចា។ ដូចនេះ ខាងភាគីសហជីពដែលជាតំណាងកម្មករ ត្រូវទទួលយកតាមអ្វីដែលជាការសម្រេចចិត្តតាមលក្ខណៈប្រជាធិបតេយ្យតាមលក្ខណៈការបោះឆ្នោតនេះ។

លោកបានថ្លែងថា៖««យើងឃើញថា ស្ថានភាព ២ ឆ្នាំមកនេះ គឺស្ថានភាពកម្មកររបស់យើង គឺពិតជាជួបការលំបាកខ្លាំងមែនទែនផ្នែកហិរញ្ញវត្ថុរបស់ពួកគាត់ ដោយសារតែពាក់ព័ន្ធនឹងបញ្ហាកូវីដ-១៩ ហើយអ្វីដែលសំខាន់ ដូចជាឆ្នាំ ២០១៩ និងឆ្នាំ ២០២២ គឺកម្មករបានបាត់បង់ផលប្រយោជន៍ជាច្រើន ដូចជាការកាត់ថ្ងៃឈប់សម្រាក និងការលុបថ្ងៃឈប់សងជាដើម»។

លោក ប៉ាវ ស៊ីណា បានបន្ថែមទៀតថា លោករីករាយចំពោះយន្តការនេះដែលមានការចរចារាល់ឆ្នាំហើយមានផលបូកជាប្រចាំ ខណៈដែលប្រទេសផ្សេងៗមួយចំនួនទៀតមិនមានការតម្លើងសោះ។

សូមបញ្ជាក់ថា នៅឆ្នាំ ២០២១ ក្រោយក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាសម្រេចតម្លើង ១៩២ ដុល្លារ ហើយសម្តេច ហ៊ុន សែន ប្រកាសបន្ថែមទឹកប្រាក់ ២ ដុល្លារទៀត ធ្វើឱ្យប្រាក់ឈ្នួលសម្រាប់អនុវត្តក្នុងឆ្នាំ ២០២២ ឡើងដល់ ១៩៤ ដុល្លារ ក្នុង ១ ខែ៕

# កម្ពុជាទទួលបានរថយន្ត គ្រឿងចក្រគ្រប់ប្រភេទ ចំនួន ១១៧គ្រឿង និងសម្ភារៈជាច្រើនពីភាគីចិន

*អត្ថបទ៖ អមរិន្ទ ដានុត*

រថយន្ត គ្រឿងចក្រគ្រប់ប្រភេទចំនួន ១១៧គ្រឿង ព្រមទាំងសម្ភារៈមួយចំនួន ដែលជាជំនួយឥតសំណងរបស់ក្រសួងការពារប្រទេសចិន ត្រូវបានប្រគល់ជូនក្រសួងការពារជាតិកម្ពុជានាព្រឹកថ្ងៃទី២០ ខែ កញ្ញា នេះ ដែលពិធីនេះបានប្រព្រឹត្តធ្វើឡើងនៅសាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថ ស្ថិតក្នុងតំបន់ភូមិសាស្ត្រភ្នំជុំរីករាយ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។

ក្នុងពិធីប្រគល់និងទទួលសម្ភារៈទាំងនេះ មានការចូលរួមពីសម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងលោក វ៉ាង វិនធាន ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំកម្ពុជា។

ក្រសួងការពារជាតិ បានឱ្យដឹងថា សម្ភារៈគ្រឿងចក្រផ្នែកដឹកជញ្ជូន សម្រាប់បំរើឲ្យសកម្មភាពការងារធានាផ្នែកសន្តិសុខ កងកម្លាំងកងរាជអាវុធហត្ថ ដែលត្រូវបានខាងភាគីចិនប្រគល់ជូនក្រសួងការពារជាតិកម្ពុជា នោះរួមមានរថយន្ត គ្រឿងចក្រគ្រប់ប្រភេទចំនួន ១១៧គ្រឿង ព្រមទាំងសម្ភារៈមួយចំនួនធំទៀតផងដែរ។

ប្រភពដដែលបានបន្តថា ការប្រគល់នូវសម្ភារៈ និងរថយន្តទាំងនេះ ដល់ក្រសួងការពារជាតិកម្ពុជា គឺដើម្បីបម្រើដល់ការងារធានារក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ដល់ការរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន និងកិច្ចប្រជុំនានា ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ និងជាប្រធានប្តូរវេនអាស៊ានឆ្នាំ២០២២នេះ។

លោក វ៉ាង វិនធាន មានប្រសាសន៍ថា ៖ «កងទ័ពចិននិងកម្ពុជា គឺជាបងប្អូនស្គាល់ចិត្តស្គាល់ថ្លើម និងរួមសុខរួមទុក្ខជាមួយគ្នា ជាដៃគូនិយាយតិចតែធ្វើច្រើន។ ជំនួយនេះ គឺជាសកម្មភាពជាក់ស្តែង ដែលក្រសួងការពារជាតិចិន ជួយគាំទ្រដល់ក្រសួងការពារជាតិកម្ពុជា យកទៅប្រើប្រាស់សម្រួលដល់ការងារថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ក្នុងការរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការពារជាតិអាស៊ាន និងកិច្ចប្រជុំនានា ដែលពាក់ព័ន្ធ របស់ក្រសួងការពារជាតិកម្ពុជា»។

ជាមួយគ្នានោះដែរ សម្តេចពិជ័យសេនា ទៀ បាញ់ ក៏បានលើកឡើងដែរថា ស្មារតីជួយយកអាសាគ្នាក្នុងគ្រាលំបាកប្រកបដោយសុឆន្ទៈ គឺជាឧបករណ៍ដ៏មានប្រសិទ្ធភាពបំផុត ក្នុងបុព្វហេតុនៃការកសាង ថែរក្សាសន្តិភាព ស្ថិរភាព មិត្តភាពដែកថែប រឹងមាំ យូរអង្វែង និងកិច្ចសហប្រតិបត្តិការស៊ីជម្រៅ។



សម្តេចបានបន្តថា ៖ «សម្ភារៈទាំងអស់នេះពិតជាមានតម្លៃមិនអាចកាត់ថ្លៃបាន ក្នុងពេលដែលយើងកំពុងត្រូវការចាំបាច់បំផុត សម្រាប់បម្រើឱ្យការងារថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ផ្នែកយោធា ជាពិសេសក្នុងពេលដែលក្រសួងការពារជាតិកម្ពុជា កំពុងមមាញឹកក្នុងការបំពេញតួនាទីដឹកនាំ ក្នុងឋានៈជាប្រធានរាល់កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការពារជាតិអាស៊ានសម្រាប់ឆ្នាំ២០២២នេះ»។

សម្តេចពិជ័យសេនា យល់ថា សម្ភារៈដ៏មានតម្លៃទាំងនេះ នឹងត្រូវយកទៅប្រើប្រាស់នៅក្នុងកិច្ចការសំខាន់ៗជាច្រើនទៀតបម្រើឲ្យសង្គមជាតិ។

សម្តេចពិជ័យសេនា ទៀ បាញ់ និងលោក វ៉ាង វិនធាន ក៏បានធ្វើជាសក្ខីភាព នៃការចុះហត្ថលេខាផ្ទេរប្រគល់ និងទទួលជំនួយសម្ភារៈរបស់ក្រសួងការពារជាតិចិន បានផ្តល់ឲ្យដល់ក្រសួងការពារជាតិកម្ពុជា រវាងលោក សៅ សុខា អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ជាមួយលោក វរសេនីយ៍ឯកពិសេស ថ្លាំង ហាវ ប្រធានការិយាល័យអនុព័ន្ធយោធាចិនប្រចាំកម្ពុជា៕

# អាស៊ានត្រូវបានគេជំរុញឲ្យយកចិត្តទុកដាក់នៅលើការចូលរួមក្នុងការសម្រេចចិត្ត

*អត្ថបទ៖ អរិយបុត្រ*

អ្នកជំនាញខាងសារព័ត៌មានមួយរូបឲ្យសារព័ត៌មានញូវស្រ្តេតថែម (New Straits Time) គឺ លោក មូហាមេត ហ្សូលហាហ្វី ហ្សូល បាហារី (Mohammad Zulhafiy Zol Bahari ) បានសរសេរនៅក្នុងបទវិចារណកថាមួយដោយវាយតម្លៃនូវតួនាទីនិងសារៈសំខាន់របស់យុវវ័យនៅក្នុងការសម្រេចចិត្តនៅក្នុងតំបន់។

លោកបានលើកឡើងថា យុវ័យនានានៅក្នុងតំបន់អាស៊ានគួរតែយល់ឲ្យកាន់តែច្បាស់អំពីបញ្ហាដែលកំពុងប្រឈមមុខនឹងពិភពលោក ហើយថ្នាក់ដឹកនាំក៏គួរតែផ្តល់ឱកាសឲ្យយុវវ័យចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងតំបន់។

លោកបានបន្តថា អ្វីដែលត្រូវការគឺការចូលរួមពិតប្រាកដ និងការចូលរួមដែលមានអត្ថន័យពោលគឺជាឱកាសដែលអាចឲ្យយុវជនបញ្ចេញទស្សនៈ និងផ្តល់ដំណោះស្រាយ និងលើកជាសំណើនានា សម្រាប់អនាគតនៅក្នុងតំបន់របស់ពួកគេ។

លោកមូហាមេត បានបន្តថា ទាំងនេះគួរតែជាគោលដៅ ដែលអាចឱ្យយុវជនជួបជុំគ្នាតាមរយៈយន្តការថ្មីមួយ ដែលអនុញ្ញាតឱ្យពួកគេនិយាយអំពីការបង្កើតគោលនយោបាយ និងនាំមកនូវគំនិតថ្មីៗ ដើម្បីជានាថារបៀបវារៈឆ្នាំ ២០៣០ នៅក្នុងតំបន់នឹងមិនក្លាយជាឯកសារដែលគេបំភ្លេចចោលនោះទេ។

លោកក៏បានបង្ហាញនូវក្តីកង្វល់ថា ទស្សនៈនេះអាចត្រូវបានគេចាត់ទុកថា ជាបដិវត្តន៍មួយសម្រាប់អាស៊ាន ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយយុវវ័យគួរតែអាចចូលរួមបាន។

លោកមូហាមេតបានបន្តថា ប្រសិនគេអានគំនរនៃសេចក្តីប្រកាសអំពីអាស៊ាន និងយុវជននៅក្នុងតំបន់នោះគេ នឹងឃើញឯកសារយោងជាច្រើនអំពីរបៀបដែលប្លុកនេះប្តេជ្ញាចិត្តក្នុងការលើកកំពស់ការចូលរួមរបស់ យុវជន តែជាអកុសល អ្នកដឹងថាឯកសារទាំងនេះភាគច្រើនជាសេចក្តីប្រកាសដែលបានត្រឹមតែប្រកាសប៉ុណ្ណោះ។

លោកមូហាមេត បានថ្លែងថា ៖ «តាមរយៈឯកសារទាំងនេះ យើងក៏អាចល្មមនឹងយល់ពីគម្លាត និងភាពមិនស៊ីសង្វាក់គ្នាដែលមានក្នុងចំណោមអ្នកបង្កើតគោលនយោបាយអាស៊ាន»។ លោកថាជាឧទាហរណ៍ ឯកសារស្តីពីសន្ទស្សន៍អភិវឌ្ឍន៍យុវជនអាស៊ីដំបូងគេដែលបានបោះពុម្ពក្នុងឆ្នាំ ២០១៧ បានលើកឡើងនូវ យុទ្ធសាស្រ្តមួយរបស់អាស៊ានដែលផ្តោតលើ ការចូលរួមរបស់យុវជន" ហើយគេក៏អាចរកឃើញនូវប្រយោគ និងគំនិតល្អៗ អំពីរបៀបដែលអាស៊ានយកចិត្តទុកដាក់ចំពោះយុវជន។

ឯកសារនេះបង្ហាញថា ការត្រូវបានផ្តល់សិទ្ធិអំណាចឱ្យមានភាពសកម្មខាងនយោបាយ និងសង្គមអាចបង្កើនតួនាទីរបស់យុវជន ហើយសង្គមអាចទទួលបានអត្ថប្រយោជន៍ពីគំនិតច្នៃប្រឌិតថ្មីពីសម្លេងរបស់យុវជន។

លោក មូហាមេត បានបន្តថា អាស៊ានមិនខុសទេក្នុងការលើកកម្ពស់ការងារស្ម័គ្រចិត្ត និងការចូលរួមរបស់ប្រជាពលរដ្ឋ ប៉ុន្តែចំណុចសំខាន់គឺថា យើងក៏ត្រូវការវេទិកាថ្មីមួយសម្រាប់យុវជនដើម្បីចូលរួម និងផ្តល់សិទ្ធិអំណាចក្នុងន័យពិតនៃពាក្យនេះ។

ខណៈពេលដែលយើងត្រូវនិយាយអំពីបដិវត្តន៍ឧស្សាហកម្មទី ៤ ដែលជាប្រធានបទនៃកិច្ចសន្ទនាយុវជនអាស៊ានលើកទី ១ យើងត្រូវធ្វើឱ្យយុវជនមានកន្លែងដែលអាចស្តាប់សម្លេងរបស់ពួកគេបាន ខណៈពេលដែលការពិភាក្សាអំពីផលប៉ះពាល់នៃបញ្ញាសិប្បនិមិត្តនៅក្នុងសេដ្ឋកិច្ច។ ទស្សនៈនេះវាក៏មានបញ្ហាផ្សេងទៀតដែលត្រូវដោះស្រាយ ដោយចាប់ផ្តើមពីការប្រែប្រួលអាកាសធាតុ និងវិសមភាព។ នេះបើតាមការបញ្ជាក់ពីលោកមូហាមេត

បើតាមលោកមូហាមេត ការបង្កើតយន្តការថ្មីនេះនឹងមានការលំបាក និងចំណាយច្រើន ហើយនឹងត្រូវការដើមទុននយោបាយច្រើន ប៉ុន្តែនេះជាអ្វីដែលតំបន់ត្រូវការ។

លោកបានបន្ថែមថា គោលដៅចុងក្រោយ-នេះគឺជាមហិច្ឆតា ហើយមនុស្សជាច្រើនប្រហែលជាគិត នឹងនាំទៅរកការធ្វើឱ្យប្រសើរឡើងនូវវេទិកាបែបនេះនៅក្នុងវេទិកាមួយដែលការសម្រេចចិត្តពិតប្រាកដត្រូវបានធ្វើឡើងដោយយុវជន៕

# ប្រធានអាស៊ានជំរុញឲ្យសមាជិកបន្សួមគ្នាជាធ្លុងមួយលើប្រព័ន្ធពាណិជ្ជកម្មអន្តរជាតិ

*អត្ថបទ៖ អរិយបុត្រ*

ក្នុងនាមជាប្រធានអាស៊ាន សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជាបានថ្លែងថា អាស៊ានគួររួមគ្នាជាធ្លុងមួយ ដើម្បីសម្របសម្រួល និងជំរុញឱ្យមានការរៀបចំក្របខ័ណ្ឌជាសកលសម្រាប់ពាណិជ្ជកម្មអន្តរជាតិ ដែលបម្រើឱ្យផលប្រយោជន៍គ្រប់ប្រទេសទាំងអស់ ប្រកបដោយតម្លាភាព និងគ្មានការរើសអើង។

សម្តេចបានថ្លែង ក្នុងពិធីបើកកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៥៤ និងកិច្ចប្រជុំពាក់ព័ន្ធនៅសណ្ឋាគារសុខា ខេត្តសៀមរាប នាព្រឹកថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២ថា បញ្ហាសំខាន់មួយទៀតដែលអាស៊ានត្រូវគិតគូបន្ថែមទៀត គឺការឆ្លើយតបឱ្យបានទាន់ពេលវេលាទៅនឹងនិន្នាការថ្មីៗនៅក្នុងនិម្មាបនកម្មពាណិជ្ជកម្មសកល។

សម្តេចបានបញ្ជាក់ បញ្ហាថ្មីៗទាំងនេះ រួមមានវិបត្តិប្រេងឡើងថ្លៃ អត្រាអតិផរណាខ្ពស់ បរិស្ថានបម្រែបម្រួលអាកាស ធាតុជំងឺឆ្លងរាតត្បាតជាដើម កំពុងជំរុញឱ្យមាននិន្នាការឆ្ពោះទៅរកការធ្វើពាណិជ្ជកម្មក្នុង គន្លងថ្មីក្នុងតំបន់ និងក្នុងពិភពលោក។ លោកថា ក៏ប៉ុន្តែមិនមានន័យថា បញ្ហាទាំងនេះ នឹងតម្រូវឱ្យបណ្តាប្រទេសនៅក្នុងពិភពលោកប្រើប្រាស់ជាឧបករណ៍គាំពារនិយម បង្កើតជារបាំងពាណិជ្ជកម្ម និងបន្ទប់បង្អាក់ដល់ខ្សែប្រវាក់ផ្គត់ផ្គង់តំបន់ និងសកលលោក ឬ ខិតខំកសាងច្បាប់ និងកិច្ចព្រមព្រៀងអន្តរជាតិ ដែលបម្រើឱ្យតែប្រទេសខ្លួន ឬក្រុមប្រទេសមួយក្តាប់តូច ដែលជាបក្សពួកខ្លួននោះឡើយ។

សម្តេចបានបញ្ជាក់ថា ៖ «អាស៊ានគួររួមគ្នាជាធ្លុងមួយ ដើម្បីសម្របសម្រួល និងជំរុញឱ្យមានការរៀបចំក្របខ័ណ្ឌជាសកលសម្រាប់ពាណិជ្ជកម្មអន្តរជាតិ ដែលបម្រើឱ្យផលប្រយោជន៍គ្រប់ប្រទេសទាំងអស់ ប្រកបដោយតម្លាភាព និងគ្មានការរើសអើង»។

សម្តេចបានមានប្រសាសន៍ថា ៖ «អាស៊ានគួរពិចារណាលើគំនិតផ្តួចផ្តើមបង្កើត ក្របខ័ណ្ឌកិច្ចព្រមព្រៀងបៃតងអាស៊ាន (ASEAN Green Deal) ដែលអាចប្រែក្លាយខ្លួនបន្តិចម្តងៗ ឆ្ពោះទៅកាន់អនាគតបៃតងដែលមានចីរភាព ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព ភាពធន់រឹងមាំ និងភាពប្រកួតប្រជែងក្នុងផ្នែកសេដ្ឋកិច្ច»។

សម្តេចក៏បានសម្តែងនូវការជឿជាក់ថា អាស៊ាននឹងបន្តធ្វើដំណើរទៅមុខប្រកបដោយភាពរឹងមាំ សាមគ្គីភាព និងមិត្តភាព ដើម្បីជម្នះរាល់បញ្ហាប្រឈមនានា និងការកសាងសហគមន៍អាស៊ានប្រកបដោយបរិយាប័ន្នយ៉ាងពិតប្រាកដស្របតាមស្មារតីស្នូលរបស់អាស៊ានគឺ «ចក្ខុវិស័យមួយ អត្តសញ្ញាណមួយ និងសហគមន៍តែមួយ» និងឈរលើជំហរនៃការឯកភាពគ្នាសម្រាប់កិច្ចសហប្រតិបត្តិការ និងដើម្បីផលប្រយោជន៍ទៅវិញទៅមក ជាពិសេសប្រយោជន៍រួមរបស់ ប្រជាជននិងតំបន់។




នាឱកាសនោះ លោក ប៉ាន់ សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាប្រធានកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានសម្រាប់ ឆ្នាំ២០២២ បានថ្លែងថា កិច្ចប្រជុំនេះនឹងពិភាក្សាអំពីការវិវត្តន៍រីកចម្រើននៃសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន រួមទាំងសមិទ្ធិផលសេដ្ឋកិច្ចអាទិភាពរបស់កម្ពុជា។

លោកបាបន្តទៀតថា ការងើបឡើងវិញនៃសេដ្ឋកិច្ចក្រោយពីជំងឺកូវីដ-១៩ ទំនាក់ទំនងសេដ្ឋកិច្ចក្រៅតំបន់របស់អាស៊ាន ពាក្យស្នើសុំចូលជាសមាជិកអាស៊ានរបស់ប្រទេសទីម័រឡេស្តេ បញ្ហាពហុភាគីនិងតំបន់ផ្សេងៗ ការឆ្លើយតបនឹងវិបត្តិដែលកំពុងកើតមានលើសាកលលោក នាពេលបច្ចុប្បន្នបណ្តាលមកពីការប្រកួតប្រជែងឥទ្ធិពលនយោបាយ និងបញ្ហាវិបត្តិរវាងរុស្ស៊ី-អ៊ុយក្រែន ជាដើម៕

# កម្ពុជា-ឥណ្ឌា ធ្វើកម្មវិធីផ្សព្វផ្សាយទេសចរណ៍ជាមួយគ្នា ក្រោយខកខានដោយសារកូវីដ-១៩

*អត្ថបទ៖ អមរិន្ទ ដានុត*

ភាគីឥណ្ឌាមកពីរដ្ឋមធ្យ័តប្រទេស (Madhya Pradesh) ដែលជារដ្ឋធំមួយនៅភាគកណ្តាលឥណ្ឌានោះ បានរៀបចំកម្មវិធីបង្ហាញផ្លូវទេសចរណ៍ទៅកាន់រដ្ឋមធ្យ័តប្រទេស (Madhya Pradesh Roadshow) ជាមួយក្រសួងទេសចរណ៍ និងសមាគមទេសចរណ៍កម្ពុជា (CATA) ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍នឹងគ្នាឡើងវិញ។

កម្មវិធីនេះរៀបចំឡើងនារាត្រីកាលពីចុងខែសីហា កន្លងទៅនេះ នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូកេត្រា ដោយមានការចូលរួមពីលោក ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ លោកស្រី ទេវ្យានី ខូប្រាហ្គាដេ ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំកម្ពុជា លោកស្រី Sushri Usha Thakur រដ្ឋមន្ត្រីក្រសួងទេសចរណ៍និងវប្បធម៌នៃរដ្ឋមធ្យ័តប្រទេស លោកស្រី ឆាយ ស៊ីវលីន ប្រធានសមាគមទេសចរណ៍កម្ពុជា និងតំណាងក្រុមហ៊ុនទេសចរណ៍នៅកម្ពុជាជាច្រើននាក់ទៀត។

លោក Sheo Shekhar Shokla រដ្ឋលេខាធិការក្រសួងទេសចរណ៍និងវប្បធម៌ នៃរដ្ឋមធ្យ័តប្រទេស បានថ្លែងប្រាប់អ្នកសារព័ត៌មានថា ការណ៍ដែលក្រសួងទេសចរណ៍និងវប្បធម៌នៃរដ្ឋមធ្យ័តប្រទេស រៀបចំកម្មវិធីបង្ហាញផ្លូវទេសចរណ៍ទៅកាន់រដ្ឋមធ្យ័តប្រទេសនៅកម្ពុជា គឺដោយសារប្រទេសទាំងពីរមានវប្បធម៌ស្រដៀងគ្នា ដែលធ្លាប់មានទំនាក់ទំនងជាមួយគ្នារាប់ពាន់ឆ្នាំមកហើយ ហើយនេះក៏ជាឱកាសរំលឹកនូវទំនាក់ទំនងឡើងវិញដែរ។



លោកបានបន្តថា ៖ «ក្រសួងទេសចរណ៍និងវប្បធម៌ នៃរដ្ឋមធ្យ័តប្រទេស ក៏មានបំណងចង់ជំរុញកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ជាមួយកម្ពុជា ក្រោយខកខានដោយសារវិបត្តិជំងឺកូវីដ-១៩អស់រយៈពេល៣ឆ្នាំកន្លងមក ជាពិសេសជាមួយក្រសួងទេសចរណ៍ និងផ្នែកឯកជនក្នុងវិស័យទេសចរណ៍នៅកម្ពុជា»។

លោក Sheo Shekhar Shokla បានបន្ថែមថា ប្រជាជនកម្ពុជាដែលទៅដល់ប្រទេសឥណ្ឌាក៏មានឱកាសក្នុងការបង្ហាញវប្បធម៌ខ្លួនទៅកាន់ប្រទេសឥណ្ឌាផងដែរ។ នៅទីរដ្ឋមធ្យ័តប្រទេសនោះ គឺមានគោលដៅទេសចរណ៍ជាច្រើនដែលភ្ញៀវទេសចរអាចដើរទស្សនាកម្សាន្តផង និងសិក្សាស្វែងយល់ផង។

លោកក៏នឹងនាំការផ្សព្វផ្សាយទេសចរណ៍រវាងប្រទេសទាំងពីរនាឱកាសនោះជូនដំណឹងទៅដល់បណ្តាដៃគូ និងក្រុមហ៊ុនទេសចរណ៍នៅប្រទេសឥណ្ឌាដទៃទៀត ដើម្បីឱ្យកិច្ចសហប្រតិបត្តិការនេះចាប់ផ្តើមដំណើរការប្រកបដោយផ្លែផ្កា។

ចំណែកលោកស្រី ឆាយ ស៊ីវលីន បានឱ្យដឹងដែរថា តាមរយៈកម្មវិធីផ្សព្វផ្សាយពីគោលដៅទេសចរណ៍របស់ឥណ្ឌានេះ សមាគមទេសចរណ៍កម្ពុជា និងក្រុមហ៊ុនទេសចរណ៍ ទីភ្នាក់ងារទេសចរណ៍របស់កម្ពុជាបានធ្វើបច្ចុប្បន្នភាពផលិតផលទេសចរណ៍របស់ខ្លួនដែរ ដើម្បីរៀបចំលក់ជូនភ្ញៀវទេសចរដែលចង់ទៅទស្សនានៅប្រទេសឥណ្ឌា។

លោកស្រីបានបន្តថា តាមរយៈកម្មវិធីនេះ សមាគមទេសចរណ៍កម្ពុជារំពឹងថានឹងជួយជំរុញការពន្លឿនការរៀបចំឱ្យមានការហោះហើរត្រង់រវាងកម្ពុជានិងឥណ្ឌា ដើម្បីឈានទៅជំរុញចលនាទេសចរពីគ្នាទៅវិញទៅមកឱ្យបានច្រើន ខណៈបច្ចុប្បន្នភ្ញៀវទេសចរត្រូវឆ្លងកាត់ប្រទេសទី២សិន មកទៅដល់ប្រទេសឥណ្ឌា ឬមកដល់ប្រទេសកម្ពុជា។

ជាមួយគ្នានោះដែរ លោករដ្ឋមន្ត្រី ថោង ខុន ក៏បានឱ្យដឹងដែរថា កម្មវិធីបង្ហាញផ្លូវទេសចរណ៍នាពេលនេះនឹងជួយផ្សព្វផ្សាយគោលដៅទេសចរណ៍នៃប្រទេសទាំងពីរ និងជួយពង្រឹងកិច្ចសហប្រតិបត្តិការរបស់កម្ពុជា-ឥណ្ឌាឱ្យកាន់តែរឹងមាំ។

លោកបានបង្ហាញការជឿជាក់ថា ការចូលរួមរបស់សារព័ត៌មាន បណ្តាការីទេសរណ៍ ទីភ្នាក់ងារទេសចរណ៍ សណ្ឋាគារ និងភាគីពាក់ព័ន្ធទាំងអស់ក្នុងឱកាសនោះ នឹងរួមចំណែកបង្កើនការផ្សព្វផ្សាយពីគោលដៅទេសចរណ៍នៃប្រទេសទាំងពីរបន្ថែមទៀត ធ្វើឱ្យប្រជាជននៃប្រទេសទាំងពីរកាន់តែស្គាល់និងយល់ដឹងបន្ថែមទៀត ជាពិសេសការពង្រឹងការផ្លាស់ប្តូរទៅវិញទៅមករវាងប្រជាជននិងប្រជាជន ព្រមទាំងរំហូរទេសចររវាងប្រទេសទាំងពីរ។

បើតាមតំណាងភាគីឥណ្ឌា សាធារណរដ្ឋឥណ្ឌាក៏មានគម្រោងចង់ពង្រីកការហោះហើរមកកាន់កម្ពុជា ក៏ដូចជាប្រទេសជិតខាងផងដែរ។ បន្ទាប់ពីកម្មវិធីនេះ ភាគីឥណ្ឌានឹងពិភាក្សាជាមួយរដ្ឋាភិបាលរបស់ខ្លួន ដើម្បីបើកឱ្យមានការហោះហើរពីរដ្ឋមធ្យ័តប្រទេសនិងរដ្ឋមួយចំនួនទៀតនៅឥណ្ឌាមកកាន់ប្រទេសកម្ពុជា និងប្រទេសក្នុងតំបន់អាស៊ានដទៃទៀត៕

# វិស័យអាកាសចរណ៍ស៊ីវិលកម្ពុជា៖ ពពកខ្មៅនឹងរសាត់ពីកម្ពុជានៅចុងឆ្នាំក្រោយ

*អត្ថបទ៖ អរិយបុត្រ*

ពពកខ្មៅដោយសារតែកូវីដ ១៩ និង បញ្ហាសាកលដែលបានគ្របដណ្តប់លើវិស័យដឹកជញ្ជូនផ្លូវអាកាស ជាពិសេសគឺ លើវិស័យសេវាកម្មនិងទេសចរណ៍នៅកម្ពុជាប្រមាណជា ពីរឆ្នាំមកនេះ រំពឹងថា នឹងរសាត់នៅចុងឆ្នាំ២០២៣ ខាងមុខ។

លោក ស៊ិន ចាន់សិរីវុត្ថា អ្នកនាំពាក្យរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានឲ្យដឹងកាលពី ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០២២ ថា ប្រសិនបើមិនមានពពកខ្មៅថ្មីមកបាំងទេ វិស័យអាកាសចរណ៍កម្ពុជានឹងមានកំណើនឡើងវិញនៅចុងឆ្នាំក្រោយ ។

លោកបានបញ្ជាក់នៅក្នុងសន្និសីទកាសែតមួយថា «យើងរំពឹងថា ចំនួនអ្នកដំណើរតាមផ្លូវអាកាសនឹងមានការកើនឡើងនៅចុងឆ្នាំ២០២៣ ឬដើមឆ្នាំ២០០៤ បើគ្មានបញ្ហាសាកលអ្វីកើតឡើងបន្តទេនោះ»។

លោកបានបន្តថា ពីខែមករា ដល់ សីហា មានក្រុមហ៊ុនអាកាសចរណ៍ដែលបានតភ្ជាប់ផ្លូវហោះហើរមកកាន់កម្ពុជាឡើងវិញចំនួន ២៥ ក្រុមហ៊ុន ហើយតាមពិនិត្យស្ថានការណ៍ គឺអ្នកដំណើរមានការកើនឡើងជាលំដាប់ពីមួយខែទៅមួយខែ។

លោកបានបន្តថា នៅក្នុងរយៈពេល ៨ ខែ



នៃឆ្នាំ២០២២ នេះកម្ពុជាបានទទួលអ្នកដំណើរសរុប ប្រមាណជា ១,១៣ លាននាក់កើនឡើងរហូតដល់ទៅ ៦០០ ភាគរយ ធៀបនឹងរយៈពេលដដែលកាលពីឆ្នាំទៅ ប៉ុន្តែប្រសិនបើប្រៀបធៀបនឹង ឆ្នាំ២០១៩ វិញនោះ គឺធ្លាក់ចុះ ដល់ទៅ ៧៨ ភាគរយ ។

លោក ជា អូន រដ្ឋលេខាធិការប្រចាំការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល បានឲ្យដឹងនៅថ្ងៃដដែលថា នៅក្នុងចំណោមក្រុមហ៊ុនអាកាសចរណ៍ដែលហោះនោះក្រុមហ៊ុនអាកាសចរណ៍នៅក្នុងស្រុក មានចំនួន ៦ ។

លោកបានបន្តទៀតថា ដើម្បីលើកកំពស់និងជំរុញដំណើការអភិវឌ្ឍន៍ព្រលានយន្តហោះអោយសុវត្ថិភាព ដើម្បីបន្តការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជានោះ កម្ពុជាបានខិតខំបំពេញតាមស្តង់ដានៃអង្គការអាកាសចរណ៍ស៊ីវិលពិភពលោក ដោយបានធ្វើទំនើបកម្មប្រព័ន្ធសុវត្ថិភាព និង ការដាក់អោយអនុវត្តប្រព័ន្ធ និង ស្តង់ស្តាសុវត្ថិភាព ជាច្រើនដោយរួមទាំងការវិនិយោគ លើអាកាសយានដ្ឋានថ្មីៗ អោយស្របតាមបទដ្ឋានសាកលលោកផងដែរ ។

លោកបានមានប្រសាសន៍បន្តថា ក្រៅពីនោះ កម្ពុជាក៏បានយកចិត្តទុកដាក់លើការលើការបណ្តុះបណ្តាលធនធានមនុស្ស ដោយកម្ពុជាមានអាកាសយានិកទាំងអស់ ៣២ រូបហើយ នៅក្នុងនោះ ១៦ នាក់គឺជាយុវវ័យជំនាន់ក្រោយ៕

# កម្ពុជាប្រកាសបើកក្លឹបសេដ្ឋកិច្ចអាស៊ាន

*អត្ថបទ៖ អរិយបុត្រ*

ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេច ហ៊ុន សែន ក្នុងនាមជាប្រធានអាស៊ាន បានប្រកាសបើកជាផ្លូវការនូវក្លឹបសេដ្ឋកិច្ចអាស៊ាន (ASEAN Economic Club) ដែល ក្លឹបនេះ នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់សមាហរណកម្មសេដ្ឋកិច្ចអាស៊ាន ឱ្យកាន់តែជិតស្និទ្ធ តាមរយៈការចូលរួមតាមដាន វាយតម្លៃ និងផ្តល់អនុសាសន៍ ឯករាជ្យ និងប្រកបដោយវិជ្ជាជីវៈ។

ក្នុងពិធីបើកវេទិកាភាពជាអ្នកដឹកនាំ និងភាពជាដៃគូអាស៊ានឆ្នាំ២០២២ ក្រោម ប្រធានបទ«ភាពជាដៃគូសម្រាប់អាស៊ានដែលមានភាពស្អិតរមួត និងឆ្លើយតបរហ័ស» នាព្រឹកថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២ សម្តេច ហ៊ុន សែន បានលើកឡើងថា នាពេលថ្មីៗនេះ សម្តេចបានស្នើបង្កើតឡើងនូវក្របខ័ណ្ឌកិច្ចព្រមព្រៀងបៃតងអាស៊ាន (ASEAN Green Deal) ដែល អាចអនុញ្ញាតឱ្យតំបន់របស់អាស៊ានធ្វើអន្តរកាលជាបណ្តើរៗ ទៅជាសហគមន៍




ដែលមាន ចីរភាព ប្រសិទ្ធភាពប្រើប្រាស់ធនធាន និងភាពធន់។

សម្តេចក៏បាន ស្វាគមន៍នូវគំនិតផ្តួចផ្តើមរបស់វិទ្យាស្ថានយុទ្ធសាស្ត្រដើម្បីអាស៊ីប៉ាស៊ីហ្វិក និង វិទ្យាស្ថាន ចក្ខុ វិស័យអាស៊ី ក្នុងការបង្កើតឡើងនូវ តំបន់សេដ្ឋកិច្ច ឬ វិនិយោគបៃតង (Green Economic or Investment Zone) ជាមួយនឹងការដាក់ឱ្យចូលធរមាននូវច្បាប់ស្តីពីវិនិយោគថ្មី នាពេល ថ្មីៗ កន្លងទៅនេះហើយ ទន្ទឹមនេះ កម្ពុជាបានត្រៀមខ្លួនរួចជាស្រេចក្នុងការធ្វើជាម្ចាស់ផ្ទះសម្រាប់តំបន់សេដ្ឋកិច្ចបៃតងដំបូងគេបង្អស់។

សម្តេចនាយករដ្ឋមន្ត្រី ក៏បានគាំទ្រការបង្កើតឡើងនូវមូលនិធិអភិវឌ្ឍន៍ សេដ្ឋកិច្ចកម្ពុជា (Cambodia Economic Development Fund) ដែលនឹងចូលរួមចំណែក ក្នុងបរិវត្តកម្មឌីជីថល និងការអភិវឌ្ឍបញ្ញា សិប្ប និម្មិត(AI) និងបំពាក់នូវជំនាញ និងឧបករណ៍ ចាំបាច់ដល់កម្លាំងពលកម្មកម្ពុជាក្នុង សម័យបដិវត្តន៍ឧស្សាហកម្មទី ។

សម្តេចបានគូសបញ្ជាក់ថា ៖ «ក្នុងនាមជាប្រធានអាស៊ាន ក្នុងឆ្នាំ២០២២ នេះ កម្ពុជា បាន និងកំពុងចូលរួមយ៉ាង សកម្មក្នុងការពង្រីក និងពង្រឹងកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ ក្នុងគ្រប់ទម្រង់ និងគ្រប់វិស័យ ទាំងផ្នែកសង្គម-សេដ្ឋកិច្ច ពាណិជ្ជកម្ម ការវិនិយោគ និងនយោបាយ»។

សម្តេចបានបន្តថា៖ «ជាមួយប្រទេសជាមិត្តដៃគូអភិវឌ្ឍន៍ និងសហគមន៍អន្តរជាតិ ទាំងក្នុងក្របខណ្ឌប្រទេស និងតំបន់ ជាពិសេសតាមរយៈការរៀបចំវេទិកាសន្ទនាដែលមាន ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ»។

សម្តេចនាយករដ្ឋមន្ត្រីបានបន្ថែមថា កម្ពុជាចង់ឃើញតំបន់អាស៊ាន ក៏ដូចជា សកលលោក ទាំងមូល មានសុខសន្តិភាព ស្ថិរភាព និងវិបុលភាព ប្រកបដោយចីរភាព និងបរិយាបន្នយ៉ាងពិតប្រាកដ។ ជាមួយនឹងការគោរព អធិបតេយ្យភាពនៃប្រទេសនីមួយៗ ការអនុវត្តតាមច្បាប់អន្តរជាតិ ជាពិសេស ធម្មនុញ្ញអង្គការសហប្រជាជាតិ និងការប្រកាន់ខ្ជាប់ជានិច្ចនូវយន្តការ ពហុភាគីនិយម ដែលមានការចូល រួមសន្ទនាពីគ្រប់ភាគីពាក់ព័ន្ធ និងការរួមគ្នាស្វែងរក ដំណោះ ស្រាយបញ្ហាប្រឈមដោយសន្តិវិធី ជាមួយនឹងស្មារតីបើកចំហ យោគយល់ និងអត់ធ្មត់៕

# កម្ពុជាទទួលបានពានរង្វាន់ពិភពលោកចំនួន២ គឺ ទេសចរណ៍វប្បធម៌ និងទេសចរណ៍យុវជនឈានមុខគេ

*អត្ថបទ៖ អមរិន្ទ ដានុត*

កម្ពុជាទទួលបានពានរង្វាន់ពិភពលោកចំនួន២ពីស្ថាប័ន World Travel Awards ទីមួយគឺពានរង្វាន់គោលដៅវប្បធម៌ឈានមុខគេក្នុងទ្វីបអាស៊ីឆ្នាំ២០២២ (Asia's Leading Culture Destination 2022) និងទី២ពានរង្វាន់គោលដៅទេសចរណ៍យុវជនឈានមុខគេក្នុងទ្វីបអាស៊ីឆ្នាំ២០២២ (Asia's Leading Youth Travel Destination 2022)។

ក្រសួងទេសចរណ៍បានឱ្យដឹងថា មុនឈានដល់ការទទួលបានពានរង្វាន់ទាំងពីរនេះ ភ្ញៀវទេសចរប្រមាណ២លាននាក់ជុំវិញពិភពលោកបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសប្រទេសកម្ពុជាជាគោលដៅទេសចរណ៍វប្បធម៌ និងជាគោលដៅទេសចរណ៍យុវជនឈានមុខគេក្នុងទ្វីបអាស៊ីឆ្នាំ២០២២ ។








ពិធីប្រគល់ពានរង្វាន់ទាំងនេះដែរត្រូវបានធ្វើឡើងនាព្រឹត្តិការណ៍ពិព័រណ៍ទេសចរណ៍អន្តរជាតិ ITE HCMC 2022 នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម នាថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២២ ។ ឯកឧត្តម ថោង រដ្ឋសក្តិ អគ្គនាយកអភិវឌ្ឍន៍ទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិនៃក្រសួងទេសចរណ៍ ជាអ្នកឡើងទទួលពានរង្វាន់ទាំងពីរនេះក្នុងនាមតំណាងរាជរដ្ឋាភិបាលនិងប្រជាជនកម្ពុជា។

លោក ថោង រដ្ឋសក្តិ បានឱ្យដឹងថា ៖ «តាមរយៈការអនុវត្តនូវផែនការយុទ្ធសាស្ត្រស្តីពីការបើកទទួលទេសចរណ៍វ៉ាក់សាំង, វិធានការគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុងឆ្នាំ ២០២១-២០២៣, ផែនទីចង្អុលផ្លូវស្តីពីផែនការស្តារនិងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្នុងនិងក្រោយដំណាក់កាលនៃវិបត្តិជំងឺកូវីដ-១៩ ឆ្នាំ២០២០-២០២៥»។

លោកបានបន្តថា ដំណាក់កាលទី២ (Recovery) និងឈរលើយុទ្ធសាស្ត្រចាក់ស្រោចវ៉ាក់សាំង ដើម្បីទាក់ទាញភ្ញៀវទេសចរជាតិនិងអន្តរជាតិ ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានធ្វើឱ្យកម្ពុជាមានសន្ទុះចំនួនភ្ញៀវទេសចរអន្តរជាតិកើនឡើង៥៨០ភាគរយក្នុងរយៈពេល៨ខែដើមឆ្នាំ២០២២ ដែលមានចំនួនជិត១លាននាក់។

កត្តាទាំងនេះធ្វើឱ្យកម្ពុជាត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតពីអ្នកទេសចរជាង២លាននាក់ក្លាយជាម្ចាស់ពានរង្វាន់ចំនួន២ ក្រោមប្រធានបទ «គោលដៅសម្រាប់ទ្វីបអាស៊ី» ទីមួយគឺគោលដៅវប្បធម៌ឈានមុខគេក្នុងទ្វីបអាស៊ី២០២២ និងទីពីរគឺគោលដៅទេសចរណ៍យុវជនឈានមុខគេក្នុងទ្វីបអាស៊ីឆ្នាំ២០២។ ក្រៅពីកម្ពុជាក៏មានប្រទេសដទៃទៀតដែលទទួលបានពានរង្វាន់នេះដែរ ដូចជា ឥណ្ឌា ជប៉ុន ថៃ និង វៀតណាម និងប្រទេសដទៃទៀតសរុបចំនួន៣៥ប្រទេស។

លោក ថោង រដ្ឋសក្តិ បានបន្តថា អ្នកដំណើរអន្តរជាតិទាំងអស់មកទស្សនាកម្សាន្តនៅកម្ពុជាតាមរយៈការបើកឡើងវិញនូវ Visa-on-Arrival (Free Visa for ASEAN Travelers)។ ចំពោះភ្ញៀវទេសចរដែលចាក់វ៉ាក់សាំងពេញលេញអាចចូលមកតាមច្រកចេញ/ចូលប្រទេសគ្រាន់តែបង្ហាញកាត/វិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩ រីឯភ្ញៀវទេសចរមិនបានចាក់វ៉ាក់សាំងគ្រាន់តែធ្វើតេស្តរហ័សតែប៉ុណ្ណោះ។ នេះសបញ្ជាក់ឱ្យឃើញថា «កម្ពុជាជាគោលដៅទេសចរណ៍សុវត្ថិភាព ផ្តល់ភាពកក់ក្តៅ ស្អាត និងបៃតង»។

លោក ថោង រដ្ឋសក្តិ បានបង្ហាញការរំពឹងទុកថា តាមរយៈការដាក់ចេញនូវផែនទីចង្អុលផ្លូវស្តីពីផែនការស្តារនិងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុងនិងក្រោយដំណាក់កាលនៃវិបត្តិជំងឺកូវីដ-១៩ ឆ្នាំ២០២០-២០២៥, យុទ្ធនាការទស្សនាកម្ពុជាឆ្នាំ២០២៣ និងការចូលរួមព្រឹត្តិការណ៍ពិព័រណ៍ទេសចរណ៍អន្តរជាតិ ITE HCMC 2022 នឹងជួយទាក់ទាញកំណើនវិនិយោគិន និងទេសចរវៀតណាមកាន់តែច្រើនថែមទៀត ព្រោះវៀតណាមជាទីផ្សារលំដាប់ទី២របស់កម្ពុជា ដែលមាន១៨៩,៧៨២នាក់ សម្រាប់រយៈពេល៧ខែដើមឆ្នាំ២០២២ ។

សូមជម្រាបថា នេះគឺជាការប្រារព្ធខួបទី២៩ឆ្នាំរបស់ក្រុមហ៊ុនអន្តរជាតិ World Travel Awards ដែលបានប្រព្រឹត្តទៅនៅទីក្រុងហូជីមិញ ប្រទេសវៀតណាម នាថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២២ ស្របពេលព្រឹត្តិការណ៍ពិព័រណ៍ទេសចរណ៍អន្តរជាតិ ITE HCMC 2022 ក្រោមប្រធានបទ «ការរីកចម្រើនឆ្ពោះទៅមុខទាំងអស់គ្នា - Growing Forward Together»៕

# អ្នកជំនាញ លើកឡើងពីអត្ថប្រយោជន៍និងការបារម្ភពីការបំបៅកូនដោយទឹកដោះម្តាយ

*អត្ថបទ៖ អមរិន្ទ ដានុត*

ការបំបៅដោយទឹកដោះម្តាយ ជួយទ្រទ្រង់ដល់ការអភិវឌ្ឍខួរក្បាលប្រកបដោយសុខភាពល្អ និងជួយបង្កើនសមត្ថភាពខួរក្បាលខ្ពស់នៅក្នុងការធ្វើតេស្តបញ្ញា នៅក្នុងចំណោមកុមារ និងយុវវ័យនៅគ្រប់កម្រិតប្រាក់ចំណូលរបស់គ្រួសារទាំងអស់។

មានការប៉ាន់ស្មានថាការជំរុញអត្រាបំបៅកូនដោយទឹកដោះម្តាយនៅទូទាំងពិភពលោក នឹងអាចសង្គ្រោះអាយុជីវិតកុមារដែលមានអាយុក្រោមប្រាំឆ្នាំ លើសពី ៨២០.០០០ នាក់ ជារៀងរាល់ឆ្នាំ។

អង្គការយូនីសេហ្វប្រចាំកម្ពុជា បានលើកឡើងថា ខណៈដែលស្ត្រីជាម្តាយភាគច្រើននៅក្នុងប្រទេសកម្ពុជាជ្រើសរើសយកការបំបៅកូនដោយទឹកដោះខ្លួន ក៏មានការស្រាវជ្រាវមួយបង្ហាញថាប្រវ៉ាឡង់នៃការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់រហូតដល់ទារកអាយុប្រាំមួយខែដែលជាស្តង់ដារណែនាំដោយយូនីសេហ្វ និងដោយអង្គការសុខភាពពិភពលោក (WHO) មានការធ្លាក់ចុះជាលំដាប់នៅក្នុងប្រទេសនាទស្សវត្សរ៍កន្លងទៅ។

ទោះបីជាមានវឌ្ឍនភាពខ្ពស់សម្រេចបាននៅចន្លោះឆ្នាំ២០០០ និងឆ្នាំ២០១០ ដែលឃើញមានការកើនឡើងនូវតួលេខទាំងនេះក្តី។ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) ពីឆ្នាំ២០១៤ បានរកឃើញថាការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់បានធ្លាក់ចុះពីចំនួន ៧៣.៥% នៅក្នុងឆ្នាំ ២០១០ មកនៅត្រឹមចំនួន ៦៥% នៅក្នុងឆ្នាំ ២០១៤ ភាគច្រើនធ្លាក់ចុះនៅតំបន់ទីប្រជុំជន ហើយមានកុមារតែក្នុងចំនួន ៣៧% ប៉ុណ្ណោះបានទទួលនូវការបំបៅដោយទឹកដោះម្តាយនេះ បន្តរហូតដល់អាយុពីរឆ្នាំ ដូចដែលបានណែនាំដោយអង្គការ WHO។



នៅក្នុងឆ្នាំ ២០២១ តួលេខទាំងនេះបានបន្តធ្លាក់ចុះតទៀត ដោយមានកុមារត្រឹមចំនួន ៥១% ប៉ុណ្ណោះ បានទទួលនូវការបំបៅទឹកដោះម្តាយតែមួយមុខគត់ នៅក្នុងរយៈពេលប្រាំខែដំបូងនៃអាយុរបស់ពួកគេ។

ជាម្តាយរបស់កូនពីរនាក់ អ្នកស្រី កាំង វ៉ាន់ឌី អាយុ៣១ឆ្នាំ ដែលមានមុខរបរប្រចាំខ្លួនជាអ្នកលក់ចាប់ហួយផងដែរនោះបានឱ្យដឹងថា ទឹកដោះម្តាយមានសារសំខាន់ណាស់សម្រាប់កូនៗរបស់គាត់ដើម្បីចាប់ផ្តើមនូវការលូតលាស់ដ៏ល្អបំផុតក្នុងដំណាក់កាលដំបូងនៃជីវិតរបស់ពួកគេ។

អ្នកស្រីបាននិយាយថា៖ «ដំបូងទឹកដោះម្តាយ គឺជួយភ្នែក ខួរក្បាលកុមារ និងពង្រឹងប្រព័ន្ធភាពស៊ាំនឹងជំងឺ ធ្វើឲ្យសុខភាពរឹតតែល្អ ដោយការពារសរីរាង្គកាយទាំងនេះពីការវាយលុករបស់មេរោគ និងជំងឺនានា។ ហើយនៅពេលពួកគេធំឡើង ពួកគេឆ្លាត នៅក្នុងការសិក្សា និងការរស់នៅក្នុងជីវិតប្រចាំថ្ងៃ»។

ដោយអនុវត្តតាមការណែនាំរបស់មណ្ឌលសុខភាព បានខ្ជាប់ខ្ជួន រួមមានរបៀបបំបៅកូនដោយទឹកដោះម្តាយឲ្យបានត្រឹមត្រូវ ប្រកបដោយអនាម័យល្អ និងការផ្តល់អាហារបន្ថែម ក្រោយពីទារកអាយុបានប្រាំមួយខែ កូនៗរបស់អ្នកស្រី វ៉ាន់ឌី មានសុខភាពល្អ និងកម្រឈឺណាស់ បើប្រៀបធៀបនឹងកុមារដទៃដែលមានអាយុស្របាលគ្នានៅក្នុងភូមិ។

គាត់បានថ្លែងថា ៖ «ជីវិតវាលំបាកហើយក្នុងអំឡុងពេលមានជំងឺកូវីដរាតត្បាត ប៉ុន្តែយើងត្រូវតែប្រឹងប្រែងរស់ ហើយឥឡូវនេះយើងកំពុងតែខិតខំធ្វើការរកចំណូលបន្ថែមទៀត»។

លោកស្រី ទុង រដ្ឋាវី ទីប្រឹក្សាជាន់ខ្ពស់ក្រសួងសុខាភិបាល បានលើកឡើងថា ការមិនបំបៅកូនដោយទឹកដោះម្តាយធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ការអភិវឌ្ឍខួរក្បាល និងសតិស្មារតីរបស់កុមារ។ កុមារមិនទទួលបានការបំបៅដោយទឹកដោះម្តាយពេញលេញ មានទំហំខួរក្បាលតូចជាងកុមារដែលបានបៅទឹកដោះម្តាយពេញលេញ។

លោកស្រីមានប្រសាសន៍ថា ៖ «របាយការណ៍អង្កេតសុខភាពនិងប្រជាសាស្ត្រកម្ពុជាឆ្នាំ២០២២ បានបង្ហាញពីអត្រានៃការបំបៅកូនដោយទឹកដោះម្តាយតែមួយគត់នៅកម្ពុជាមាននិន្នាការបន្តធ្លាក់ចុះគួរឱ្យព្រួយបារម្ភយ៉ាងខ្លាំងពីអត្រា៦៥%នៅឆ្នាំ២០១៤មកនៅត្រឹម៥១%នៅឆ្នាំ២០២២នេះ»។

បើតាមលោកស្រី ទុង រដ្ឋាវី ការថយចុះនៃមិនទាន់មានការសិក្សាណាបញ្ជាក់ពីមូលហេតុក្នុងការធ្លាក់ចុះយ៉ាងគំហុកនៃអត្រាបំបៅដោះកូននេះនៅឡើយទេ ប៉ុន្តែលោកស្រីគិតថាមានកត្តាជាច្រើនដែលរួមចំណែក ដូចជា ស្ត្រី៧៦%ធ្វើការនៅក្នុងប្រព័ន្ធ ហើយពួកគាត់ភាគច្រើនបានបញ្ឈប់ការបំបៅដោះកូននៅពេលត្រលប់មកធ្វើការវិញ និងមានកត្តាមួយចំនួនទៀតផងដែរ។

អ្នកឯកទេសអាហារូបត្ថម្ភរបស់យូនីសេហ្វប្រចាំកម្ពុជា លោកស្រី Selamawit Negash បានថ្លែងថា ការដើរបញ្ច្រាសទៅនឹងទិន្នាការវិជ្ជមានទាំងនេះគឺធ្វើឲ្យមានការព្រួយបារម្ភជាខ្លាំង ព្រោះកុមារមានអាយុក្រោមប្រាំមួយខែ ដែលទទួលការបំបៅដោយទឹកដោះម្តាយត្រឹមមួយរយៈណានោះមានការប្រឈមកាន់តែខ្ពស់ទៅនឹងមរណភាពជាពិសេសដោយសារជំងឺរាគរូស៕

# កម្ពុជានឹងប្រើ Robots សម្រាប់ត្រួតពិនិត្យប្រព័ន្ធលូ ជាលើកដំបូង

*អត្ថបទ៖ ផល សុផានិត*

ក្រសួងសាធារណៈការ និងដឹកជញ្ជូន នឹងដាក់អោយប្រើប្រាស់នូវមនុស្សយន្ត (Robots) ដែលជាបច្ចេទេសចុងក្រោយ ដើម្បីជួយដល់មនុស្សក្នុងការថែរក្សា និងសម្អាតប្រព័ន្ធលូទឹកសម្អុយ។

ដំណឹងដ៏ល្អនេះ បានចែកចាយនៅក្នុងឱកាសដែលលោក ស៊ុន ចាន់ថុល ទេសរដ្ឋមន្ត្រី រដមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ចុះពិនិត្យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងប្រព័ន្ធលូនៅក្នុងក្រុងសៀមរាប ខេត្តសៀមរាប ដោយមានការចូលរួមថ្នាក់ដឹកនាំក្រសួងទទួលបន្ទុក និងមន្ត្រីជំនាញពាក់ព័ន្ធកាលពីម្សិលមិញ។







ការប្រើប្រាស់នូវ មនុស្សយន្ត ឬ Robotsនេះផ្អែកលើស្ថានភាពជាក់ស្តែងនៃប្រព័ន្ធលូផ្នែកខាងក្នុង ដើម្បីដោះស្រាយបញ្ហាប្រឈមអោយបានទាន់ពេលវេលា ដូចជាការស្ទះបណ្តាញលូជាដើម។

ការប្រើប្រាស់នូវមនុស្សយន្ត ឬ Robots គឺសំដៅត្រួតពិនិត្យប្រព័ន្ធលូ ដែលជាបច្ចេកវិទ្យាទំនើបមានភ្ជាប់ ជាមួយកាមេរ៉ា អាចមើលឃើញស្ថានភាពជាក់ស្តែងប្រព័ន្ធលូផ្នែខាងក្នុង ការកកស្ទះ ឬការខូចខាត ដើម្បីចាត់វិធានការដោះស្រាយបានទាន់ពេលវេលា។

ថ្លែងក្នុងបទសម្ភាសន៍ទៅកាន់ក្រុមអ្នកសារព័ត៌មាននាឱកាសនោះ លោកទេសរដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក៏បានផ្តាំផ្ញើ និងសំណូមពរឱ្យបងប្អូនប្រជាពលរដ្ឋចូលរួមថែរក្សាផ្លូវថ្នល់របស់យើងទាំងអស់គ្នា សម្អាតចិញ្ចើមផ្លូវមុខផ្ទះឱ្យបានស្អាត ទុកដាក់សំរាមឱ្យបានត្រឹមត្រូវ ពីព្រោះសំរាមជាប្រភពនាំមកនូវកកស្ទះដល់ប្រព័ន្ធលូ ជាពិសេសកុំចាក់ដីខ្ពស់ជាងផ្លូវ ដែលអាចបង្កឱ្យមានការជន់លិច ធ្វើឱ្យផ្លូវឆាប់ខូចមុនអាយុកាល និងសូមចូលរួមគោរពច្បាប់ចរាចរណ៍ឱ្យបានខ្ជាប់ខ្ជួន ដើម្បីជៀសវាងគ្រោះថ្នាក់ចរាចរណ៍៕

# ក្រសួងបរិស្ថាននិងដៃគូ គ្រោងរួមគ្នាបង្កាត់ពូជក្រពើភ្នំ

*អត្ថបទ៖ ផល សុផានិត*

ក្រសួងបរិស្ថាន និងអង្គការ WWF បានបញ្ជាក់ជំហររួមគ្នាមួយក្នុងការបង្កើនចំនួនប្រជាសាស្ត្រសត្វក្រពើភ្នំ នៅក្នុងដែនជម្រកសត្វព្រៃស្រែពកក្នុងភូមិសាស្ត្រខេត្តមណ្ឌលគិរី ឱ្យមានចំនួនកើនឡើងនៅក្នុងព្រៃធម្មជាតិ។



លោក នេត្រ ភក្ត្រា អ្នកនាំពាក្យក្រសួងបរិស្ថាន បានលើកឡើងថា តាមរយៈការសិក្សាស្រាវជ្រាវរបស់អង្គការដៃគូ គឺគេឃើញវត្តមានកូនសត្វក្រពើភ្នំ កំពុងតែរស់នៅតំបន់ មួយនេះ ពិសេសនៅតាមបណ្តោយដងទន្លេស្រែពក នៅក្នុងភូមិសាស្ត្រជម្រកសត្វព្រៃស្រែពក ក្នុងខេត្តមណ្ឌលគិរី។

សម្រាប់ការសិក្សាចាប់តាំងតែពីឆ្នាំ ២០០៥មក ឃើញមានតែស្លាកស្នាមក្នុងនេះឃើញលាមក ដានជើង ឬក៏ដានកន្ទុយ ប៉ុន្តែថ្មីៗនេះឃើញដោយផ្ទាល់នៃវត្តមានកូនសត្វក្រពើភ្នំតែម្តង។

លោកបានបន្ថែមយ៉ាងដូច្នេះថា ៖ «ពេលនេះយើងកំពុងសិក្សារួមគ្នាថា តើយើងពង្រឹងប្រព័ន្ធចំនួនប្រជាសាស្ត្រ នៅតំបន់សត្វស្រែពកយ៉ាងដូចម្តេច? ចំណុចសំខាន់ការដែលពង្រឹងវត្តមានសត្វក្រពើភ្នំ ដែលមានជាក់ស្តែងនៅកន្លែងនេះជាចំណុចអាទិភាព»។

មន្ត្រីជាន់ខ្ពស់រូបនេះ ក៏បានគូសបញ្ជាក់ថា ក្រសួងបរិស្ថានមើលឃើញពីភាពចាំបាច់ក្នុងកិច្ចការពារសត្វប្រភេទមួយចំនួនដែលជិតផុតពូជ ឬក៏ជាការគំរាមកំហែងបំផុតនៅលើពិភពលោក ក្នុងនេះដូចជាសត្វក្រពើភ្នំ ដែលសំបូរច្រើននៅក្នុងប្រទេសកម្ពុជា។

បើតាមក្រសួងបរិស្ថាន កន្លងមកក្រសួងបានទទួលជោគជ័យមកហើយ ពីការបង្កាត់ពូជក្រពើភ្នំ ហើយធ្វើការពន្លែងកូនរបស់វាចូលទៅក្នុងតំបន់ធម្មជាតិអារ៉ែង ខេត្តកោះកុង។

លោក សេង ទៀក ប្រធានអង្គការ WWF ថា អង្គការរបស់លោកនឹងសហការជាមួយក្រុមអភិរក្សដែនជម្រកស្រែកពក និងក្រសួងបរិស្ថាន ដើម្បីរៀបចំការពង្រឹងប្រជាសាស្ត្រដែលតាមការសិក្សាមានប្រមាណជាង១០ក្បាល។

លោកថា ការសិក្សាបានរកឃើញថាការបន្តពូជរបស់ក្រពើភ្នំ មានភាពយឺតយ៉ាវបន្តិច ដូច្នេះដើម្បីឱ្យមានកំណើនសត្វក្រពើភ្នំដែលជាសត្វកម្រ ហើយមានភាពទាក់ទាញផ្នែកទេសចរណ៍នឹងយកមកដាក់នៅក្នុងតំបន់ស្រែពកថែមទៀត។

លោកបានមានប្រសាសន៍ថា៖ «អញ្ចឹងខ្ញុំគិតថាលទ្ធភាពសត្វព្រៃដែលយើងជំរុញកើនចំនួននោះ គឺនៅពេលគេចូលមើលព្រៃនឹងមានការទាក់ទាញភ្ញៀវទេសខ្លាំង ហើយវាបង្កើនចំណូលដល់សហគមន៍ផង និងជាតិផង»។

គួរបញ្ជាក់ថា ប្រទេសកម្ពុជា គឺជាទីជម្រកសំខាន់ជាសកលមួយសម្រាប់ការរស់រាននៃសត្វក្រពើភ្នំដែលត្រូវបានគេប៉ាន់ប្រមាណថា មានចំនួនសរុបចន្លោះពី ២០០ ទៅ ៤០០ក្បាល កំពុងរស់នៅក្នុងទីជម្រកធម្មជាតិនានាក្នុងប្រទេស។ ចំណែកនៅលើពិភពលោកចំនួនសត្វក្រពើភ្នំ ដែលស្ថិតក្នុងវ័យអាចបន្តពូជបានមានប្រមាណមិនលើសពី ១,០០០ក្បាលឡើយ៕

# រួមគ្នាបញ្ចប់វិបត្តិអន្ទាក់ និងការជួញដូរសត្វព្រៃគ្រប់ប្រភេទ

*អត្ថបទ៖ អមរិន្ទ ដានុត*

យុទ្ធនាការអន្ទាក់សូន្យ ត្រូវបានបន្តធ្វើដំណើរទៅដល់ខេត្តរតនគីរី នាដើមខែកញ្ញា ដើម្បីបញ្ឈប់វិបត្តិអន្ទាក់ និងការបរបាញ់សត្វព្រៃគ្រប់ប្រភេទក្នុងព្រៃធម្មជាតិកម្ពុជា សំដៅអភិរក្សសត្វព្រៃកម្ពុជាឱ្យនៅគង់វង្សនិងមានចំនួនសម្បូរឡើងវិញ។






យុទ្ធនាការនេះត្រូវបានរៀបចំឡើងដោយក្រសួងបរិស្ថាន រដ្ឋបាលខេត្តរតនគីរី និងអង្គការពាក់ព័ន្ធមួយចំនួនដូចជា អង្គការទាំងនោះរួមមាន អង្គការជីវិតធម្មជាតិនៅកម្ពុជា (BirdLife in Cambodia) អង្គការអភិរក្សអន្តរជាតិ (CI) អង្គការ FFI អង្គ ការ WWF អង្គការ WEA អង្គការ ACCB និងអង្គការសន្សំម្លប់ព្រៃ។

ខេត្តរតនគីរី គឺជាខេត្តទី៦ និងចុងក្រោយគេដែលបានរៀបចំយុទ្ធនាការអន្ទាក់សូន្យនេះ មុននឹងឈាន បិទបញ្ចប់យុទ្ធនាការនៅរាជធានីភ្នំពេញក្នុងខែតុលា ខាងមុខនេះ។

លោក នេត្រ ភក្ត្រា រដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាប្រធានដឹកនាំយុទ្ធនាការអន្ទាក់សូន្យបាន ឱ្យដឹងថា យុទ្ធនាការអន្ទាក់សូន្យគឺជាកិច្ចខិតខំប្រឹងប្រែងរួមរវាងក្រសួងបរិស្ថាន អាជ្ញាធរពាក់ព័ន្ធ អង្គការដៃគូក្នុងការងារអភិរក្សនិងដៃគូអភិវឌ្ឍន៍ដើម្បីលុបបំបាត់អន្ទាក់គ្រប់ប្រភេទក្នុងតំបន់ការពារធម្មជាតិ។

លោកថា ៖ «សត្វព្រៃបានដើរតួនាទីសំខាន់ក្នុងការធានានិរន្តរភាពប្រព័ន្ធ អេកូឡូស៊ី ហើយការបាត់បង់សត្វព្រៃនិងជីវៈចម្រុះនឹងធ្វើឱ្យប៉ះពាល់ដល់លំនឹងប្រព័ន្ធអេកូឡូស៊ី។ លើសពីនេះ សត្វព្រៃជាសក្តានុពលយ៉ាងសំខាន់ ក្នុងការជំរុញទេសចរណ៍ធម្មជាតិ ដែលជាយន្តការក្នុងការអភិវឌ្ឍ សេដ្ឋកិច្ចមូលដ្ឋាន បង្កើតមុខរបរ និងបង្កើតចំណូលជូនពលរដ្ឋ»។

អភិបាលខេត្តរតនគីរីលោកញ៉ែម សំអឿន បានប្រកាសគាំទ្រយ៉ាងពេញទំហឹងចំពោះយុទ្ធនាការអន្ទាក់សូន្យ ដែលផ្តួចផ្តើមដោយក្រសួងបរិស្ថាន និងអង្គការដៃគូនានា។



លោកបានលើកឡើងដែរថា ៖ «រដ្ឋបាលខេត្តនឹងដាក់ចេញផែនការឱ្យមន្ត្រីចុះត្រួតពិនិត្យនៅតាមផ្សារទូទាំងខេត្ត ដើម្បីទប់ស្កាត់ការចរាចរណ៍លក់ដូរសាច់ព្រៃដោយខុសច្បាប់ ក្នុងមូលដ្ឋាន ក្នុងន័យធ្វើយ៉ាងចូលរួមអភិរក្សសត្វព្រៃ ឱ្យនៅគង់វង្ស»។

លោក ញ៉ែម សំអឿន បានទទូចដល់ពលរដ្ឋទាំងអស់ សូមេត្តាកុំចូលព្រៃបរបាញ់សត្វ សូមកុំបរិភោគសាច់ព្រៃ ព្រោះថាមានជំងឺជាច្រើនបានកើតឡើងដោយសារតែការបរិភោគសាច់ព្រៃជាដើម។

នាយកអង្គការ WWF កម្ពុជា លោក សេង ទៀក បានលើកឡើងដែរថា ប្រទេសកម្ពុជាបានឈានមុខគេបង្អស់នៅ ក្នុងតំបន់អាស៊ីភាគអគ្នេយ៍ លើការដោះស្រាយវិបត្តិអន្ទាក់ដែលជាមូលហេតុចម្បងនាំឲ្យសត្វព្រៃបាត់បង់ ពូជ និងមានការថយចុះចំនួនរបស់វាគួរឲ្យព្រួយបារម្ភ។

លោកបានបន្ថែមថា ៖ « បញ្ហាអន្ទាក់នេះចាំបាច់ ត្រូវដោះស្រាយព្រមគ្នាជាមួយ យុទ្ធសាស្ត្រអប់រំផ្សព្វផ្សាយ ការពង្រឹងការអនុវត្តន៍ច្បាប់ ការបង្កើនទោស ពិន័យ និងការបង្កើតជម្រើសថ្មីសម្រាប់ប្រជាជនមូលដ្ឋាន»។

«យុទ្ធនាការអន្ទាក់សូន្យ » បានចាប់ផ្តើមជាផ្លូវការនៅខែមីនា ឆ្នាំ២០២២ នៅរាជធានីភ្នំពេញ ក្រោមការ ផ្តួចផ្តើមនិងដឹកនាំរបស់ក្រសួងបរិស្ថាន និងដោយមានការគាំទ្រពីដៃគូអភិរក្សនិងដៃគូអភិវឌ្ឍន៍។ យុទ្ធនា ការអន្ទាក់សូន្យ ដែលមានរយៈពេល ៦ខែ ដោយផ្តោតលើខេត្តគោលដៅចំនួន ៦ រួមមាន៖ ខេត្តស្ទឹងត្រែង ព្រះវិហារ ក្រចេះ មណ្ឌលគិរី កំពង់ធំ និងរតនគិរី៕

# ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម មានអភិបាលជាជាតិខ្មែរដំបូង



*អត្ថបទ៖ កែវ កញ្ញា*

ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាមមានអំណរសប្បាយដោយមានលោកបូជាចារ្យជាតិខ្មែរបានក្លាយជាអភិបាលគ្រប់គ្រងក្នុងនាមសម្តេចប៉ាបសម្រាប់ភូមិភាគនេះ គឺលោកសិលា សួន ហង្សលី។

គ្រីស្តបរិស័ទមកពីគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជាបានជួបជុំគ្នាជាង១០០០នាក់ ដើម្បីចូលរួមក្នុងពិធីប្រគល់មុខងារជាផ្លូវការជូនលោកសិលា សួន ហង្សលី ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម ក្រោមអធិបតីភាពរបស់លោកអគ្គរាជទូត ប៉ូល ធិឆាង អ៊ុណាម លោកកាឌីណាល់ លូវីស ម៉ារីលីង រួមនិងអភិបាល និងបូជាចារ្យជិត១០០អង្គ កាលពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២២ នៅព្រះសហគមន៍កាតូលិកកំពង់ចាមក្រុង ក្នុងខេត្តកំពង់ចាម។

លោកអគ្គរាជទូត ប៉ូល ធិឆាង អ៊ុណាម ប្រចាំប្រទេសកម្ពុជា ថៃនិងឡាវ បានសួរពីបំណងរបស់សាមីខ្លួន ដែលនឹងបន្តមុខងារជាគង្វាលសម្រាប់ព្រះសហគមន៍នៅក្នុងភូមិភាគកំពង់ចាម ដោយមានជំនឿ សេចក្តីស្រឡាញ់ ចិត្តស្មោះត្រង់ និងសុខចិត្តស្តាប់បង្គាប់របស់សន្តអាសនៈ និងសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ។

លោកសង្កត់ធ្ងន់ទៀតថា ក្នុងមុខងារជាអភិបាលនេះ គឺជម្រុញឲ្យមានកិច្ចប្រតិបត្តិការ និងសហគ្នា ដែលណែនាំឲ្យអស់លោកបូជាចារ្យនៅក្រោមបង្គាប់ ឆ្ពោះទៅកាន់មាគ៌ានៃការសង្គ្រោះ និងជំរុញឲ្យលោកអធិដ្ឋាន ដើម្បីជាប្រយោជន៍ដល់ប្រជារាស្ត្រទាំងមូលរបស់ព្រះជាម្ចាស់ និងដល់អស់អ្នកដែលលោកនឹងជួប។

លោកសិលា សួន ហង្សលី បានឆ្លើយតបវិញថា «បាទ! ខ្ញុំយល់ឃើញដូច្នេះហើយ»។

បន្ទាប់មកលោកអគ្គរាជទូត ក្នុងនាមសម្តេចប៉ាប បានបំពាក់ចិញ្ចៀន មួក និងខ្សែកជូនលោកអភិបាលថ្មី ហើយប្រកាសជាផ្លូវការ លោកជាអភិបាលព្រះសហគមន៍កាតូលិកសម្រាប់ភូមិភាគកំពង់ចាម។

ក្រសួងប្រកាសដំណឹងល្អដល់ប្រជាជាតិទាំងឡាយក្នុងនាមសម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានចេញរាជក្រឹត្យជ្រើសតាំងលោកសិលា សួន ហង្សលី ជាអភិបាលព្រះសហគមន៍ភូមិភាគកំពង់ចាម កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២ បន្តមុខងារពីលោកអន់តូនីសាមី ស៊ូសៃរាជ្យដែលត្រូវចូលនិវត្តន៍។

ក្នុងរយៈពេលជិត៣ឆ្នាំ កន្លងមក លោកប៊្រុយណូ កូសម៍បានមើលការខុសត្រូវភូមិភាគកំពង់ចាមបណ្តោះអាសន្នក្នុងមុខងារជា Administrator of Apostolic Prefect of Kampong Cham។

«ថ្ងៃនេះខ្ញុំមានចិត្តរំភើបយ៉ាងខ្លាំង នៅក្នុងពិធីប្រគល់មុខងារ ខណៈពេលប្រកាសលិខិតតែងតាំង របស់សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ ដែលបានជ្រើសតាំងខ្ញុំដែលជាបូជាចារ្យ ជាអភិបាលក្នុងព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម» នេះជាការបញ្ជាក់របស់លោកសិលា សួន ហង្សលី ក្នុងថ្ងៃបុណ្យទទួលមុខងារ។

លោកបន្ថែមថា លោកគិតថា នេះគឺជាការអស្ចារ្យមួយដែលព្រះជាម្ចាស់បានធ្វើនៅក្នុងជីវិតរបស់លោក ទោះបីលោកជាមនុស្សទន់ខ្សោយ។

«ដោយសារការអស្ចារ្យនេះខ្ញុំសង្ឃឹមថា ព្រះជាម្ចាស់ និងប្រទានកម្លាំងកាយកម្លាំងចិត្ត និងដោយអំណោយទាននៃព្រះវិញ្ញាណដ៏ពិវិសុទ្ធ ខ្ញុំជឿថាព្រះវិញ្ញាណដ៏វិសុទ្ធនឹងជួយពង្រឹងជំនឿនិងសេចក្តីក្លាហានដល់ខ្ញុំ ដើម្បីឲ្យខ្ញុំទៅមុខ ក្នុងការណែនាំភូមិភាគកំពង់ចាម» លោកអភិបាលថ្មីបញ្ជាក់។

ព្រះសហគមន៍នៅក្នុងប្រទេសកម្ពុជា ត្រូវបានបែងចែកជា៣ភូមិភាគ ដោយសន្តអាសនៈក្នុងឆ្នាំ ១៩៦៨ ដែលមានភ្នំពេញ បាត់ដំបង និងកំពង់ចាម។ ភូមិភាគកំពង់ចាម គ្រប់ដណ្តប់ខេត្តចំនួន៨ គឺ កំពង់ចាម ត្បូងឃ្មុំ ព្រៃវែង ស្វាយរៀង ស្ទឹងត្រែង ក្រចេះ រតនគិរី និងមណ្ឌលគិរី។



លោកអភិបាលសិលា សួន ហង្សលី ប្រសូតនៅក្នុងគ្រួសារគ្រីស្តបរិស័ទ នាថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧១ ក្នុងភូមិតាស្គរ ឃុំសារិកាកែវ ស្រុកល្វាឯម ខេត្តកណ្តាល ដែលនៅតំបន់នោះមានព្រះសហគមន៍កាតូលិកមាត់ក្រសាស់ ជាទីកន្លែងកំណើតរបស់អតីតអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ លោកយ៉ូសែប ឆ្មារ សាឡាស់។

ក្នុងវ័យកុមារភាពលោករស់នៅក្នុងរបបខ្មែរក្រហម និងត្រូវបានភៀសខ្លួនទៅជំរំជំរំជនភៀសខ្លួនខ្មែរថៃ ខណៈដែលប្រទេសកម្ពុជាស្ថិតនៅក្នុងសង្គ្រាមស៊ីវិល។ លោកចាប់ផ្តើមឈ្វេងយល់ជីវិតនៃការត្រាស់ហៅ នៅជំរំ ក្នុងឆ្នាំ១៩៩១ ហើយក្នុងឆ្នាំ១៩៩២ លោកបានសុំចូលទេវវិទ្យាល័យនៅក្នុងប្រទេសកម្ពុជា។ លោកត្រូវបានតែងតាំងជាបូជាចារ្យកាតូលិកនាថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០១ ជាបូជាចារ្យសម្រាប់ភូមិភាគភ្នំពេញ។

ក្រោយមកលោកអភិបាលអេមីល ដេតម្ប អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានចាត់លោកឲ្យទៅបម្រើការងារនៅតំបន់កំពត-កែប ជាមួយលោកអូលីវីយេ ឆ្មឹតហស្លេ ដែលជាបូជាចារ្យក្នុងឆ្នាំនោះ។

លោកអភិបាលអូលីវីយេ ឆ្មឹតហស្លេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ មានប្រសាសន៍ក្នុងបទសំភាសន៍នៅថ្ងៃដដែលថា កិច្ចការងាររបស់លោកហង្សលី ដែលបានបំពេញនៅក្នុងភូមិភាគក្នុងនាមជាបូជាចារ្យភូមិភាគ ជាអ្នកទទួលខុសត្រូវមណ្ឌលសកម្មភាព ជាតំណាងពេញសិទ្ធិរបស់លោកផ្ទាល់ និងជានាយកទេវវិទ្យាល័យសន្តយ៉ូហាន ម៉ារីវីយ៉ាណែរ «អាចនិយាយបានថា ភូមិភាគភ្នំពេញ គឺជាសាលារៀនមួយសម្រាប់លោកលីដែលអាចឲ្យគាត់ចូលទៅក្នុងជីវិតថ្មី គឺចាប់ផ្តើមនៅថ្ងៃនេះ ជាអភិបាលភូមិភាគកំពង់ចាម»

លោកអភិបាលអូលីវីយេ បន្ថែមថា យើងមើលឃើញមានអំណោយទានពិសេសរបស់ព្រះជាម្ចាស់សម្រាប់ព្រះសហគមន៍នៅប្រទេសកម្ពុជា គឺនៅថ្ងៃនេះយើងមានកូនខ្មែរ ដែលទទួលខុសត្រូវនៅព្រះសហគមន៍ភូមិភាគកំពង់ចាម និងជាពេលវេលារួមគ្នាធ្វើដំណើរ នៅក្នុងព្រះសហគមន៍កាតូលិកក្នុងប្រទេសកម្ពុជានិងនៅក្នុងប្រទេសឡាវដើម្បីប្រកាសដំណឹងល្អ។

លោកស្រីគឹម ទូច អាយុ៧៨ឆ្នាំ ជាម្តាយមីងរបស់លោកអភិបាលហង្សលី មានប្រសាសន៍ថា «ត្រេកអរខ្លាំងណាស់ ដែលលោកបានឡើង ជាអភិបាល»

លោកស្រីប្រាប់ទៀតថា គាត់គ្មានអ្វីជូនលោកអភិបាលហង្សលីនោះទេ ប៉ុន្តែលោកស្រីសង្ឃឹមថា វត្តមានរបស់លោកស្រីនឹងជួយលើកទឹកចិត្តដល់លោកអភិបាលថ្មី «ឲ្យគាត់បន្តបេសកកម្មនេះរហូតទៅ កុំងាកក្រោយ កុំអាឡោះអាល័យអ្វីទៀត»

លោកបូជាចារ្យ វ៉ាំងសង់ សេន័យឆាល់ ជាប្រធានសាសនទូតក្រៅប្រទេសពីទីក្រុងប៉ារីស ប្រទេសបារាំង (MEP) និងជាបូជចារ្យដែលធ្លាប់បម្រើការងារនៅក្នុងប្រទេសកម្ពុជាមានប្រសាសន៍ថា ក្រុមអ្នកបួសរបស់លោកនៅតែបន្តជួយគាំទ្រដល់ភូមិភាគកំពង់ចាម និងព្រះសហគមន៍នៅកម្ពុជា ដោយចាត់បូជាចារ្យឲ្យមកបម្រើការងារ និងជួយឧត្ថម្ភជាថវិកា និងជំនាញសិក្សានានាសម្រាប់អ្នកបួស និងគ្រីស្តបរិស័ទមួយចំនួន។ លោកបញ្ជាក់ថា ក្រុមគ្រួសារMEP បានមកដល់ទឹកដីកម្ពុជាក្នុងឆ្នាំ១៩៥៨ ហើយទិសដៅសំខាន់របស់ក្រុមនេះ គឺចូលរួមជាមួយព្រះសហគមន៍ក្នុងស្រុក បង្កើតនិងធ្វើឲ្យព្រះសហគមន៍ក្នុងស្រុករីកចម្រើន។

លោកប្រធានMEP រូបនេះ បន្តថា នេះគឺជាលើកទីមួយដែលមានលោកអភិបាលខ្មែរក្នុងភូមិភាគកំពង់ចាម នៅក្នុងភូមិភាគភ្នំពេញធ្លាប់មានលោកឆ្មារសាឡាស់ និងបាត់ដំបងធ្លាប់មានលោកទេពអ៊ឹម។ «ថ្ងៃនេះគឺមានលោកខ្មែរទីបី គឺលោកសួនហង្សលី

*អានបន្តទំព័រ-១៣...*

# អន្តរសាសនាចូលរួមទិវាប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា

*អត្ថបទ៖ ដាលីស*

សាសនិកនៃគ្រីស្តសាសនា ពុទ្ធសាសនា និងឥស្លាមសាសនា ចំនួន១៥០០នាក់ បានចូលរួមគ្នាក្នុងទិវាអន្តរសាសនាដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្រោមប្រធានបទ «សូមកុំយកកម្ពុជា ធ្វើជាគោលដៅប្រព្រឹត្តអំពើជួញដូរមនុស្ស»។

«យើងត្រូវការការចូលរួមពីគ្រប់សាសនា ដើម្បីរួមគ្នាប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា» នេះជាការលើកឡើងរបស់លោកនាយករដ្ឋមន្ត្រីហ៊ុន សែន។ លោកបន្តថា ការជួញដូរមនុស្ស ឬឧក្រិដ្ឋកម្មដែលបានកើតឡើង មិនមែនមានតែកម្ពុជាមួយទេ តែក៏មាននៅបណ្ដាប្រទេសផ្សេងទៀតដែរ។

លោកបញ្ជាក់ថា «ការជួញដូរមនុស្សពីប្រទេសមួយទៅកាន់ប្រទេសមួយ ជារឿងអកុសលសម្រាប់ប្រជាជនក្រីក្រ ប្រសិនបើយើងមិនទប់ស្កាត់ទេ»

លោកនាយករដ្ឋមន្ត្រី បានស្នើសុំឲ្យសាសនានីមួយៗអប់រំសាសនិករបស់ខ្លួន ឲ្យយល់ដឹងអំពីវិធីបង្ការរារាំង និងប្រើប្រាស់គ្រប់តួអង្គ និងគ្រប់សកម្មភាពទាំងឡាយ ហើយធ្វើសេចក្ដីរាយការណ៍នៅពេលបានឃើញហេតុការណ៍ទាំងនោះនៅតាមមូលដ្ឋាន។

លោកបន្ថែមថា «កុំឱ្យកម្ពុជាក្លាយជាឋានសួគ៌នៃភាវរកម្ម និងការជួញដូរមនុស្ស»

អន្តរសាសនាដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ត្រូវបានធ្វើឡើង៦ឆ្នាំមកហើយ ដែលត្រូវផ្ដួចផ្ដើមដំបូងដោយអង្គការការីតាសកម្ពុជាក្នុងឆ្នាំ២០១៦ ។

លោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង អេនរីគេ ហ្វីការេដូ មានប្រសាសន៍ថា ថ្ងៃនេះការជួបជុំជាអន្តរសាសនា គឺដើម្បីរួមគ្នាប្រឆាំងនឹងការជួញដូរមនុស្សនៅក្នុងសង្គមនិងនៅក្នុងពិភពលោកបានប្រព្រឹត្តទៅប្រកបដោយភាពជោគជ័យ។




លោកអភិបាលបន្ថែមថា យើងរួមគ្នាក្នុងគ្រប់សាសនា ដើម្បីអធិដ្ឋាន លើកទឹកចិត្តគ្នានិងធ្វើការជាមួយគ្នា ក្រោមមានវត្តមានដ៏ខ្ពស់ខ្ពស់របស់សម្ដេចហ៊ុនសែន បានផ្ដល់កំលាំងឲ្យយើង ដើម្បីកសាងសង្គមដែលយើងកំពុងថែរក្សានិងការពារតាមគុណតម្លៃនៃសាសនានីមួយ។

នៅក្នុងទិវាអន្តរសាសនាដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលបានធ្វើឡើងនាថ្ងៃទី២៩ ខែកញ្ញាកន្លងទៅនេះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានកំណត់យកថ្ងៃទី 20 ខែសីហាជារៀងរាល់ឆ្នាំ ដើម្បីប្រារព្ធទិវានេះ។

លោកអភិបាលគីគេ បន្ថែមថា សាសនាទាំងអស់មានពេល៣៦៥ថ្ងៃក្នុងមួយឆ្នាំ ដើម្បីរួមគ្នារិះគិតនិងពិភាក្សាគ្នា រកវិធីការពារថែរក្សាជីវិតមនុស្ស កុំឲ្យទទួលភាពអយុត្តិធម៌តែមានជីវិតរស់នៅដោយថ្លៃថ្នូរ និងត្រូវការពារថែរក្សាសន្តិភាពកុំឲ្យមានការជួញដូរ។

សម្ដេចព្រះពុទ្ធជ័យមន្នី យឹម សន ព្រះមេគុណរាជធានីភ្នំពេញមានសង្ឃដីកាថា គ្រប់សាសនាទាំងអស់រួមជាមួយសាសនាព្រះពុទ្ធ មានតួនាទីចូលរួមជាមួយរាជរដ្ឋាភិបាលដើម្បីអប់រំ និងផ្សព្វផ្សាយទ្រឹស្ដីសាសនារបស់ខ្លួនដល់បរិស័ទឱ្យយល់ ព្រមទាំងហាមឃាត់ការជួញដូរមនុស្សព្រោះជាអំពើបាប។

ព្រះអង្គសូមចម្រើនពរដល់បរិស័ទទាំងអស់នៅកម្ពុជា ឱ្យគិតស្រឡាញ់ជីវិតទូទៅមិនមែនត្រឹមតែគ្រួសារខ្លួនឯង ហើយកុំដើម្បីផលប្រយោជន៍អ្វីមួយទៅបំពានពង្រាត់មនុស្សក្នុងគ្រួសារអ្នកដទៃ។

ព្រះមេគុណអង្គនេះ បន្ថែមថា ប្រសិនបើយើងអាចធ្វើបាន នោះសង្គមជាតិយើងនិងពិភពលោកទាំងមូលនឹងបានសេចក្ដីសុខដោយការស្រឡាញ់គ្នា និងយោគយល់គ្នា។

យោងតាមរបាយការណ៍ដែលប្រកាសដោយសម្ដេច ស ខេង ឧបនាយករដមន្ត្រី និងជាប្រធានគណៈកម្មធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស បានឱ្យដឹងថា ក្រោយពេលសភាពការណ៍កម្ពុជាបានធូរស្រាលពីកូវីដ១៩ បទល្មើសឆបោកតាមប្រព័ន្ធទូរគមនាគមន៍បានកើតមានច្រើន និងប្រើប្រាស់ដែនដីកម្ពុជាជាឧបករណ៍នៃការជួញដូរមនុស្ស។ នេះជាមូលហេតុ អាមេរិកដាក់បញ្ចូលកម្ពុជាក្នុងចំណាត់ថ្នាក់លេខ៣ ក្នុងសមាគមអាស៊ានមានវៀតណាម ម៉ាឡេស៊ី កម្ពុជា និងភូមា។

ការជួញដូរទាំងនោះមានដូចជា ប្រើប្រាស់ឧបាយកលឆបោក ដោយវិនិយោគ ដោយបង្ខំមនុស្ស ឃុំឃាំង ធ្វើទារុណកម្ម និងជំរិតទារប្រាក់ពីគ្រួសារជនរងគ្រោះ។

ក្នុងរបាយការណ៍ដដែលបានឲ្យដឹងទៀតថា ចាប់ពីថ្ងៃ១៨ ខែសីហា ឆ្នាំ២០២២ មកដល់ថ្ងៃទី២៩ ខែកញ្ញា ក្រសួងមហាផ្ទៃបានទទួលបណ្ដឹងតាមប្រព័ន្ធហ្វេសប៊ុកនិងទូរសព្ទទាន់ហេតុការណ៍ចំនួន៣៦៨ករណី។ក្នុងនេះមាន២៤៩ករណីក្នុងខេត្តព្រះសីហនុ ដោយរំដោះជនរងគ្រោះបាន៣៦១នាក់ ដោយក្នុងនោះ៥៤នាក់ជាជនរងគ្រោះដោយការជួញដូរមនុស្សក្នុង៩ករណី ដែលមានសញ្ជាតិចំនួន៦ គឺភាគច្រើនជនជាតិវៀតណាម និងចិនថៃ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងខ្មែរ។

តាមប្រសាសន៍របស់លោកឧបនាយករដ្ឋមន្ត្រី បានឱ្យដឹងថា ជនរងគ្រោះភាគច្រើនជាយុវវ័យដែលចេះបច្ចេកវិទ្យាស្ទាត់ជំនាញ។

គណៈកម្មការជួញដូរមនុស្ស បានស្រង់មតិស្រាវជ្រាវអំពីមូលហេតុនាំឱ្យមានការជួញដូរមនុស្ស ដោយរកឃើញថា ពលរដ្ឋចំនួន១០៥៣នាក់ក្នុង២០រាជធានីខេត្តមាន បន្ទុកគ្រួសារនិងបំណុល ខ្វះការយកចិត្តទុកដាក់ពីគ្រួសារនិងសង្គម ខ្វះការសិក្សាអប់រំ ខ្វះការទទួលព័ត៌មានពីរដ្ឋាភិបាល និងសង្គមស៊ីវិល លែងល្បែងស៊ីសង សេពគ្រឿងញៀន និងគ្រឿងស្រវឹង៕

---

ដែលទទួលខុសត្រូវក្នុងភូមិភាគកំពង់ចាម។ ខ្ញុំរំភើបចិត្តណាស់»

លោកសិលា សួន ហង្សលី ជាអភិបាលជាតិខ្មែរទី៣ និងជាអភិបាលជាតិខ្មែរដំបូងសម្រាប់ភូមិភាគកំពង់ចាម។ ក្នុងឆ្នាំ១៩៧៥-១៩៧៧ ព្រះសហគមន៍នៅកម្ពុជាមានលោកអភិបាលជាតិខ្មែរដំបូងគឺ លោកយ៉ូសែប ឆ្មារ សាឡាស់ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងទី២ គឺលោកប៉ូល ទេព អ៊ឹម សុត្ថា ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង។

«ខ្ញុំផ្ទាល់ខ្ញុំរំភើបណាស់ ដែលលោកលីគឺជាអភិបាលព្រះសហគមន៍យើង នៅក្នុងភូមិភាគកំពង់ចាម» នេះជាប្រសាសន៍លោកអេនរីគេ ហ្វីការេដូ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង។



លោកបន្ថែមថា លោកអភិបាលហង្សលី មានបីចំណុចដែលជាសារៈសំខាន់ គឺលោកខ្មែរ លោកមានចំណេះដឹងនិងរបៀបច្រើនដែលនាំឲ្យយើងមានរីកចម្រើនច្រើន និងតាមរយៈអំណោយទានដែលគាត់មាន នឹងនាំឲ្យព្រះសហគមន៍នៅក្នុងស្រុកខ្មែរ សេចក្ដីសង្ឃឹមនិងអំណរសប្បាយដែលមកពីព្រះជាម្ចាស់ គឺជាកម្លាំងរបស់យើង។

អ្នកស្រីអ៊ឹម រដ្ឋា មក ពីព្រះសហគមន៍បុស្សខ្នុរ ក្នុងភូមិភាគកំពង់ចាម ឲ្យដឹងថា «ខ្ញុំសង្ឃឹមថា គាត់ដឹកនាំយើងល្អជាងបូជាចារ្យបរទេស ដោយសារគាត់ជាជនជាតិខ្មែរ បើគាត់និយាយយើងស្រួលស្ដាប់ ពីព្រោះយើងនៅតាមស្រុក ហើយណាមួយយើងជាជនជាតិខ្មែរដូចគ្នា គាត់នឹងយល់ពីយើងបានច្រើន»

អ្នកស្រីថា គាត់នឹងអធិដ្ឋាន សូមព្រះជាម្ចាស់ប្រទានពរដល់លោកអភិបាលថ្មីឲ្យមានកម្លាំង ដឹកនាំឲ្យមានគ្រីស្តបរិស័ទមានជំនឿជឿលើព្រះជាម្ចាស់កាន់តែច្រើនឡើង។

លោកអភិបាលហង្សលី បានឲ្យដឹងទៀតថា «ពិតមែននៅក្នុងភូមិភាគកំពង់ចាមនេះមានគ្រីស្តបរិស័ទតិចតួច ជាងភូមិភាគដទៃទៀត ប៉ុន្តែខ្ញុំជឿថាបេសកកម្មនឹងវត្តមានរបស់ខ្ញុំក្នុងនាមជាអភិបាលនៃភូមិភាគនេះ គឺមានសារៈសំខាន់»

លោកអភិបាលថ្មី បញ្ជាក់ថា ចំណុចសំខាន់ដំបូង ដែលលោកនឹងត្រូវធ្វើគឺ ឈ្វេងយល់អំពីព្រះសហគមន៍នៅក្នុងតំបន់នីមួយៗ ទាំងបុគ្គលិក គណៈកម្មការ និងសហការជាមួយលោកបូជាចារ្យ និងអតីតអភិបាលព្រះសហគមន៍នេះ ពិនិត្យមើលអំពីចំណុចខ្វះខាតដែលគួរកែលម្អ ដើម្បីធ្វើដំណើរទៅខាងមុខក្នុងការប្រកាសដំណឹងល្អឲ្យបានរីកចម្រើន។

លោកអភិបាលហង្សលីបញ្ជាក់ទៀតថា កត្តាសំខាន់មួយទៀតគឺយើងត្រូវមានសេចក្ដីស្រឡាញ់នៅក្នុងព្រះសហគមន៍ រវាងលោកអភិបាលនិងគ្រីស្តបរិស័ទ លោកអភិបាលនិងព្រះសហគមន៍ ព្រមទាំងគណៈកម្មការបុគ្គលិកបព្វជិតបព្វជិតាទាំងអស់ ដើម្បីធ្វើជាសាក្សីអំពីជំនឿ ដែលមកពីព្រះយេស៊ូ។ «នៅពេលណាដែលយើងរស់នៅជាក្រុមមួយដែលមានលក្ខណៈល្អប្រសើរជាមួយគ្នា ដូច្នេះការប្រកាសដំណឹងល្អ នឹងមានប្រសិទ្ធភាពដែលនេះគឺជាផលផ្លែ នៃព្រះវិញ្ញាណដ៏វិសុទ្ធ» លោកអភិបាលហង្សលីបន្ថែម។

ព្រះសហគមន៍នៅក្នុងប្រទេសកម្ពុជាមានគ្រីស្តបរិស័ទប្រមាណ២ម៉ឺននាក់ ក្នុងចំណោមប្រជាជនជិត១៦លាននាក់ ដែលជាពុទ្ធបរិស័ទចំនួន៩៥%៕

# បុណ្យភ្ជុំជាពេលរំលឹកដឹងគុណបុព្វការី ឪពុកម្ដាយនៅរស់ និងអ្នកក្រីក្រ









*ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក* ក្នុងអំឡុងពេលបុណ្យភ្ជុំបិណ្ឌ គ្រីស្តបរិស័ទបាននាំយកម្ហូបអាហារមកព្រះវិហារ ដើម្បីចូលរួមក្នុងពិធីបុណ្យរំលឹកដល់មរណបុគ្គលដែលបានចែកឋានទៅហើយ។ ពិធីបុណ្យនេះត្រូវបានធ្វើឡើងកាលពីថ្ងៃទី២៤-២៦ ខែកញ្ញា។

តាមឯកសារអំពីប្រវត្តិសាស្ត្ររបស់ព្រះសហគមន៍ដែលចងក្រងដោយលោកបូជាចារ្យហ្វ្រង់ស្វ័រ ប៉ុងសូដ៏ នៃក្រុមសាសនទូតក្រៅប្រទេសនៃទីក្រុងប៉ារីស (MEP) បានឲ្យដឹងថា ក្នុងឆ្នាំ១៩៧០ បុរីវ៉ាទីកង់បានអនុញ្ញាតឲ្យគ្រីស្តបរិស័ទនៅកម្ពុជាអាចប្រារព្ធពិធីរំលឹកដល់មរណបុគ្គលនៅក្នុងថ្ងៃបុណ្យភ្ជុំបិណ្ឌជាមួយប្រជាជនក្នុងប្រទេស។

បុណ្យភ្ជុំបិណ្ឌត្រូវបានប្រជាជនខ្មែរប្រារព្ធឡើងជាយូរមកហើយ ដោយធ្វើឡើងតាមបែបប្រពៃណីពុទ្ធសាសនា ដោយមានរយៈពេល១៥ថ្ងៃ ក្នុងនោះមាន១៤ថ្ងៃជាថ្ងៃដាក់បិណ្ឌ និងកាន់វេន ហើយថ្ងៃទី១៥ គឺជាថ្ងៃបុណ្យភ្ជុំ។

ក្នុងរយៈពេលនោះ ប្រជាពលរដ្ឋខ្មែរ ទាំងចាស់ក្មេងបានទៅវត្តជាប្រចាំ ដោយមានទាំងចង្ហាន់និងបាយបិណ្ឌតាមវេននៃគ្រួសាររៀងៗខ្លួនយកទៅប្រគេនព្រះសង្ឃនៅវត្ត។ ប៉ុន្តែនៅថ្ងៃភ្ជុំ ប្រជាជនបានប្រមូលផ្តុំកូនចៅនិងគ្នីគ្នាទៅវត្តអារាម ធ្វើពិធីធំមួយ ឧទ្ទិសកុសលដល់អ្នកស្លាប់។

តាមសង្ឃដីកា របស់ព្រះភិក្ខុ វី សុវិជ្ជា ព្រះសកលវិទ្យាធិការ ពុទ្ធិកសកលវិទ្យាល័យព្រះសីហនុរាជ សាខាខេត្តបាត់ដំបង ឲ្យដឹងថាពីបិណ្ឌទី១ដល់បិណ្ឌទី១៤ គឺជាការកាន់វេន។ ហើយសម្រាប់ថ្ងៃទី១៥ គឺបុណ្យភ្ជុំ ដែលភ្ជុំនេះមានន័យថា ប្រជុំ គឺជាការប្រមូលផ្តុំសាច់ញាតិ។ «ជាឱកាសពិសេស ដែលមនុស្សម្នាក់ៗបានឲ្យតម្លៃនៃការជួបជុំ (គឺ)សំខាន់ណាស់ ព្រោះជាការសម្តែងនូវការដឹងគុណ និងការជួបជុំជាស្មារតីនៃសាមគ្គីភាព បង្ហាញសេចក្តីស្រលាញ់ដល់មនុស្សរស់ ហើយអាចមានឱកាសដើម្បីបំពេញបុណ្យកុសលជាមួយព្រះសង្ឃ មាតាបិតា សាច់ញាតិយើង ជាមួយអ្នកក្រីក្រផ្សេងៗទៀត»

ព្រះតេជគុណបន្ថែមថា ពិធីបុណ្យនេះ គឺបង្ហាញនូវកតញ្ញូតាធម៌សម្រាប់បុព្វការីជនដែលបានចែកឋានទៅហើយ ជាការឧទ្ទិសកុសលសម្រាប់ពួកលោកផង និងជាការសម្តែងការគោរពនិងដឹងគុណចំពោះអ្វីៗដែលជាការលះបង់របស់ដូនតាផង។ ម្យ៉ាងវិញទៀតជាឱកាសបានជួបជុំសាច់សាលោហិតដែរ។

«ភ្ជុំ ម៉ែពុកចង់ឲ្យកូនៗទៅជុំជាមួយពួកគាត់។ ពេលខ្លះខ្ញុំអត់ចង់ទៅ ព្រោះអត់មានលុយមានកាក់អី ប៉ុន្តែឲ្យតែដល់ថ្ងៃហ្នឹងចង់ទៅជួបជុំជាមួយគាត់» នេះជាសម្តីរបស់អ្នកស្រី ហៀម សុកខុន ជាគ្រីស្តបរិស័ទនៅព្រះសហគមន៍កំពង់គោ ក្នុងខេត្តកំពង់ធំ។

សព្វថ្ងៃសុកខុនធ្វើការងារនៅស្ថាប័នមួយរបស់ព្រះសហគមន៍កាតូលិកនៅក្នុងទីក្រុងភ្នំពេញ ដែលមានចំងាយជិត២០០គីឡូម៉ែត្រពីស្រុកកំណើត។

គ្រីស្តបរិស័ទរូបនេះ បានបន្ថែមថា ការទៅព្រះវិហារចាំបាច់ណាស់សម្រាប់ថ្ងៃបុណ្យភ្ជុំចំពោះរូបគាត់ «ដល់ថ្ងៃហ្នឹងត្រូវតែទៅ ដូចមានអារម្មណ៍មួយថា មានជីដូនជីតានៅវិហារហ្នឹង ព្រោះគាត់ជាគ្រីស្តបរិស័ទ ដូចពួកគាត់នៅមុខៗយើងក្នុងវិហារអីចឹង។ យើងអធិដ្ឋានសម្រាប់គាត់ ហើយឲ្យគាត់អធិដ្ឋានសម្រាប់យើងវិញដែរ»

នៅតាមព្រះសហគមន៍កាតូលិកនៅក្នុងប្រទេសកម្ពុជា ពិធីបុណ្យនេះបានធ្វើនៅគ្រប់ទីកន្លែងជាពិសេសគឺនៅថ្ងៃបុណ្យភ្ជុំ។

លោកបូជាចារ្យ ជីអូវ៉ាន់នី មានប្រសាសន៍នៅក្នុងធម្មទេសនានាថ្ងៃទី២៥ ខែកញ្ញា នៅព្រះសហគមន៍សន្តយ៉ូសែប ជុំគិរី នៃខេត្តកំពត ដូច្នេះថា ពិធីបុណ្យភ្ជុំបិណ្ឌជាពិធីបុណ្យប្រពៃណីខ្មែរ ប៉ុន្តែដោយឡែកព្រះសហគមន៍កាតូលិករបស់យើងក៏បានថ្វាយអភិបូជា ដើម្បីរួមគ្នាអធិដ្ឋាននិងរំលឹកដល់វិញ្ញាណក្ខន្ធដែលបានស្លាប់ទៅ ព្រោះនៅក្នុងព្រះសហគមន៍កាតូលិកក៏មានពិធីបុណ្យមួយដែលហៅថា បុណ្យរំលឹកដល់មរណបុគ្គលផងដែរ។

តាមប្រតិទិនរបស់ព្រះសហគមន៍កាតូលិកសកល ថ្ងៃប្រារព្ធបុណ្យរំលឹកដល់មរណបុគ្គលគឺនៅថ្ងៃទី២ ខែវិច្ឆិកាជារៀងរាល់ឆ្នាំ។

នៅព្រះវិហារសន្តយ៉ូសែបជុំគិរី ដែលមានចំងាយប្រមាណ១១០គីឡូម៉ែត្រពីរាជធានីភ្នំពេញ បានរៀបចំពិធីបុណ្យរំលឹកមរណបុគ្គលនេះ ដោយមានពុទ្ធបរិស័ទនៅក្នុងតំបន់ចូលរួមផងដែរ។

ពាក់អាវសជាមួយនិងខោពណ៌ទឹកប៊ិច ដៃកាន់ចានស្រាក់ មានអាយុ ២៧ឆ្នាំជាពុទ្ធបរិស័ទ លោកឡុង ចាន់ដារ៉ា មកចូលរួមថ្វាយអភិបូជាជាមួយបងប្អូនគ្រីស្តបរិស័ទ បាននិយាយថា ទោះបីជាលោកមិនមែនជាគ្រីស្តបរិស័ទ ប៉ុន្តែលោកជឿថាការធ្វើបុណ្យគឺត្រូវធ្វើដោយចិត្តនិងសទ្ធា ហើយកុសលនេះ នឹងទៅដល់អ្នកស្លាប់ដូចគ្នា។

ក្នុងពិធីនេះ លោកដារ៉ាបានយកបាយសម្លមកចូលរួមជាមួយគ្រីស្តបរិស័ទ ដោយចង់ដឹងថា ការប្រារព្ធបុណ្យភ្ជុំរបស់គ្រីស្តសាសនាមានលក្ខណៈបែបណា។

លោកបន្ថែមថា «ខ្ញុំមានអារម្មណ៍ថា ប្លែកម្យ៉ាងហើយគិតថាបងប្អូនគ្រីស្តបរិស័ទមានចិត្តស្រលាញ់និងយកចិត្តទុកដាក់ជាមួយមនុស្សជុំវិញខ្លួនជាពិសេសគឺការចែកទានដល់លោកតាលោកយាយចាស់ជរាហើយមានការហូបអាហារជុំគ្នាទៀត ធ្វើអោយខ្ញុំមានអារម្មណ៍ថាកក់ក្តៅ»។

ទន្ទឹមនឹងនោះអ្នកស្រី សយ នី ជាគ្រីស្តបរិស័ទនិយាយថា ការចូលរួមរបស់បងប្អូនពុទ្ធបរិស័ទបានបង្ហាញអោយឃើញថា ព្រះសហគមន៍កំពុងតែប្រកាសដំណឹងល្អទៅកាន់បងប្អូនដែលមិនទាន់ស្គាល់ព្រះជាម្ចាស់ ជារបៀបមួយដែលបង្ហាញពីអន្តរសាសនា។

ស្ត្រីវ័យ៤៥ឆ្នាំរូបនេះបានបន្តថា សូមអោយអ្វីៗដែលមាននៅក្នុងថ្ងៃនេះ ក្លាយជារបៀបមួយ

*អានបន្តទំព័រ-១៥...*

# លោកអភិបាល សួន ហង្សលី ឲ្យបព្វជិតាថ្មី នាំវត្តមានព្រះជាម្ចាស់ដល់អ្នកដទៃ

*អត្ថបទ៖ កែវ កញ្ញា*

«ព្រះជាម្ចាស់កែច្នៃជីវិតរបស់យើងឲ្យទៅជាជីវិតមួយដែលមានប្រយោជន៍។» នេះជាប្រសាសន៍លើកឡើងរបស់លោកអភិបាលសិលា សួន ហង្សលី អភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម ទៅកាន់យុវតីពីររូបដែលក្លាយជាបព្វជិតានាថ្ងៃទី១៤ខែកញ្ញានេះ។

«សូមឲ្យបងស្រីធ្វើជាថូមួយដែលមានសោភ័ណ្ឌភាព ដែលមកពីស្នាព្រះហស្តរបស់ព្រះជាម្ចាស់ ដែលណែនាំឲ្យមនុស្សលោកដែលឃើញជីវិតរបស់យើង ឃើញអ្វីៗដែលយើងប្រព្រឹត្ត គេគិតអំពីអ្នកដែលបានបង្កើត។» លោកអភិបាលលីបញ្ជាក់។

លោកអភិបាលបានពន្យល់ថា ដីឥដ្ឋមិនសូវមានតម្លៃទេ ប៉ុន្តែនៅពេលជាងស្មូនបានរៀបចំថូមួយដ៏ស្អាតចេញពីវា ថូនោះទៅជារបស់មានតម្លៃ។

យុវនារីទាំងពីររូបដែលថ្វាយពាក្យសច្ចា មានក្លារ៉ា ដួត ស្រីឡៃ និងក្លារ៉ា យាន កញ្ញា ដែលអ្នកទាំងពីរមកពីគ្រួសារពុទ្ធបរិស័ទ នៅកោះរការក្រៅ ក្នុងខេត្តកំពង់ចាម។ អ្នកទាំងពីរបានចូលសិក្សាអប់រំក្នុងក្រុមគ្រួសារបព្វជិតា អ្នកស្រឡាញ់ព្រះឈើឆ្កាង នៅក្នុងភូមិភាគកំពង់ចាម។

ព្រះសហគមន៍ភូមិភាគកំពង់ចាម គ្របដណ្ដប់ខេត្តចំនួន៨រួមមាន កំពង់ចាម ត្បូងឃ្មុំ ព្រៃវែង ស្វាយរៀង ក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី។

លោកអភិបាលហង្សលី មានប្រសាសន៍ទៀតថា ការឆ្លើយតបនឹងការត្រាស់ហៅគឺមានការលំបាកជាច្រើនដោយមានសន្យាចំនួនបី គឺរស់នៅលីវ រស់នៅបែបក្រីក្រ និងស្តាប់បង្គាប់ប្រធានក្រុមគ្រួសារអ្នកបួស។

លោកបានពន្យល់ថា ពាក្យសច្ចានេះ ជាសន្យាមួយដ៏លំបាកក្នុងសម័យដែលយើងរស់នៅក្នុងសង្គមជឿនលឿន ដែលមនុស្សលោកបច្ចុប្បន្នមានការប្រកួតប្រជែងគ្នា គេចង់បានទ្រព្យសម្បត្តិច្រើន ចង់មានកិត្តិយស ចង់មានគ្រួសារមួយដ៏ថ្កុំថ្កើងក្នុងសង្គម។




លោកអភិបាលបន្តថា ការថ្វាយខ្លួនគឺថ្វាយទាំងភាពទន់ខ្សោយ ហើយក៏ត្រូវការការបន្ទាបខ្លួនរស់នៅក្នុងជីវិតសាមញ្ញដូចព្រះយេស៊ូ។ ការបន្ទាបខ្លួននាំឲ្យអ្នកដទៃចង់ស្គាល់ព្រះជាម្ចាស់ផងដែរ ហើយការបន្ទាបខ្លួន នាំឲ្យព្រះជាម្ចាស់លើកយើងឡើង ដើម្បីបំពេញបេសកកម្មពិសេសរបស់ព្រះអង្គដល់មនុស្សលោកដែលយើងជួបជារៀងរាល់ថ្ងៃ។

លោកអភិបាលក៏បានជំរុញនិងលើកទឹកចិត្តដល់គ្រីស្តបរិស័ទដែលមានវត្តមានជាង២០០នាក់ក្នុងពិធី ឲ្យរស់នៅដោយបង្ហាញវត្តមានព្រះជាម្ចាស់ ដើម្បីឲ្យគេបានឃើញ និងស្វែងរកព្រះជាម្ចាស់ ឲ្យគេអាចទៅចួបព្រះអង្គតាមរយៈសកម្មភាពរបស់គ្រីស្តបរិស័ទ។

ពិធីថ្វាយពាក្យសច្ចាប្រណិធានលើកដំបូងនេះ បានធ្វើឡើងនៅក្នុងព្រះសហគមន៍កាតូលិកកំពង់ចាមក្រុង ស្ថិតក្នុងបុណ្យលើកតម្កើងព្រះឈើឆ្កាង។ បេក្ខជនទាំងពីរបានលុតជង្គង់នៅមុខអាសនៈទល់មុខប្រធានក្រុមគ្រួសារអ្នកបួស ហើយបានសន្យាស្ម័គ្រស្តាប់បង្គាប់និងធ្វើតាមពេញមួយជីវិត។

ក្រុមគ្រួសារបព្វជិតាអ្នកស្រឡាញ់ឈើឆ្កាងព្រះយេស៊ូ បង្កើតឡើងដោយលោកអភិបាលសិលា ម៉ារី ឡាំប៊ែរ ដឺឡាមុត ជាសាសនទូតជាតិបារាំងក្នុងឆ្នាំ១៦៧០ នៅតុងកឹនប្រទេសវៀតណាម ហើយក្រោយមកនៅក្នុងទឹកដីកូសាំងស៊ីននិងតំបន់អាស៊ីអាគ្នេយ៍មួយចំនួនទៀត។

បច្ចុប្បន្នក្រុមបព្វជិតានេះ មានសមាជិក៨នាក់រួមទាំងសមាជិកថ្មីដែលទើបថ្វាយពាក្យសច្ចាប្រណិធាន។

ដូនជីអាង សង្វាត ជាប្រធានក្រុមគ្រួសារបព្វជិតាអ្នកស្រឡាញ់ឈើឆ្កាងព្រះយេស៊ូនៅប្រទេសកម្ពុជា មានប្រសាសន៍ថា ដូនជីថ្មីទាំងពីររូប ត្រូវរៀនបន្ថែមទៀត គឺរៀនអំពីកិច្ចការបម្រើព្រះសហគមន៍ រៀនបម្រើអ្នកក្រីក្រ និងរៀនរស់នៅជាមួយបងស្រីដែលជាសមាជិកក្រុមគ្រួសារនេះ។

ដូនជីប្រធានបានសង្កត់ធ្ងន់ថា «ទាំងនេះ គឺជាអ្វីដែលពួកគេត្រូវរៀបចំខ្លួនដោយខ្លួនឯង។ អត់ដឹងថា ជីវិតនៅខាងក្រៅជួបបញ្ហាអី ជួបឧបសគ្គអី តែបងស្រីសូមលើកទឹកចិត្តគេ ឲ្យបន្តជីវិតនេះទៅមុខទៀត ប៉ុន្តែកត្តាសំខាន់គឺលើសាមីខ្លួននិងព្រះជាម្ចាស់។»

ក្រុមគ្រួសារបព្វជិតានេះ មានទិសដៅសំខាន់គឺប្រកាសដំណឹងល្អដល់អ្នកដទៃឲ្យស្គាល់ព្រះជាម្ចាស់ តាមរយៈការងារអប់រំទាំងជំនឿនិងចំណេះដឹងទូទៅនៅក្នុងព្រះសហគមន៍ ការរស់នៅជីវិតជាអ្នកបួស និងកិច្ចការងារសហការផ្សេងៗជាមួយលោកបូជាចារ្យតាមតំបន់ដែលសមាជិករស់នៅ។

ដូនជីក្លារ៉ា យាន កញ្ញា ដែលទើបនឹងថ្វាយសច្ចាដំបូង បានប្រាប់ថា ដំណើរនៃជីវិតអ្នកបួសរបស់គាត់ មានឧបសគ្គធំបំផុតមួយ គឺមើលថែរក្សាយាយតាជរា។

ប៉ុន្តែដោយសេចក្តីស្រឡាញ់ចំពោះជីវិតជាអ្នកបួស ការអធិដ្ឋានផ្ទាល់ខ្លួន និងគ្រីស្តបរិស័ទ «នាំឲ្យខ្ញុំមានកំលាំងអាចបន្តទៅមុខបាន។» ដូនជីដែលជាកូនកំព្រាឪពុកម្តាយតាំងពីកុមារភាពរូបនេះបន្ថែមថា គាត់បានត្រៀមខ្លួនរួចជាស្រេចដើម្បីបម្រើព្រះជាម្ចាស់ដោយសេចក្តីស្រឡាញ់ និងអស់ពីសមត្ថភាព។

រីឯដូនជីក្លារ៉ា ដួត ស្រីឡៃ ជាដូនជីថ្មីដែរនោះ បានឲ្យដឹងដែរថា ថ្ងៃនេះ គាត់មានអំណរសប្បាយយ៉ាងខ្លាំងដែលក្តីស្រមៃចង់ក្លាយជាអ្នកបម្រើព្រះសហគមន៍ក្នុងឋានៈជាអ្នកបួសជាអ្នកក្រីក្រ អ្នកស្តាប់បង្គាប់ និងរស់នៅជាព្រហ្មចារី បានកើតជារូបរាង។

ដូនជីស្រីឡៃបន្ថែមថា «ខ្ញុំនឹងត្រៀមខ្លួនត្រៀមចិត្ត គំនិត ដើម្បីចូលរួមបំពេញបេសកកម្មរបស់ព្រះយេស៊ូ ដើរតាមគំរូរបស់ព្រះអង្គ គឺមានតែការលះបង់ និងការថ្វាយជីវិតទៅព្រះអង្គ។»

អ្នកស្រីអ៊ាង ម៉ាច អាយុ៥៨ឆ្នាំ ជាពុទ្ធបរិស័ទ និងជាម្តាយរបស់ដូនជីដួតស្រីឡៃ និយាយថា កាលពីដំបូង អ្នកស្រីក៏ធ្លាប់ឃាត់កូនរបស់គាត់មិនឲ្យចូលបួស ប៉ុន្តែដោយចិត្តស្រឡាញ់របស់កូន អ្នកស្រីក៏យល់ព្រម ព្រោះដឹងថា ជីវិតអ្នកបួសគឺជាផ្លូវល្អមួយ៕

---

> ជាឱកាសពិសេស ដែលមនុស្សម្នាក់ៗបានឲ្យតម្លៃនៃការជួបជុំ (គឺ)សំខាន់ណាស់ ព្រោះជាការសម្តែងនូវការដឹងគុណ និងការជួបជុំជាស្មារតីនៃសាមគ្គីភាព បង្ហាញសេចក្តីស្រលាញ់ដល់មនុស្សរស់ ហើយអាចមានឱកាសដើម្បីបំពេញបុណ្យកុសលជាមួយព្រះសង្ឃ មាតាបិតា សាច់ញាតិយើង ជាមួយអ្នកក្រីក្រផ្សេងៗទៀត





ដែលបង្ហាញពីសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ បង្ហាញពីធម៌មេត្តាករុណាដែលគាប់ព្រះហឫទ័យរបស់ទ្រង់ ហើយសូមអោយកិច្ចការដែលគ្រីស្តបរិស័ទម្នាក់ៗបានប្រព្រឹត្តក្លាយទៅជាផ្លូវតែមួយ ទៅជាគំរូល្អដល់អ្នកជំនាន់ក្រោយ។

ក្នុងធម្មទេសនានៅព្រះសហគមន៍ត្រែងត្រយឹង នាថ្ងៃទី២៤ ខែកញ្ញា លោកអភិបាលអូលីវីយេ ឆ្មិតហាស្លេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញមានប្រសាសន៍ថា ថ្ងៃនេះ យើងអធិដ្ឋានសម្រាប់បងប្អូនដែលស្លាប់ សូមព្រះអង្គថែរក្សានិងលើកលែងទោសឲ្យពួកគាត់ ដើម្បីឱ្យគេជម្រះចិត្តគំនិតរបស់គេម្តងទៀតរហូតដល់អាចមើលឃើញព្រះជាម្ចាស់ផ្ទាល់ភ្នែក។

លោកអភិបាលរំលឹកទៅកាន់គ្រីស្តបរិស័ទដូច្នេះថា គ្រីស្តបរិស័ទទាំងអស់ត្រូវត្រៀមខ្លួនជានិច្ច ព្រោះជីវិតមិនទៀងទាត់ អាចមានជំងឺ ឬគ្រោះថ្នាក់ចរាចរណ៍ ដោយមិនដឹងជាមុន។ ប៉ុន្តែអ្វីដែលសំខាន់នោះ ពេលរស់នៅប្រចាំថ្ងៃ គឺត្រូវយកចិត្តទុកដាក់សួរសុខទុក្ខអ្នកជំងឺ អ្នកជាប់ឃុំឃាំង ផ្តល់ម្ហូបដល់អ្នកស្រេកឃ្លាន និងឱ្យអាវទៅមនុស្សខ្លួនទទេ និងរៀបចំបុណ្យសពត្រឹមត្រូវសម្រាប់អ្នកស្លាប់ ទាំងនេះគឺជាកិច្ចការទាំង៧នៃធម៌មេត្តាករុណាដែលគ្រីស្តបរិស័ទត្រូវតែធ្វើជាប្រចាំ។

នៅក្នុងឱកាសបុណ្យភ្ជុំបិណ្ឌនេះ នៅតាមព្រះសហគមន៍ក៏មានកម្មវិធីបាចទឹកព្រះពរនិងអធិដ្ឋាននៅតាមផ្នូរឬចេតិយរបស់គ្រីស្តបរិស័ទ ហើយព្រះសហគមន៍នៅតាមកន្លែងនីមួយៗតែងតែរៀបចំជាសំភារៈ គ្រឿងឧបភោគ និងម្ហូបអាហារជូនដល់អ្នកក្រីក្រ និងចាស់ជរាដែលគ្មានទីពឹង ដោយមានការចូលរួមថវិកាពីក្រុមគ្រួសារគ្រីស្តបរិស័ទនៃព្រះសហគមន៍នីមួយ៕

# កម្ពុជានឹងមានបូជាចារ្យ៣រូបបន្ថែមទៀតក្នុងពេលឆាប់ៗ



*អត្ថបទ៖ សួន ស្រីហួចដាលីស*

សំឡេងភ្លេងឆៃយ៉ាំលាន់កងរំពងយ៉ាងឱឡារិក មុខក្បួនដង្ហែរយុវជនបីរូបជានិស្សិតទេវវិទ្យាល័យ សន្តយ៉ូហាន ម៉ារី វីយ៉ាណៃរនាទីក្រុងភ្នំពេញ ដែលបានសុំថ្វាយខ្លួនទៅព្រះជាម្ចាស់ដោយមានអមជាមួយនឹងមាតាបិតារបស់លោក និងអស់លោកបូជាចារ្យនិងលោកអភិបាលព្រះសហគមន៍កាតូលិកកម្ពុជាទាំង៣ភូមិភាគ ហែចូលក្នុងពិធីតែងតាំងជាឧបដ្ឋាក។

ក្នុងពិធីយ៉ាងឱឡារិកនេះ លោកនាយកទេវវិទ្យាល័យ សួន ហង្សលី បានស្នើសុំលោកអភិបាលអូលីវីយេ ឆ្មីតហាស្លេ អភិបាលនៃព្រះសហគមន៍ភូមិភាគភ្នំពេញ ទទួលលោកទាំងបីជាឧបដ្ឋាកដោយមានប្រសាសន៍ថា លោកទាំងបីបានតស៊ូនៅក្នុងការអប់រំ ការសិក្សា និងនៅក្នុងផ្លូវិញ្ញាណ ហើយពេលនេះបានបញ្ចប់ការសិក្សានិងស្នើសុំលោកអភិបាលតែងតាំងពួកគាត់ជាឧបដ្ឋាក។

បេក្ខជនទាំងបីរូបមានលោកយ៉ូហានបាទីស្តវី សំណាង លោកអន់តូនី ថៃរតនៈ(ប៊ុនលី) និងលោក ប៉ូល វិន កាន់ បានឆ្លើយតបនឹងសំណួរលោកអភិបាលអូលីវីយេ បញ្ជាក់អំពីជំហររបស់ពួកគាត់ក្នុងកិច្ចការបម្រើព្រះជាម្ចាស់ក្នុងនាមជាអ្នកបួស។

លោកបញ្ជាក់ទៀតថា ឧបដ្ឋាក គឺ«បម្រើព្រះជាម្ចាស់» ដោយថ្វាយខ្លួនជាយញ្ញបូជាអស់កល្បជានិច្ច ហើយចាប់ពីពេលនេះតទៅជីវិតរបស់ពួកលោកលែងជាជីវិតឯកជនទៀតហើយ គឺត្រូវលះបង់ភាពផ្ទាល់ខ្លួនទាំងអស់ ដូចសន្តស្ទេផានជាឧបដ្ឋាកដំបូងនៅក្នុងព្រះសហគមន៍។

លោកអភិបាលបញ្ជាក់ទៀតថា បម្រើព្រះជាម្ចាស់ គឺត្រូវធ្វើអស់ពីសមត្ថភាពដែលយើងមានដោយមិនធ្វើតាមអារម្មណ៍ តែពោរពេញដោយអំណរសប្បាយរបស់ព្រះជាម្ចាស់ដែលនាំឱ្យមានកម្លាំងទៅមុខជានិច្ច។

លោកឧដ្ឋាកថ្មី ត្រូវបានបំពាក់ឯកសណ្ឋានជាឧបដ្ឋាក ដោយមានកន្សែង៣នា និងដាម៉ាតិច(អាវបំពង់វែង)របស់លោកឧបដ្ឋាករួចលុតជង្គង់ទទួលព្រះគម្ពីរពីលោកអភិបាល ជាសញ្ញាដើម្បីបំពេញបេសកកម្មប្រកាសព្រះបន្ទូល។

លោកឧបដ្ឋាកវិន កាន់ ទៅបម្រើព្រះសហគមន៍មណ្ឌលសកម្មភាពព្រះសីហនុ ជាមួយលោក





បូជាចារ្យឃុំាំងលូកា តាវ៉ូឡា។ លោកឧបដ្ឋាកវី សំណាង ទៅបម្រើព្រះសហគមន៍មណ្ឌលសកម្មភាពភ្នំពេញថ្មី ភ្នំពេញខាងត្បូង និងតាខ្មៅ ដែលមានលោកអភិបាលអូលីវីយេជាអ្នកណែនាំ។

លោកឧបដ្ឋាកប៊ុនលី ឲ្យដឹងថា ទំរាំបានមកដល់ថ្ងៃនេះ លោកបានឆ្លងកាត់នូវទុក្ខលំបាកនិងឧបសគ្គជាច្រើន ប៉ុន្តែអ្វីដែលអាចឲ្យលោកទៅមុខបានគឺ ការអធិដ្ឋានជាមួយព្រះជាម្ចាស់ ដើម្បីអាចនៅជាមួយព្រះអង្គដោយទុកចិត្ត និងផ្ញើជីវិតលើព្រះអង្គ។

លោកបន្តថា «បម្រើតុសក្ការៈគឺបម្រើព្រះគ្រីស្ត គឺទាំងពិធីបុណ្យនិងមនុស្ស។ ខ្ញុំនឹងព្យាយាមរស់នៅក្នុងទំនាក់ទំនងដោយយកចិត្តទុកដាក់សួរសុខទុក្ខអ្នកក្រីក្រ»

ក្នុងសំលៀកបំពាក់ថ្មីជាឧបដ្ឋាក លោកប៉ូល វិន កាន់ និយាយថា «ខ្ញុំមិននឹកស្មានថាព្រះជាម្ចាស់បានជ្រើសរើសខ្ញុំឱ្យទទួលការតែងតាំងអគ្គសញ្ញានេះដោយសារយើងជាអ្នកតូចតាចជាមនុស្សធម្មតាសាមញ្ញ តែព្រះជាម្ចាស់បានត្រាស់ហៅយើងឱ្យមានកិត្តិយស។ នៅពេលដែលខ្ញុំគិតរបៀបនេះ ខ្ញុំព្រឺសម្បុរ ដោយសារជីវិតខ្ញុំអស្ចារ្យមែនទែន»

លោកកាន់បន្ថែមថា «ស្រឡាញ់ និងបម្រើ» ជាពាក្យស្លោកឆ្លាក់នៅក្នុងដួងចិត្តរបស់លោក ក្នុងកិច្ចការប្រចាំថ្ងៃ ដែលនឹងត្រូវអនុវត្តក្រោយពេលទទួលអគ្គសញ្ញាតែងតាំងជាឧបដ្ឋាកនេះ។



> បម្រើតុសក្ការៈគឺ
> បម្រើព្រះគ្រីស្ត គឺទាំង
> ពិធីបុណ្យនិងមនុស្ស។
> ខ្ញុំនឹងព្យាយាមរស់នៅ
> ក្នុងទំនាក់ទំនងដោយ
> យកចិត្តទុកដាក់
> សួរសុខទុក្ខអ្នកក្រីក្រ

រីឯលោកឧបដ្ឋាក វី សំណាង មានប្រសាសន៍ថា «កាលពីយប់មិញខ្ញុំគេងមិនលក់ ហើយព្រឹកឡើងពេលអធិដ្ឋានតាមពេលកំណត់ ខ្ញុំស្រក់ទឹកភ្នែកនិងមើលឈើឆ្កាង»

«ខ្ញុំមានអារម្មណ៍រំភើបចង់ហោះ» ជាពាក្យដែលចេញពីមាត់លោក វី ចាន់ឌី ក្នុងនាមជាឪពុក របស់លោកឧបដ្ឋាកវីសំណាង។ លោកចាន់ឌីឲ្យដឹងទៀតថា នៅពេលកូននិយាយថា គាត់មានបំណងចង់ក្លាយជាបូជាចារ្យតាំងពីក្មេង ឪពុករូបនេះបានសម្រេចចិត្តថ្វាយកូនរបស់គាត់ទៅព្រះជាម្ចាស់ដោយបាននាំកូនប្រុសទៅព្រះវិហារទៀងទាត់។

ចំពោះលោកង្វៀង ឃុំាំង លើង ជាឪពុករបស់លោកឧបដ្ឋាក ថៃ រតនៈ ហៅប៊ុនលី បានឱ្យដឹងថា គាត់បានទន្ទឹងរង់ចាំពិធីនេះអស់រយៈពេល ១៦ឆ្នាំមកហើយ «ខ្ញុំចង់ឱ្យកូនខ្ញុំបំពេញតួនាទី

*អានបន្តទំព័រ-១៧..*

# ការចែកទានគឺជាទង្វើល្អនិងការជួយដែលកើតចេញពីទឹកចិត្តនិងសេចក្តីពិតដែលទទួលបានពីព្រះជាម្ចាស់

*អត្ថបទ៖ ព្រះសហគមន៍*

ក្រុមសង្គហៈព្រះសហគមន៍ព្រះកុមារយេស៊ូបឹងទំពុន នៃមណ្ឌលសកម្មភាពភ្នំពេញខាងត្បូងមានការចែកទានទៅដល់ក្រុមគ្រួសារដែលមានជីវភាពខ្វះខាតចំនួន២០គ្រួសារនៅក្នុងរដូវបុណ្យភ្ជុំបិណ្ឌ ក្រោមអធិបតីភាព លោកបូជាចារ្យ ដាមីញ៉ាំង ហ្វារនី អ្នកទទួលខុសត្រូវមណ្ឌលសកម្មភាពព្រះសហគមន៍កាតូលិកភ្នំពេញខាងត្បូងកាលពីព្រឹកថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២២ ។



លោកបូជាចារ្យដាមីញ៉ាំងមានប្រសាសន៍ថា អំណោយដែលបានចែកជូនបងប្អូនក្រីក្រនៅពេលនេះ បានមកពីគ្រីស្តបរិស័ទ និងសប្បុរសជនដែលបានចូលរួមជាមួយគ្នាដើម្បីចែករំលែកសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះពួកគាត់។

លោកបូជាចារ្យបានបញ្ជាក់ថា «មិនមែនខ្ញុំទេ ដែលចែកជូនបងប្អូន គឺគ្រីស្តបរិស័ទនិងអ្នកផ្សេងៗជួយគ្នា»

ជាមួយគ្នានេះដែរ អ្នកស្រី ងួន ផល្លា គណៈកម្មការសង្គហៈបាននិយាយទាំងទឹកមុខអំណរសប្បាយថា ៖ «រាល់ថ្ងៃនេះ យើងជួយអ្នកក្រីក្រមាន៣ប្រភេទ គឺគ្រួសារក្រីក្ររើសអេតចាយដែលមានកូនប្រើប្រាស់គ្រឿងញៀន ចាស់ជរាមានជំងឺប្រចាំកាយ និងកូនសិស្សកំពុងសិក្សានិងរស់នៅជាមួយក្រុមគ្រួសារដែលផ្ទុកមេរោគអេដស៍»

អ្នកស្រីបន្តថា ទោះបីជាការចែកទាននេះមិនសូវច្រើនលើសលប់ ប៉ុន្តែអាចជួយសម្រួលនូវជីវភាពរបស់គាត់បានមួយគ្រា។ មួយវិញទៀតការជួយគឺជួយមិនគិតទៅលើគ្រួសារគ្រីស្តបរិស័ទឬមិនមែនគ្រីស្តបរិស័ទនោះទេ។

អ្នកស្រីបន្ថែមថា ពួកគាត់មិនមែនជាអ្នកមាននោះទេ ប៉ុន្តែពួកគាត់សប្បាយចិត្តនឹងជួយអ្នកដែលខ្វះខាតនិងអត់ជាងខ្លួន។ អ្នកស្រីផល្លាបញ្ជាក់ថា អំណោយទាំងនេះ ក៏ចូលរួមពីពុទ្ធបរិស័ទផងដែរ។

ការចែកសេចក្តីស្រលាញ់នឹងការចែកទានមិនគិតទៅលើសាសនាអ្វីនោះទេ សំខាន់ទង្វើល្អនិងការជួយរបស់យើងកើតចេញទឹកចិត្តនឹងសេចក្តីស្រលាញ់ពិតប្រាកដដែលយើងទទួលបានពីព្រះជាម្ចាស់ ។ នេះជាការបញ្ជាក់របស់អ្នកស្រីផល្លា។

អ្នកស្រី យ៉ែម ចន្ថេន ជាពុទ្ធបរិស័ទនិងជាម្ចាស់ហាងណារិនកាត់ដេរ បាននិយាយថា «ការចែកទាននេះគឺធ្វើទៅពិតៗ ទោះជាបីជាព្រះពុទ្ធសាសនាក៏មានធ្វើបែបនេះដែរ ហើយសម្រាប់អ្វីដែលយើងអាចចែករំលែកបានយើងគួរតែចែករំលែកទៅដល់គ្រួសារដែលអត់ជាងយើង»

អ្នកស្រីចន្ថេនបន្តលើកឡើងទៀតថា ៖ «អ្វីដែលយើងគិតថាល្អគឺយើងធ្វើទៅ កុំអោយតែយើងទៅប្រព្រឹត្តអំពើបាប»។



បុរសពិការដៃ ឈ្មោះ ម៉ៅ សុខកង ដែលមានអាយុ៥៣ឆ្នាំ បានមកទទួលអំណោយពីព្រះសហគមន៍បាននិយាយថា ៖ «ខ្ញុំពិតជាសប្បាយចិត្តដែលព្រះសហគមន៍បានជួយដល់គ្រួសារក្រីក្រដូចជារូបខ្ញុំ ព្រោះខ្ញុំវាអត់ ហើយបានព្រះសហគមន៍ជួយបែបនេះធ្វើអោយគ្រួសារខ្ញុំ ហូបបានមួយគ្រាធំ និងធ្វើអោយខ្ញុំមានចិត្តតស៊ូ ប្រឹងបន្តដំណើរជីវិតទៅមុខទៀត»



ពេលជាមួយគ្នានេះ អ្នកស្រីសាម សុខា អាយុ៤២ឆ្នាំ រៀបរាប់ទាំងទឹកភ្នែកថា «ខ្ញុំពិតជារំភើបខ្លាំងមិនដឹងរកពាក្យអ្វីមកនិយាយ។ ខ្ញុំក្តុកក្តួលខ្លាំង ព្រោះខ្ញុំជាគ្រួសារដែលមានជីវភាពលំបាកហើយមានជម្ងឺប្រចាំកាយទៀត ខ្ញុំមានតែពាក្យថា អរគុណខ្លាំងណាស់ចំពោះព្រះសហគមន៍ដែលបានចែកទាននេះមកកាន់គ្រួសារក្រីក្រដូចជាខ្ញុំ»



សព្វថ្ងៃនេះក្រុមសង្គហៈព្រះសហគមន៍ព្រះកុមារយេស៊ូបឹងទំពុននៅតែបន្តជួយដល់គ្រួសារដែលផ្ទុកមេរោគអេដស៍ គ្រួសារដែលបាត់បង់កម្លាំងពលកម្ម ជារៀងរាល់ខែដែលថវិកាទាំងនោះ ទទួលបានពីដង្វាយរបស់បងប្អូនគ្រីស្តបរិស័ទ និងជាពុទ្ធបរិស័ទ ដើម្បីរួមគ្នាទិញជាគ្រឿងឧបភោគបរិភោគ សម្ភារប្រើប្រាស់ដើម្បីចែកជូនទៅគ្រួសារទីទ័លដែលរស់នៅក្នុងសង្កាត់បឹងទំពុនទី១ និងទី២៕

ឱ្យបានល្អ និងណែនាំអ្នកជិតខាងឱ្យបានសុខសប្បាយទាំងអស់គ្នា»

ជាមួយគ្នានោះដែរ លោកអភិបាលអូលីវីយ៉េមានប្រសាសន៍ទៀតថា ព្រះសហគមន៍កម្ពុជាមានការត្រាស់ហៅតិច ហើយនេះជាផ្លែដែលបានទទួលនៅក្នុងជីវិតរបស់លោកឧបដ្ឋាកទាំងបី ទាំងព្រះសហគមន៍ ទាំងសាលាដុនបូស្កូ និងលោកបូជាចារ្យដែលបានអធិដ្ឋានសម្រាប់ការត្រាស់ហៅ។

លោកអភិបាលបញ្ជាក់ថា «នេះជាកម្លាំងមួយដើម្បីឱ្យយើងបន្តប្រកាសដំណឹងល្អ ដើម្បីឱ្យយើងទៅជាអ្នកបម្រើ ព្រោះឧបដ្ឋាកមានន័យថា «បម្រើ» ដោយសន្យានៅលីវអស់មួយជីវិតដើម្បីថ្វាយខ្លួនទៅព្រះជាម្ចាស់ ទៅបងប្អូន និងព្រះសហគមន៍»

មកដល់ពេលបច្ចុប្បន្ននេះ ព្រះសហគមន៍នៅកម្ពុជាមានលោកបូជាចារ្យជាតិកម្ពុជាចំនួន១០នាក់ប៉ុណ្ណោះក្នុងចំណោមសាសនទូតបរទេសជិត១០០នាក់ដែលកំពុងបម្រើការងារនៅក្នុង ព្រះសហគមន៍ចំនួនជាង៨០ ទោះបីជាព្រះសហគមន៍នៅកម្ពុជាបានកកើតឡើងតាំងពីសតវត្សទី១៦មកក៏ដោយ។ ដោយសារតែសង្គ្រាមរាប់មិនអស់នៅក្នុងប្រទេស ជាពិសេសក្នុងរបបប៉ុលពត បានបំផ្លាញស្ទើរតែទាំងស្រុងនូវសាសនានិងហេដ្ឋារចនាសម្ព័ន្ធរបស់ជាតិ ក្នុងនោះលោកអភិបាលជាតិខ្មែរ និងសហការីរបស់លោក អស់លោកបព្វជិត-ជិតា និងគ្រីស្តបរិស័ទជាច្រើនបានស្លាប់និងត្រូវបានសម្លាប់។

មកដល់ពេលនេះ គ្រីស្តបរិស័ទនៅក្នុងប្រទេសកម្ពុជាមានចំនួនតិចតួចនៅឡើយ គឺប្រមានជា២ម៉ឺននាក់ក្នុងចំណោមប្រជាជនជិត១៦លាននាក់៕

# គ្រូអប់រំជំនឿត្រូវការជំនឿនិងទ្រឹស្តី

*អត្ថបទ៖ សួន ស្រីហួចដាលីស*

គ្រូអប់រំជំនឿ៤៧នាក់មកពីមណ្ឌលសកម្មភាព៣ក្នុងភូមិភាគភ្នំពេញបានសិក្សាឈ្វេងយល់អំពីគរុកោសល្យនៃការបញ្ជូនបន្តជំនឿ និងប្រវត្តិព្រះសហគមន៍កាតូលិកនៅកម្ពុជានិងជាសកល នៅព្រះវិហារសន្តីម៉ារីញញឹមចំការទៀង ក្នុងស្រុកត្រាំកក់ ខេត្តតាកែវ នាថ្ងៃទី១៧និង១៨ កញ្ញា ២០២២ ។

លោក ដួង សារង់ គណៈកម្មការអប់រំជំនឿភូមិភាគភ្នំពេញមានប្រសាសន៍ថា ការកកើតព្រះសហគមន៍គឺតាមរបៀបសាមញ្ញៗ ដោយមានការណែនាំ និងជំរុញពីព្រះអំណោយទានរបស់ព្រះជាម្ចាស់ ដោយមានគ្រឹះគឺព្រះយេស៊ូដែលសោយទិវង្គតនិងមានព្រះជន្មរស់ឡើងវិញ។





លោកអភិបាលអូលីវីយ៉េ បានរំឭកដល់គ្រូអប់រំជំនឿដូច្នេះថា ព្រះសហគមន៍គឺជាស្ថាប័នចាស់ជាងគេក្នុងពិភពលោក ដែលមានព្រះជាម្ចាស់ជាអង្គតែមួយ ដោយខិតខំសម្រុះសម្រួល រិះគិត និងដើរជាមួយគ្នាក្នុងព្រះសហគមន៍ ដោយណែនាំមនុស្សមានជីវិតអស់កល្បជានិច្ចតាមរយៈជំនឿ។

សិក្ខាកាមតាមមណ្ឌលសកម្មភាពនីមួយៗបានចែករំលែកបទពិសោធនៃការអប់រំជំនឿ និងរបៀបនៃការបង្កើតព្រះសហគមន៍នីមួយៗ។

នៅក្នុងសិក្ខាសាលានេះ លោកអភិបាលអូលីវីយ៉េ មានប្រសាសន៍អំពីការកកើតព្រះសហគមន៍នៅកម្ពុជាតាំងពីឆ្នាំ១៥៥៥ រហូតមកដល់ពេលបច្ចុប្បន្ននេះ។

លោកអភិបាលអធិដ្ឋានសូមព្រះវិញ្ញាណដ៏វិសុទ្ធ ជាពន្លឺបំភ្លឺគ្រូអប់រំជំនឿឱ្យស្គាល់សេចក្តីពិតដោយមានព្រះជាម្ចាស់ជាផ្លូវ ជាសេចក្តីពិត និងជាជីវិត និងបាចទឹកព្រះពរដល់គ្រូអប់រំជំនឿទាំងអស់។ លោកក៏សូមព្រះវិញ្ញាណសណ្ឋិតលើគ្រូអប់រំជំនឿទាំងអស់ឱ្យទៅជាសាក្សីភាពនិងមានភាពក្លាហានក្នុងការប្រកាសជំនឿដោយសេចក្តីពិត។

លោកមាឃ ស៊ិន មកពីព្រះសហគមន៍ចំការទៀងរៀបរាប់ថា សិក្ខាសាលានេះធ្វើឱ្យខ្ញុំទទួលបានបទពិសោធថ្មីដែលមានលក្ខណៈតម្រង់ទិសដើម្បីអប់រំជំនឿនៅក្នុងព្រះសហគមន៍របស់លោកផ្ទាល់ឱ្យកាន់តែប្រសើរ។ លោកមាឃ ស៊ិន បញ្ជាក់ទៀតថា «សិក្ខាសាលានេះធ្វើឱ្យខ្ញុំយល់ថា អប់រំជំនឿ គឺអប់រំឱ្យគេជឿមិនមែនដើម្បីឱ្យចេះទេ។»

អ្នកស្រី ង៉ែត សារូ បានឱ្យដឹងថា សិក្ខាសាលានេះទោះបីមានរយៈពេលខ្លី តែជួយឱ្យគាត់ឲ្យស្គាល់ពីប្រវត្តិព្រះសហគមន៍នីមួយៗ បានយល់ពីតួនាទីរបស់ខ្លួននិងការប្រើប្រាស់សៀវភៅដើម្បីអប់រំជំនឿ ជាពិសេសមានការចាត់តាំងជាផ្លូវការរបស់លោកអភិបាលឱ្យទៅបម្រើការអប់រំជំនឿដែលជាការលើកទឹកចិត្តដល់អ្នកណែនាំជំនឿ។

គ្រូអប់រំជំនឿទាំងនោះមកពី ព្រះវិហារម៉ារីញញឹមចំការទៀង ព្រះវិហារសន្តីតេរេសានៃព្រះកុមារយេស៊ូ (ព្រៃកប្បាស) ព្រះវិហារព្រះត្រៃឯកគីរីវង់ ព្រះវិហារសន្តប៉ូល ព្រះវិហារបាទីព្រះសហគមន៍កំពង់អំពិល ព្រះសហគមន៍ត្រពាំងក្រញូងមានគ្រីស្តបរិស័ទ១៤នាក់ ព្រះសហគមន៍ក្រុងតាកែវ ព្រះវិហារសន្តមីកាអែល(កំពង់សោម) ព្រះវិហារសន្តម៉ាថាយកោះកុង ព្រះវិហារសន្តីតេរេសានៃព្រះកុមារយេស៊ូ (ស្រែអំបិល) ព្រះវិហារសន្តអូគូស្តាំង(កំពត) ព្រះវិហារសន្តយ៉ូសែប(ជុំគីរី) ព្រះវិហារសន្តប៉ូល(កោះស្លា) ព្រះវិហារសន្តីម៉ារី(ត្រពាំងរុន) ព្រះវិហារសន្តសិលា(ព្រៃកប្រស់)។

លោកអភិបាលអូលីវីយ៉េ បានបន្ថែមថា ពេលនេះយើងបើកឆ្នាំសិក្សាថ្មី និងបំពេញពាក្យសន្យាយកចិត្តទុកដាក់អប់រំជំនឿនៅតាមព្រះសហគមន៍ពេញមួយឆ្នាំ ។

# គ្រីស្តសាសនានិងពុទ្ធសាសនារួមគ្នាជួយអ្នកក្រីក្រ

*អត្ថបទ៖ សួន ស្រីហួចដាលីស*

ជនក្រីក្រ៣៣០គ្រួសារ ទទួលគ្រឿងឧបភោគបរិភោគពីព្រះសហគមន៍កាតូលិកនិងព្រះសង្ឃខាងព្រះពុទ្ធសាសនា នៅព្រះវិហារសន្តហ្វ្រង់ស្វ័រសាវីយ៉េ (ព្រះសហគមន៍ចំប៉ា) នៅភូមិចំប៉ា ស្រុកកៀនស្វាយ ខេត្តកណ្តាល។









តាមប្រសាសន៍របស់លោកបូជាចារ្យ វិរជ័យ ស៊្រីប្រាម៉ុង បានឱ្យដឹងថា «គោលបំណងចង់ចែកជូនដល់ប្រជាជនក្រីក្រក្នុងឱកាសបុណ្យភ្ជុំ និងបងប្អូនដែលរងគ្រោះដោយទឹកលិច»។

លោកបូជាចារ្យបន្ថែមថា នៅក្នុងឱកាសនេះដែរក៏មានក្រុមព្រះសង្ឃខាងព្រះពុទ្ធសាសនា ធ្វើការជាមួយទូតនៅសមាគមវៀតណាម ដែលជួយតាមភូមិវៀតណាមដែលមានទឹកលិចឬមានបញ្ហានានា បានស្នើចូលរួមជួយចំនួន២០០គ្រួសារ រួមជាមួយព្រះវិហារសន្តហ្វ្រង់ស្វ័រសាវីយ៉េ ចំនួន១៣០គ្រួសារ។ ការផ្តល់ជូននេះ ក៏មានអ្នកក្រជនជាតិខ្មែរជុំវិញភូមិចំនួន១៣០គ្រួសារផងដែរ។

តាមប្រសាសន៍លោកបូជាចារ្យដដែលបានឱ្យដឹងទៀតថា ការសម្តែងធម៌មេត្តាករុណា ជាព្រះយេស៊ូដែលបង្រៀនយើងឱ្យចេះបង្ហាញសេចក្តីស្រឡាញ់ដល់អ្នកក្រីក្រ អ្នកជិតខាង។

គ្រឿងបរិភោគដែលបានចែកជូនដល់ជនក្រីក្រចំនួន៣៣០គ្រួសារ នាថ្ងៃទី៤ កញ្ញា ២០២២ ទាំងនោះមាន អង្ករ១០គីឡូ និងមី ១០កញ្ចប់ក្នុងមួយគ្រួសារ៕

# កុមារគ្រីស្តបរិស័ទឈ្វេងយល់អំពីបេសកកម្មរបស់ខ្លួន













*អត្ថបទ៖ សួន ស្រីហួចដាលីស*

កុមារជិត២០០នាក់នៃមណ្ឌលសកម្មភាពភ្នំពេញខាងជើង បានចូលរួមជាមួយគ្នាបោះជំរំរិះគិតលើបេសកកម្មក្នុងនាមជាកុមារគ្រីស្តបរិស័ទ ធ្វើនៅព្រះវិហារសន្តយ៉ូសែប ផ្សារតូច នារាជធានីភ្នំពេញ។

លោកបូជាចារ្យ ប៉ូល រឿង ឆ័ត្រសិរី ជាប្រធានមណ្ឌលសកម្មភាពព្រះសហគមន៍កាតូលិកភ្នំពេញខាងជើងមានប្រសាសន៍ថា កុមារទាំងនោះភាគច្រើនជាកូនគ្រីស្តបរិស័ទ និងកំពុងរៀនអប់រំជំនឿ ហើយកម្មវិធីបោះជំរំនេះ គឺដើម្បីឲ្យពួកគាត់អនុវត្តនូវអ្វីដែលគាត់បានរៀន។

លោកបូជាចារ្យបន្ថែមថា ការជួបជុំនេះ គឺដើម្បីឱ្យកុមារទាំងអស់ស្គាល់គ្នា និងមានទំនាក់ទំនងល្អនៅពេលអនាគត ទោះបីជាពួកគាត់មកពីព្រះសហគមន៍ផ្សេងៗក៏ដោយ។ លោកបន្តថា នៅពេលធំឡើងពួកគាត់ក៏អាចជួយព្រះសហគមន៍ឱ្យមានភាពរឹងមាំ ដោយមានការសហការគ្នា លើកទឹកចិត្តគ្នា និងរស់នៅជាសាក្សីនៃជំនឿ។

កម្មវិធីបោះជំរំកុមារនេះ ទទួលកុមារពីអាយុ៥ដល់១៨ឆ្នាំ ដែលមកពីព្រះសហគមន៍មួយចំនួនក្នុងមណ្ឌលសកម្មភាពភ្នំពេញខាងជើង រួមមាន៖ ផ្សារតូច ព្រែកតាទែន សែនសុខ ស្វាយប៉ាក អិរយក្សត្រ ពោធិ៍ធំ និងក្ដីកណ្ដាល។

លោកឆ័ត្រសិរីបញ្ជាក់ថា ដូច្នេះអ្វីដែលគាត់គួរតែធ្វើគឺបង្ហាញជំនឿរបស់គាត់តាមអ្វីដែលគាត់អាចធ្វើបានរួមទាំងការបង្ហាញជំនឿដល់អ្នកនៅជុំវិញខ្លួនរបស់ពួកគាត់ផងដែរ។

លោកបូជាចារ្យបន្ថែមថាទោះបីជាព្រះសហគមន៍មានគ្នាតិចនៅក្នុងសង្គម ប៉ុន្តែពេលឃើញមនុស្សជួបបញ្ហា គាត់ត្រូវបញ្ចេញសកម្មភាព។ «គាត់អាចធ្វើបុណ្យ ធ្វើទាន តាមសមត្ថភាពរបស់គាត់ ចេះសន្សំសំចៃ និងជួយតាមកម្លាំងរបស់គាត់។» លោកឆ័ត្រសិរីបញ្ជាក់។

នៅក្នុងប្រទេសកម្ពុជា គ្រីស្តសាសនានិកាយកាតូលិកមានប្រហែល២០០០០នាក់ប៉ុណ្ណោះ ក្នុងចំណោមប្រជាជនជិត១៦លាននាក់។

នៅក្នុងកម្មវិធីនោះដែរ កុមារទាំងអស់បានស្នាក់នៅនិងរៀនអំពីរបៀបរស់នៅជាក្រុម សិក្សាបន្ថែមអំពីជំនឿ ការជួយគ្នាទៅវិញទៅមក រៀនពីសុភាវធម៌ សុជីវធម៌ និងចេះស្រឡាញ់បរិស្ថាន និងលេងល្បែងកំសាន្តនានា។

លោក ហេង ច័ន្ទរិទ្ធី ជាអ្នកសម្របសម្រួល និងជាប្រធានក្រុមយុវជននៅព្រះវិហារសន្តយ៉ូសែប ផ្សារតូច បានឱ្យដឹងថា ការបោះជំរំកុមារលើកនេះ ពួកយើងចង់ប្រមូលផ្ដុំយុវជនក៏ដូចជាក្មេងៗនៅក្នុងតំបន់មណ្ឌលសកម្មភាពភ្នំពេញខាងជើងចូលរួមគ្នាជាផ្លុងតែមួយតាមរយៈសកម្មភាពផ្សេងៗដែលទាក់ទងទៅនឹងសាររបស់សម្ដេចប៉ាបក្នុងសន្និបាតព្រះសហគមន៍សកល។

កម្មវិធីដែលបានធ្វើឡើងរយៈពេល៣ថ្ងៃ គឺពីថ្ងៃទី១១-១៤ ខែសីហា កន្លងទៅ បានចែកចេញជាបីផ្នែកសំខាន់ៗ។ ប្រធានក្រុមយុវជនរូបនេះ បន្ថែមថា ការជួបជុំគ្នានៅថ្ងៃសុក្រ គឺឲ្យកុមារចូលរួម ជាមួយគ្នា ស្គាល់គ្នារាប់ជាគ្នាជាមិត្តភក្តិ។

រីឯថ្ងៃសៅរ៍យើងគិតពីកម្លាំងជម្នះ គឺមានន័យថាក្រោយពេលដែលគាត់មានមិត្តភក្តិហើយ កុមារប្រឈមមុខនឹងការឈ្លោះទាស់ទែងគ្នា និងមានការបែកបាក់គ្នា ដូច្នេះគណៈកម្មការយើងបានរៀបចំដំណោះស្រាយ ធ្វើយ៉ាងណាឱ្យគាត់បានត្រូវរ៉ូវគ្នាវិញ។ ច័ន្ទរិទ្ធីបន្ថែមថា ថ្ងៃបញ្ចប់គឺបញ្ចៀបអំពីបេសកកម្ម ដើម្បីឲ្យពួកគាត់អាចបង្កើតកម្មវិធីនានា និងដើម្បីនាំកុមារដែលចង់ស្គាល់ពីព្រះយេស៊ូឱ្យចូលរួមជាមួយគ្នានៅតាមព្រះសហគមន៍របស់ពួកគាត់។

កុមារា សុខ រតនពង្ស មកពីព្រះវិហារគីឡូម៉ែត្រលេខ១១ និយាយថា នេះជាលើកទី២ដែលគាត់បានចូលរួមបោះជំរំនេះ។ រតនពង្សបន្តថា កាលពីដំបូងគាត់មានអារម្មណ៍ខ្លាចគេ ប៉ុន្តែក្រោយមកគាត់មានមិត្តច្រើន ធ្វើឲ្យគាត់មានភាពក្លាហានជាងមុន និងធ្វើឱ្យគាត់សប្បាយចិត្ត។

កុមារា រូបនេះបន្ថែមថា «នៅពេលខ្ញុំត្រលប់ទៅវិញ ខ្ញុំធ្វើរឿងល្អជាមួយអ្នកជុំវិញ ដូចជាឃើញគេបាត់អីត្រូវជួយរកគេ ពេលឃើញគេមានរឿងអីខ្ញុំត្រូវមកសួរនិងជួយគេ។»

ក្នុងវ័យ១៥ឆ្នាំកុមារី ធូ ទ្រី រៀបរាប់ថា ក្នុងនាមជាកូនគ្រីស្តបរិស័ទជាកុមាររបស់ព្រះសហគមន៍ កម្មវិធីបោះជំរំនេះបានជួយឱ្យយើងចេះរួបរួមគ្នា ចេះស្រឡាញ់មិត្តភក្តិ។ ធូ ទ្រីបន្ថែមថា ក្រោយពីបញ្ចប់កម្មវិធីនេះ «ខ្ញុំនឹងទៅជួយដល់កុមារនៅព្រះសហគមន៍របស់ខ្ញុំ ឱ្យចេះជួយគ្នា រួបរួមគ្នា»៕

# សកម្មភាពនានារបស់ព្រះសហគមន៍កាតូលិកកម្ពុជា

## ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ



## ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម



## ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង

